# សទ្ទានុក្រមពាក្យថ្មី

វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា  រាជធានីភ្នំពេញ

បោះពុម្ពលើកទី១ក្នុងឆ្នាំ២០១៨ដោយវិទ្យាស្ថានភាសាជាតិ រក្សាសិទ្ធិ

© ២០១៨ វិទ្យាស្ថានភាសាជាតិ

សមាសភាពអ្នកស្រាវជ្រាវគម្រោង ៖

- **ទីប្រឹក្សា** ៖ ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ**
- **អ្នកត្រួតពិនិត្យរួម** ៖ ឯកឧត្តមបណ្ឌិត **ជួរ គារី**
- **ក្រុមស្រាវជ្រាវ** ៖

១. លោក **កែវ លីណែត** ប្រធាន
២. លោកបណ្ឌិត **ជុំ ស៊ុនណាង** សមាជិក
៣. លោកស្រីបណ្ឌិត **ហង់ ថាវី** សមាជិក
៤. លោកស្រី **តិប ស៊ីណា** សមាជិក

**ក្របសៀវភៅ ៖** ដើមឆ្វេះនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន
ឫស្សីត្រឹប © **កែវ លីណែត**

**ព.ស.២៥៦២** **គ.ស.២០១៨**

# និវេទនកថា

វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាបានបោះពុម្ពវចនានុក្រមខ្មែរចំនួនពីរលើកមកហើយ។ ក្នុងឆ្នាំ២០០៥ វិទ្យាស្ថានបានបោះពុម្ព **វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ** ដែលមានមេពាក្យនិងកូនពាក្យប្រមាណបួនម៉ឺនមួយពាន់។ ក្នុងឆ្នាំ២០១៧ វិទ្យាស្ថានបានបោះពុម្ព **វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ** ដោយដាក់សូរអាន និង មានមេពាក្យប្រមាណបួនម៉ឺន។

តាមការវិវត្តសង្គម យើងសង្កេតឃើញពាក្យមួយចំនួនបានលេចឡើងជាទម្រង់វចនតាថ្មីឬរក្សាទម្រង់ដដែលតែមានបម្រែបម្រួលផ្នែកន័យ។ ដូច្នេះ ការងារក្នុងវិស័យវចនលេខន៍ (lexicography) ជាការងារនិរន្ត ដែល, ជាធម្មតា, បន្តពីជំនាន់មនុស្សមួយទៅជំនាន់មនុស្សមួយទៀត។

សទ្ទានុក្រមនេះអាចជាផ្នែកតូចមួយនៃការរួមចំណែកក្នុងវិស័យវចនលេខន៍។ គេតោងទទួលស្គាល់ថា នៅពេលដែលពាក្យមួយត្រូវគេយកមករៀបរៀងក្នុងសទ្ទានុក្រមឬវចនានុក្រមនោះ ពាក្យថ្មីឯទៀតបានលេចឡើង។ ទោះយ៉ាងណាក្តី ការតាមដាននិងការចងក្រងតាមបែបវិទ្យាសាស្រ្តអាចធ្វើឱ្យគេយល់បានទិដ្ឋភាពស៊ីជម្រៅនៃភាសាមួយបាន។

មេពាក្យឬកន្សោមពាក្យដែលយើងបានរៀងរៀងឡើងនេះមានប្រភពភាគច្រើនមកពី ផ្នែករុក្ខវិទ្យា, សត្វវិទ្យា និង ផ្នែកវប្បធម៌។ យើងបានជ្រើសរើសយកពាក្យពីផ្នែករុក្ខវិទ្យាច្រើនជាងពាក្យពីផ្នែកឯទៀត។ ជាទូទៅ យើងមិនយកឈ្មោះរុក្ខជាតិដែលមានក្នុងវចនានុក្រមខ្មែរឆ្នាំ១៩៦៧-៦៨មកពន្យល់ទេ។ យើងបានផ្អែកច្រើនលើឯកសាររបស់លោកស្រីបណ្ឌិត **ឌី ផុន ប៉ូលីន**។ ទោះយ៉ាងណាក្តី យើងមិនស្រង់ឈ្មោះរុក្ខជាតិទាំងអស់មកដែរ។ យើងបានផ្ទៀងផ្ទាត់នឹងឯកសារអ្នកនិពន្ធមួយចំនួនផ្សេងទៀត មុន

នឹងជ្រើសយកមកចុះធ្វើជាមេពាក្យក្នុងសទ្ទានុក្រមនិងផ្តល់និយមន័យ។ យើងក៏ស្វែងរកព័ត៌មានទៅតាមលទ្ធភាពដែលរកបានតាមអ៊ីនធឺណិត ដើម្បីរំលេចលក្ខណសម្បត្តិរបស់រុក្ខជាតិនីមួយៗ។ កិច្ចការនេះស្ថិតក្នុងគម្រោងដែលមានរយៈពេលខ្លី ដូច្នេះ គង់នឹងមានចំណុចខ្វះខាតច្រើនដែលគេអាចបន្ថែមឬពង្រីកលើកិច្ចការនេះ នាពេលអនាគត។

មានទិដ្ឋភាពសង្គមវប្បធម៌ខ្មែរច្រើនទៀតដែលអ្នកស្រាវជ្រាវនានាគួរចងក្រងធ្វើជាសទ្ទានុក្រមឬវចនានុក្រម។ ក្នុងបរិវេណនៃការស្រាវជ្រាវនេះ យើងសង្ឃឹមថា សទ្ទានុក្រមនេះអាចរួមចំណែកខ្លះក្នុងវិស័យវចនលេខន៍ខ្មែរ៕

# មាតិកា


សេចក្តីថ្លែងអំណរគុណ

និវេទនកថា

អក្សរសង្ខេប

ព្រៃឈើនិងរុក្ខជាតិមួយចំនួននៃប្រទេសកម្ពុជា

ក-អ

**ឧបសម្ព័ន្ធ១** *សម្រង់សេចក្តីទាក់ទងនឹងឈ្មោះរុក្ខជាតិ តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរមួយចំនួន*

**ឧបសម្ព័ន្ធ២** *សម្រង់ឈ្មោះរុក្ខជាតិ ពីវចនានុក្រមខ្មែរគ.ស.១៩៦៧-៦៨*

# សេចក្ដីថ្លែងអំណរគុណ

កិច្ចការស្រាវជ្រាវនេះសម្រេចបានតាមរយៈការឧបត្ថម្ភថវិកាគម្រោងរបស់រាជបណ្ឌិត្យសភាកម្ពុជាក្រោមការដឹកនាំដ៏វាងវៃរបស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ ទូច**។ លើសពីនេះ ឯកឧត្តមបណ្ឌិត **យង់ ពៅ**, អគ្គលេខាធិការ, និង មន្ត្រីទាំងអស់នៅផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៃរាជបណ្ឌិត្យសភាកម្ពុជាជាចំណែកដ៏សំខាន់ដែលបានជួយធ្វើឱ្យគម្រោង របស់យើងប្រព្រឹត្តទៅដោយរលូន ក្នុងនោះ, ជាពិសេស, យើងសូមថ្លែងអំណរគុណចំពោះ លោក **ប៊ុត សុម៉េត**, លោក **គិម វុទ្ធី** និង លោក **ហួត រ៉ា**។

ឯកឧត្តមបណ្ឌិត **ជួរ គារី** ប្រធានវិទ្យាស្ថានភាសាជាតិ បានជួយជំរុញឱ្យមាន គំនិតថ្មីៗក្នុងការស្រាវជ្រាវស្របតាមបរិបទជាតិនិងអន្តរជាតិ។ មន្ត្រីវិទ្យាស្ថានភាសាជាតិ ទាំងអស់បានផ្ដល់មតិនិងលើកទឹកចិត្តក្នុងការស្រាវជ្រាវលើប្រធានបទថ្មីៗ, ជាពិសេស, លោកស្រី **អ៊ឹង ម៉ាល័យ** លេខាអចិន្ត្រៃយ៍រដ្ឋបាលនៃវិទ្យាស្ថានភាសាជាតិ បានខ្នះខ្នែងដើម្បី ឱ្យកិច្ចការរបស់យើងធ្វើទាន់ពេលវេលា៕

# អក្សរសង្ខេប

| | |
|---|---|
| ន. | នាមសព្ទ |
| កិ. | កិរិយាសព្ទ |
| គុ. | គុណនាម |
| គុ.កិ. | គុណកិរិយា |
| ចិ. | ចិន |
| បា. | បាឡី |
| បារ. | បារាំង |
| ព.ពុ. | ពាក្យពុទ្ធសាសនា |
| ព.មេ. | ពាក្យមេមត់ |
| ព. ប្រ. | ពាក្យប្រៀប |
| ម.ព. | មើលពាក្យ |
| ស. | សៀម |
| សំ. | សំស្ក្រឹត |

# ព្រៃឈើនិងរុក្ខជាតិមួយចំនួន
# នៃប្រទេសកម្ពុជា

## ១. ព្រៃឈើនិងរុក្ខជាតិកម្ពុជា

ស្ថានភាពភូមិសាស្ត្រព្រះរាជាណាចក្រកម្ពុជាចែកជា៣សណ្ឋាន គឺ ១. តំបន់ភ្នំ ដែលមានជួរភ្នំជាប់ឆ្នេរសមុទ្រ, ២. តំបន់ទន្លេសាបនិងវាលទំនាបទន្លេមេគង្គ ៣. តំបន់ជួរភ្នំតាមបណ្ដោយព្រំដែនប្រទេសវៀតណាមនិងប្រទេសឡាវ។[1] ស្ថានភាពភូមិសាស្ត្រនេះមានអំណោយផលចំពោះមនុស្សសត្វរុក្ខជាតិ។

នៅសម័យបុរាណ, តាមឯកសារប្រវត្តិសាស្ត្រ, អ្នកដឹកនាំខ្មែរក៏មានគោលនយោបាយអភិរក្សព្រៃឈើដូចអ្នកដឹកនាំខ្មែរជំនាន់ក្រោយៗដែរ។

តាមសិលាចារឹក, នៅសម័យមុនអង្គរក៏ដូចជាសម័យអង្គរ, ព្រះមហាក្សត្រដែលជាម្ចាស់កម្មសិទ្ធិលើទឹកដីព្រៃទាំងឡាយបានផ្ដល់សិទ្ធិដល់មន្ត្រីនិងប្រជារាស្ត្ររបស់ព្រះអង្គឱ្យមានសិទ្ធិកាន់កាប់និងចាត់ចែងដីស្រែចម្ការច្បារដំណាំ។ កម្មសិទ្ធិនេះមានលក្ខណៈយូរអង្វែងដែលអាចបន្តរាប់រយឆ្នាំឬអស់កប្បាវសាន។ នៅពេលមានក្ដីក្ដាំ គេតែងដោះស្រាយតាមរយៈតុលាការដែលគេហៅថា «រាជសភា»។[2]

---

[1] SIN Meng Srun, *Forestry in Cambodia: The Dilemma of Development and Preservation,* (Phnom Penh: Dr. SIN Meng Srun), 2014, pp. 2-3.

[2] កែវ លីណែត, ការគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជាសម័យបុរាណ, ក្នុង *ទស្សនាវដ្ដី វិទ្យាស្ថានភាសាជាតិ,* ឆ្នាំទី១៧ លេខ១០ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១/Journal of Institute of National Language, Royal Academy of Cambodia, Vol. 17, No. 10, January 2018, ទំ. ៨៧-១១២។

គួរកត់សម្គាល់ថា ក្នុងសិលាចារឹកតាកែវ, សតវត្សរ៍ទី៧ (K. 79), គេឃើញមានពាក្យ *ភ្លោញឈើវ្រៃយ៍* ដែលមានន័យថា «អ្នកគ្រប់គ្រងឈើព្រៃ, មេព្រៃ»។ មេព្រៃនេះបានរួមចំណែក

ព្រះរាជក្រឹត្យចុះថ្ងៃទី១៧ខែតុលាឆ្នាំ១៩០៥បានចែកព្រៃឈើជា២ប្រភេទ គឺ ព្រៃឈើបម្រុងនិងព្រៃឈើការពារ។ ក្នុងអំឡុងទសវត្សរ៍នៃឆ្នាំ១៩២០ តាមរយៈគោលនយោបាយការបញ្ចូលដីមួយចំនួនជាដីព្រៃឈើ រដ្ឋាភិបាលអាណាព្យាបាលបារាំងបាននាំយករុក្ខជាតិក្រៅស្រុកមកដាំនៅឥណ្ឌូចិន។ ពូជឈើទាំងនោះមាន ម៉ៃសាក់, ពូជប្រេងខ្យល់ និង ស្វាវ។[3]

ក្នុងអំពើកុសលរបស់មន្ត្រីម្នាក់ឈ្មោះ ម្រតាញ ឥគានបវិត្រ ដែលបានថ្វាយអំណោយដល់ព្រះអាទិទេពស្រីមួយអង្គ។

សិលាចារឹកភិមានអាកាស, ចារជាភាសាសំស្ក្រឹតនិងភាសាខ្មែរ, ដែលអ្នកស្រាវជ្រាវសន្និដ្ឋានថា ស្ថិតក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧, រៀបរាប់ពីមហាពោធិមួយដើម, ដែលគេអាចដាំនៅមុំប្រាសាទភិមានអាកាសនាពេលនោះ, ដែលគេគោរពបូជាក្រៃលែងរហូតដល់ប្រៀបធៀបដើមពោធិ៍នោះទៅនឹងព្រះអាទិទេពក្នុងព្រហ្មញ្ញសាសនានិងបន់ស្រន់កុំឱ្យមានរឿងអ្វីអាក្រក់កើតឡើងចំពោះដើមពោធិ៍នេះ ៖

> (១)ហៃវ្រះមហាវោធិ ហៃតមានិតេមិតគិវ្រះវ្រហ្ម(២)ហៃតមានិខ្លួនិតគិវ្រះឥគ្វរ ហៃតជាកុរុង៊ិតវ្វុក្សផ(៤)ង ហៃតភាគ្យវេគ ហៃតជាអាគ្រយ៏តជគតិផោ(៥)ង ហៃតឱយផលច្បថ្មា កំបិរន្ទះបញ៊្រកម្រតេង(៦)ផ្ទែករាំបំបតិកំបិ(៨)តំរ្យក្រោធបិវ្រចិនៅកំរេកិវ្នេកិយេង៊ិត(៩)អសរុនៅកំរេកិចំចេំតអសរុ នៅស្វប្នតអ(១០)សរុ នៅចិន្តាតអសរុ នៅមះតអសរុផោ(១១)តមានិតស្វគ៌្គតមនុម្យលោះចុរបំបតិនោះ។

សិលាចារឹកមួយទៀត គឺ សិលាចារឹកបន្ទាយស្រីចារនៅដើមសតវត្សរ៍ ទី១៤និយាយពីព្រឹត្តិការណ៍ក្នុងរាជ្យព្រះបាទ **ជ័យវរ្ម័នទី៧** ទាក់ទង នឹងមេនៃវណ្ណៈមួយឈ្មោះ **ត្រីបដាក** បានទិញព្រៃមួយកន្លែងសម្រាប់គោរពបូជាអាទិទេពនៃប្រាសាទបន្ទាយស្រី។ មានមនុស្សដែលជាអ្នករាជការចូលទៅកាប់ឈើនៅព្រៃនោះ។ មេវណ្ណៈត្រីបដាក បានប្ដឹងទៅប្រធានតុលាការដើម្បីសុំសិទ្ធិគ្រប់គ្រងព្រៃនោះវិញ។ នៅឆ្នាំ១៣០៣ ព្រះបាទស្រីស្រិន្ទវរ្ម័នមានព្រះរាជបញ្ជាឱ្យមន្ត្រីរាប់ដើមឈើក្នុងព្រៃនិងបែងចែកដើមឈើនោះទៅម្ចាស់ឈើ។

[3] Buchy Marlène. Histoire forestière de l'Indochine (1850-1954). Perspectives de recherche. In: Revue française d'histoire d'outre-mer, tome 80, n°299, 2e trimestre 1993. pp. 225.

ក្នុងសម័យអាណាព្យាបាល តាមរយៈក្រឹត្យច្បាប់១៩៣០ ព្រៃឈើនៅឥណ្ឌូចិនស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលបារាំង។[4]

នៅប្រទេសកម្ពុជា តាមរយៈការបង្កើតរុក្ខបាល ចាប់តាំងពីឆ្នាំ១៩៤០, ដោយយកតាមបច្ចេកទេសបារាំង, ការកាប់ឈើធ្វើឡើងដោយសនិទានីយ, ជាពិសេស ការយកចិត្តទុកដាក់របស់សម្ដេចព្រះ **នរោត្តម សីហនុ** ក្នុងការអភិរក្សព្រៃ

---

ទាក់ទងនឹងប្រវត្តិកៅស៊ូ អ្នកស្រាវជ្រាវទទួលស្គាល់ថា លោក Charles Goodyear ជាអ្នករកឃើញដោយចៃដន្យនូវវត្តមានរបស់កៅស៊ូដែលគេអាចច្នៃយកមកប្រើប្រាស់បាន។ លោកបានដាក់ជ័រកៅស៊ូនិងស្ពាន់ធ័រលើចង្ក្រានក្ដៅដែលជាហេតុបណ្ដាលឱ្យជ័រនោះខ្លោច តែ មានភាពយឺត។ កៅស៊ូនីយកម្ម (vulcanisation) ជាដំណើរការផលិតកៅស៊ូដោយបំប្លែងពីធាតុធម្មជាតិនៃកៅស៊ូមកជាធាតុធន់ជាប់យឺតអាចប្រើប្រាស់បាន។ ប្រសិនបើគេនិយាយពីបដិវត្តន៍ឧស្សាហកម្ម គេគួរនិយាយផងដែរពីការរួមចំណែកដ៏សំខាន់របស់កៅស៊ូ។

នៅចុងសតវត្សរ៍ទី១៩ ក្នុងសម័យអាណានិគម លោកឧត្តមសេនីយ៍បារាំង De Trentinian, អភិបាលរងនៃខេត្តស៊ូដង់បារាំង, បានទទួលបេសកកម្មទៅសិក្សារុក្ខជាតិដែលផលិតជ័រនៅអាងទន្លេនីហ្សេរ៍។ រុក្ខជាតិទាំងនោះជាវល្លិ Apocynées ក្នុងប្រភេទ *Landolphia* ។ ការសិក្សាបន្តចូលដល់ ប្រទេសសេណេហ្គាល់, ប្រទេសហ្គំប៊ី និង តំបន់កាសាម៉ង់ (Casamance)។ ជាលទ្ធផល ការសិក្សានេះកំណត់បានរុក្ខជាតិពីរប្រភេទ គឺ *Landolphia heudelotii* និង *L. owariensis* ។ នៅឆ្នាំ១៩០២ គេរកឃើញប្រភេទរុក្ខជាតិទីបីគឺ កៅស៊ូប្រភេទ *Funtumia elastic* ។ ទន្ទឹមគ្នានេះ នៅឯទ្វីបអាម៉េរិក គេបានរកឃើញប្រភេទកៅស៊ូចំនួនពីរគឺ Céara (*Manihot glaziowi*) និង (*Hevea brasiliensis*)។ ប្រភេទពូជទាំងពីរខាងដើមត្រូវបានគេយកមកដាំតាមប្រទេសស្ថិតក្រោមអាណានិគមបារាំង។ រាជការខ្មែរបានចែកកៅស៊ូសម្រាប់ដាំសម្រាប់ធ្វើពាណិជ្ជកម្មដំបូងនៅឆ្នាំ១៩១៣ដល់ប្រជាជន។ ចន្លោះពីឆ្នាំ១៩២៩-១៩៣៨ ផ្ទៃដីដាំកៅស៊ូនៅកូសាំងស៊ីននិងប្រទេសកម្ពុជាមាន ៥៣ ៧៣៤ហិចតា។ អំឡុងឆ្នាំ១៩២១ ឥណ្ឌូចិនមានដើមកៅស៊ូ៤លានដើមអាចចៀរជ័របាន។ Cf. Chevalier Auguste. La situation des plantations d'Hévéa dans le monde de 1939 à 1948. In: *Revue internationale de botanique appliquée et d'agriculture tropicale,* 28e année, bulletin n°309-310, Juillet-août 1948.pp. 297-302; Magaret Slocomb, *Colons* and *Coolies: The Development of Cambodia's Rubber Plantations,* (Bangko: White Lotus, 2007), p. 14.

[4] *Ibid.,* p. 223.

ឈើ ដែលនៅពេលនោះ គេបង្កើតរុក្ខទិវា។ ក្រោយមក ចន្លោះឆ្នាំ១៩៧០-៧៥ រដ្ឋាភិបាលបានចុះកិច្ចសន្យាការកាប់ឈើក្នុងព្រៃតាមបណ្ដោយព្រំដែនតំបន់ប៉ៃលិន។ ចាប់ពីឆ្នាំ១៩៧៩-៨៩ ព្រៃឈើស្ថិតក្រោមការគ្រប់គ្រងនៃគណៈកម្មការ, ដែលក្នុងនោះ, មានជនជាតិខ្មែរមួយរូបជាប្រធាន។ ប៉ុន្តែ រាល់ការសម្រេចត្រូវពិភាក្សាជាមួយអ្នកជំនាញការវៀតណាម។ គណៈកម្មការនេះទទួលបន្ទុកលើ ការយកផល ការការពារ និង ការដាំឈើឡើងវិញ។[5]

នៅឆ្នាំ១៩៦៥ គម្របព្រៃឈើនៃប្រទេសកម្ពុជាមានចំនួនជាង១៣លានហិចតា, ឆ្នាំ១៩៩៦-៧ មានចំនួនជាង១៣លាន២សែនហិចតា និង ឆ្នាំ២០១០ មានចំនួនច្រើនជាង១០លាន៣សែនហិចតា។[6]

អ្នកស្រាវជ្រាវបានចែកព្រៃឈើជា៣ប្រភេទ ៖ ព្រៃជ្រុះស្លឹក (deciduous forest), ព្រៃរបោះ (semi-dense forest) និង ព្រៃស្ដុក (dense forest)។ ព្រៃជ្រុះស្លឹកគម្របមានគុម្ពោតឈើដុះនៅក្រោមដើមឈើធំៗហើយស្ថានភាពដីមានលក្ខណៈស្ងួត។ ប្រភេទព្រៃនេះស្ថិតនៅខាងកើតទន្លេមេគង្គនិងខាងជើងបឹងទន្លេសាប។ ព្រៃល្បោះជាប្រភេទព្រៃឈើដែលខៀវជានិច្ចពី៣០ទៅ៧០ភាគរយ។ ព្រៃញឹកមានគម្របឈើជិតគ្នានិងមានគុម្ពោតឈើដុះនៅក្រោមញឹក។ ប្រភេទព្រៃនេះផ្ដល់ផលជាឈើហ៊ុប។ មានប្រភេទព្រៃសំខាន់ដទៃទៀត គឺព្រៃស្រល់និងព្រៃកោងកាង។ ព្រៃស្រល់ច្រើនមាននៅខ្ពង់រាបគិរីរម្យខេត្តកំពង់ស្ពឺ

---

[5] Martin Marie Alexandrine. L'état des forêts cambodgiennes. In: *Journal d'agriculture traditionnelle et de botanique appliquée,* 36e année, bulletin n°1,1994. p. 9.

[6] Mark Poffenberger, ed., *Cambodia's Constested Forest Domain: The Role of Community Forestry in the New Millennium,* ((Manila: Anteneo de Manila University Press, 2013), pp. 238-239.

និងស្រគំអូនខេត្តកំពង់ធំ។ ព្រៃកោងកាងច្រើនដុះតាមតំបន់ឆ្នេរសមុទ្រ។ ជាទូទៅ ប្រភេទឈើនានាបានដុះទៅតាមស្ថានភាពដីនិងប្រភេទព្រៃ។[7]

នៅប្រទេសកម្ពុជា គេបានចែកប្រភេទឈើជា៣ គឺ ប្រភេទឈើប្រណីត (បេង, គ្រញូង, នាងនួន, ធ្នង់), ប្រភេទឈើលេខ១ (គគីរ, ក្រកាស, ម៉ៃសាក់, ធ្នឹក, ពពេល, សូក្រំ, ត្រសេក, វរយង់) និង ប្រភេទឈើលេខ២ (ឈើទាលទឹក, ឈើទាលឆ្ការ, ឈើទាលបង្គួយ, ធ្នាធា, ប្រមាស់, ខ្លុង, ខ្វាវ, លម្បោរ, ផ្ដៀក, ស្រល់, ត្បែង, ត្រាច)។[8]

តាមរយៈសំណេរអក្សរសិល្ប៍ក៏ដូចក្នុងជីវភាពរស់នៅព្រៃឈើនិងរុក្ខជាតិមានទំនាក់ទំនងជិតស្និទ្ធនឹងជនជាតិខ្មែរ។[9] អនុផលព្រៃឈើរួមចំណែកសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។ អនុផលព្រៃឈើបានរំលេចឱ្យឃើញវប្បធម៌ខ្មែរដូចជារបស់ប្រើប្រាស់នានាដែលកើតពីផលិតផលសិប្បកម្មនិងការប្រើប្រាស់ថ្នាំព្យាបាលជំងឺតាមបែបវេជ្ជសាស្ត្របុរាណ[10]។ របាយ-

---

[7] SIN Meng Srun, *op.cit.,* pp. 24-31.

[8] *Ibid,* p. 61, cited in Pan Leang Cheav, *The Forest of the Republic of Cambodia.* 1972; Buchy Marlène, *op.cit.,* p. 231.

[9] ការពិពណ៌នាពីដើមឈើនិងធម្មជាតិនានាមានក្នុងសាស្ត្រាខ្មែរដូចជា **មហាវេស្សន្តរជាតក**, **ពុទ្ធិសែននាងកង្រី**, **ស័ង្ខសិល្បជ័យ**, **ទិព្វសង្វារ**, **មរណមាតា**, **ស្រទបចេក**, **ទុំទាវ** ជាដើម ។

[10] ស្ថានភាពនៃការវិវត្តវេជ្ជសាស្ត្រនាពេលបច្ចុប្បន្នបានជំរុញឱ្យគំនិតនៃការព្យាបាលបែបទំនើបនិងសម័យបុរាណបានជួបកាន់តែច្រើនឡើងៗ។ វេជ្ជសាស្ត្រទំនើបបានវិវត្តលើមូលដ្ឋានគំនិតនៃវេជ្ជសាស្ត្របុរាណហើយបន្តរៀងមកដល់ពេលបច្ចុប្បន្ន។ ការសិក្សាប្រព័ន្ធវេជ្ជសាស្ត្រទាំងពីរមានសារៈសំខាន់រួមចំណែកក្នុងការព្យាបាលមនុស្សជាតិ។ នៅប្រទេសកម្ពុជាសម័យបុរាណ ក្នុងរាជ្យព្រះបាទ **ជ័យវរ្ម័នទី៧**, តាមសិលាចារឹកសៃហ្វង, គេដឹងថា នៅសម័យនោះ ព្រះចៅអធិរាជអង្គនេះបានចាត់ឱ្យមានការកសាងអរោគ្យសាលា (មន្ទីរពេទ្យ) ចំនួន១០២។ មនុស្សមកពីគ្រប់ស្រទាប់វណ្ណៈអាចទៅព្យាបាលនៅមន្ទីរពេទ្យនោះបាន។ ជាការពិត ព្រៃឈើនិងរុក្ខជាតិទាំងឡាយគឺជាឃ្លាំងឱសថសម្រាប់ប្រើប្រាស់ព្យាបាល

ការណ៍មួយរបស់ធនាគារពិភពលោកបង្ហាញថា ប្រជាជនខ្មែរចំនួន៨៥ភាគរយពឹងផ្អែកជាមូលដ្ឋានលើកសិកម្មនិងព្រៃឈើ[11]។

ក្នុងអំឡុងឆ្នាំ១៩៦០និង៧០ លោកស្រី **ម៉ារី អាឡិចសង់ឌ្រីន ម៉ារទីន** បានសិក្សាព្រៃឈើនិងរុក្ខជាតិនៅប្រទេសកម្ពុជា ជាពិសេស នៅតំបន់ភ្នំក្រវាញនិងខេត្តរតនគិរី។ លោកស្រីផ្តោតជាពិសេសលើភូតគាម។ ក្នុងការសិក្សានោះលោកស្រីចែកព្រៃឈើខ្មែរជា៣១ប្រភេទ[12]។

---

រោគាមនុស្សសត្វទាំងឡាយ។ ការប្រើឱសថបុរាណឬថ្នាំធម្មជាតិនៅតែបន្តមានក្នុងជីវិតរបស់មនុស្សនៅអាស៊ី ជាពិសេស ជនជាតិខ្មែរ។

[11] Mark Poffenberger, *op.cit.,* p. 232.

[12] Marie Alexandrine Martin, Essai d´ethnophytogéographie khmère. In: *Journal d´agriculture tropicale et de botanique appliquée,* vol. 21, n° 7-9, Juillet-août-septembre 1974. pp. 220-228. ព្រៃឈើទាំង៣១ប្រភេទដែលលោកស្រីបង្ហាញនោះមាន ១. **ព្រៃធ្នូរ**, ប្រភេទព្រៃដែលដុះនៅដីរាប។ វានៅឆ្ងាយពីភូមិនិងមិនមានមនុស្សកាប់រាន។ ២. **ព្រៃជាំ**, ប្រភេទព្រៃជាំទឹក ច្រើនស្ថិតនៅក្បែរបឹងត្រពាំងរំលោងជាដើម ដែលជាប្រភេទដីភក់ ហើយ មិនមានការកាប់រានទេ។ ៣. **ព្រៃដងស្ទឹង**, ប្រភេទព្រៃនៅជិតដងស្ទឹង។ គេកាប់រានដីព្រៃនេះសម្រាប់ដាំដុះ។ ៤. **ព្រៃកោះ**, ប្រភេទព្រៃនៅដំបន់រាប ហើយ នៅឆ្ងាយពីភូមិ; វាជាប្រភេទព្រៃមិនមានមនុស្សកាប់រាប។ ៥. **ព្រៃគុម្ពោត**, ប្រភេទព្រៃទួល; គេកាប់រានដើម្បីដាំដុះខ្លះៗលើដីនេះមានបន្លែបង្ការជាដើម។ ៦. **ព្រៃកោងកាង**, ប្រភេទព្រៃដុះតាមមាត់សមុទ្រ។ ៧. **ព្រៃគម្រប**, ប្រភេទព្រៃជិតព្រៃធំឬព្រៃក្រាស់។ ៨. **ព្រៃគង់**, ព្រៃរក្សាទុករបស់រដ្ឋ។ ៩. **ព្រៃក្រញឹប**, ប្រភេទព្រៃស្ថិតនៅចន្លោះរវាងព្រៃកោងកាងនិងព្រៃស្នាច់។ ដើមក្រញឹបច្រើនដុះតាមមាត់សមុទ្រ។ ១០. **ព្រៃគុប**, ព្រៃប្រើប្រាស់ដោយរដ្ឋ។ ១១. **ព្រៃអ្នកតា**, ប្រភេទព្រៃពិសិដ្ឋ, តាមជំនឿ, អ្នកបំពានចូលទៅកាប់ឈើក្នុងព្រៃនោះអាចស្លាប់ដោយសារអ្នកតាកាច់។ ១២. **ព្រៃរា**, ប្រភេទព្រៃក្រិនស្ថិតនៅដីមិនរាបស្មើ មានដុះវល្លិនៅព្រៃខាងក្រោម។ ១៣. **ព្រៃរបោះ**, ប្រភេទព្រៃស្ថិតលើដីទំនាបមិនរាបស្មើ មានដុះឈើដើមតូចៗ ដុះឃ្លាតគ្នា មានវល្លិរពាក់ដុះដោយកន្លែង ១៤. **ព្រៃរលុង**, ប្រភេទព្រៃស្ថិតលើដីទំនាបមិនរាបស្មើ, ឈើដុះឆ្ងាយៗពីគ្នា, មានដុះគុម្ពព្រឹក្សច្រើន។ ១៥. **ព្រៃរនាម**, ប្រភេទព្រៃលើដីទំនាប លិចទឹកនៅរដូវវស្សា ជាដីភក់ស្អិត។ ១៦. **ព្រៃស្តុក**, ប្រភេទព្រៃក្រាស់ស្ថិតលើដីរាប់មិនស្មើ មិនមានគុម្ពព្រឹកទេ។ អ្នកស្រុកខ្លះហៅព្រៃស្តុកថា ព្រៃស្នាច់ស្មោង។ នៅតំបន់ភ្នំគូលែន ប្រជាជនមិនស្គាល់ព្រៃស្តុកទេ គេស្គាល់តែព្រៃកណ្តាញ់និងព្រៃស្បាត។ ១៧. **ព្រៃស្នាច់**, ប្រភេទព្រៃ ដុះស្ថិតលើដីរាបក្បែរមាត់សមុទ្រ ដុះខាងក្រោយ

នៅឆ្នាំ២០០០ លោកស្រី **ឌី ផុន ប៉ូលីន** បានចេញផ្សាយសៀវភៅរុក្ខជាតិដែលមានចំនួន១២៥៤ពូជរុក្ខជាតិ។ តាមការសិក្សារបស់លោកស្រី ពូជរុក្ខជាតិទាំងនេះចែកជាពីរសាខា គឺ អប្បជិច្ឆន្នជាតិ(ប្រភេទបន្តពូជដោយផ្កា) និង បជិច្ឆន្នជាតិ(ប្រភេទបន្តពូជដោយស្ព័រ)។ ក្នុងពិភពលោកនេះ អប្បជិច្ឆន្នជាតិមានប្រមាណ៣៥០ ០០០ប្រភេទ ដែលនៅប្រទេសកម្ពុជាមានប្រហែល៤០០០ប្រភេទ។ បណ្តា១២៥៤ពូជរុក្ខជាតិ ២៩ប្រភេទដុះនៅតែប្រទេសកម្ពុជា, ១២០ ប្រភេទដុះនៅប្រទេស កម្ពុជា, វៀតណាម និង ឡាវ, ១២០ប្រភេទដុះនៅប្រទេស កម្ពុជា, វៀតណាម, ឡាវ, ថៃ និង ភូមា។ ពូជរុក្ខជាតិដទៃទៀតដុះរាយប៉ាយនៅអាស៊ីអាគ្នេយ៍, អាស៊ី, តំបន់ត្រូពិកអឺរ៉ាស៊ី, ទ្វីបអាម៉េរិក ឬ តំបន់ត្រូពិកក្នុងពិភព

---

ព្រៃក្រញឹប។ ១៨. **ព្រៃស្នុកស្នាញ**, ប្រភេទព្រៃមិនរាបស្មើមានឈើដុះស៊ុបទ្រុប ច្រើនមានដុះឫស្សីតាមជើងទេរ។ ១៩. **ព្រៃស្រោង**, ប្រភេទព្រៃស្ថិតលើដីរាបមិនស្មើ មិនសូវមានដុះវល្លិរពាក់ទេ។ ២០. **ព្រៃធំ**, ប្រភេទព្រៃមានទំហំធំជាព្រៃហ័តហោងឬស្ងាត់ មានឈើទំហំធំមានមុខជាង១ម៉ែត្រឡើង។ ២១. **ព្រៃទទឹង**, ប្រភេទព្រៃស្ថិតនៅទទឹងភូមិឬភ្នំជាដើម។ ២២. **ព្រៃបេងភូមិ**, ប្រភេទព្រៃដុះឡើងវិញ ដុះព័ទ្ធជុំវិញភូមិ។ ២៣. **ព្រៃបុះ**, ប្រភេទព្រៃដុះឡើងវិញ។ ព្រៃដែលគេគាស់រានហើយទុកចោលមួយឆ្នាំពីរក្លាយជាព្រៃបុះ។ ឆ្នាំដំបូងគេហៅចម្ការបុះ។ ២៤. **ព្រៃចាស់**, ប្រភេទគាស់រាន ប៉ុន្តែ គេទុកចោលយូរ ហើយ មិនឃើញមានដីដែលឈើដុះថ្មី។ ២៥. **ព្រៃកាប់បាន**, ប្រភេទព្រៃដែលរដ្ឋអនុញ្ញាតឱ្យកាប់បាន ២៦, **ព្រៃភ្នំ**, ប្រភេទព្រៃស្ថិតលើទីតាំងមានកូនភ្នំជាដើម។ ២៧. **ព្រៃរាប**, ប្រភេទព្រៃស្ថិតលើទីតាំងទាប។ ២៨. **ព្រៃតម**, ២៩. **ព្រៃតូច**, ព្រៃញឹក, ព្រៃស្រឡះ។, ៣០. **ព្រៃញឹក**, ៣១. **ព្រៃស្រឡះ**, ៣២. **វាលស្មៅ**។

ប្រសិនបើយើងសង្កេត លេខ៣០និងលេខ៣១បញ្ជាក់ពីភាពខុសគ្នារវាងបរិមាណឈើ ចំណែកលេខ៣២បង្ហាញពីលំហមួយដែលផ្ទុយពីលំហដែលមានឈើដុះ។ នៅពេលបច្ចុប្បន្ន តាមការវិវត្តសង្គម គេពិបាកនឹងរក្សានិយមន័យដើមរបស់ប្រភេទព្រៃឈើទាំងនេះ។ ការកំណត់ប្រភេទព្រៃឈើជារឿងលំបាក។ តាមការសិក្សារបស់ Ian G. Baird ជនជាតិកាណាដាដែលរស់នៅខេត្តរតនគិរីនិងខេត្តស្ទឹងត្រែងមានពាក្យសម្គាល់ព្រៃ១០៨ប្រភេទគោល ហើយ តាមលោក គេអាចមានពាក្យហៅលើស១០៨នេះទៅទៀត ដោយវាអាស្រ័យថា តើគេយកអ្វីជាគោលក្នុងការកំណត់ ឧទាហរណ៍ តើគេហៅសណ្ឋានដីឬយ៉ាងណាជាដើម។ Cf. Mark Poffenberger, *op.cit.,* p. 169.

លោក។ ក្នុងវចនានុក្រមខ្មែរ មានឈ្មោះរុក្ខជាតិប្រហែល៤០០។[13] យើងបានស្រង់មេពាក្យជាឈ្មោះរុក្ខជាតិក្នុងវចនានុក្រមខ្មែរ។ យើងរកឃើញថា មេពាក្យមានចំនួនជាង៥០០ពាក្យ។

ជាការពិត នៅមានប្រភេទឈើជាច្រើននៅប្រទេសកម្ពុជាមិនទាន់មានគេសិក្សានៅឡើយ។ ពូជឈើនីមួយៗមានប្រភេទច្រើនណាស់ ឧទាហរណ៍ ពូជ Psychotria មានជាង១៨០០ប្រភេទ[14] ប៉ុន្តែ នៅប្រទេសកម្ពុជាមានការសិក្សាកន្លងមកតែប៉ុន្មានប្រភេទប៉ុណ្ណោះ ដូចជា ចំប៉ីព្រៃ (Psychotria adenophylla Wall.) និង អន្លុងស (Psychotria revesii Wall. ex. Roxb.) ជាដើម។ ជាការពិត ពូជរុក្ខជាតិប្រភេទមានវត្តមានទៅតាមអាកាសធាតុនិងទឹកដី មានន័យថា ប្រភេទរុក្ខជាតិខ្លះដុះនៅតែតំបន់ខ្លះដែលស្របតាមលក្ខខណ្ឌដែលរុក្ខជាតិនោះអាចរស់បាន។

## ២. ពាក្យរុក្ខជាតិមួយចំនួនរបស់លោកស្រី ម៉ាតាំង ម៉ារី អាឡិចសង់ឌ្រីន[15]

លោកស្រី **ម៉ាតាំង ម៉ារី អាឡិចសង់ឌ្រីន** បានសិក្សារុក្ខជាតិខ្មែរតាមបែបជាតិពន្ធុភូតគាមវិទ្យា។ លោកស្រីបានលើករុក្ខជាតិចំនួន១៦០មកធ្វើចំណាត់ថ្នាក់តាមបែបវិទ្យាសាស្ត្រ។ យើងស្រង់មកខាងក្រោមតែរុក្ខជាតិណាដែលមិនមានក្នុងវចនានុក្រមរបស់លោកស្រីបណ្ឌិត **ឌី ផុន ប៉ូលីន**។

---

[13] Dy Phon Pauline, *រុក្ខជាតិប្រើក្នុងប្រទេសកម្ពុជា/Plants used in Cambodia*, ភ្នំពេញ, ២០០០, ទំ. v-xvi.

[14] http://www.wikiwand.com/en/Psychotria

[15] Martin Marie Alexandrine. Notes sur quelques végétaux utilisé au Cambodge. In : *Journal d’agriculture tropicale et de botanique appliquée,* vol. 16, n° 2-5, Février-mars-avril-mai 1969. pp. 112-157.

1. (វល្លិ)កណ្ដឹង ( ? *Ipomoea aculeate* Bl. var. *mollissima* (Zoll.) *Hallier* f. ex *Ooststr.*)
2. កណ្ដៀរ (*Peristrophe Roxburghiana* Schult.) Bremek.
3. កន្ទួលភ្នំ (*Oxalis corniculata* L.)
4. កន្ទុំរុយ, ស្មៅម្អមកាំ, ជី ហ្វេយ ថា (*Lippia nodiflora* (L.) Michx), គ្រេច (*Psychotria* sp.)
5. ខាន (*Gleichenia laevigata* (Willd.) Hook.)
6. ចារក្រអូប (*Gardenia* sp.)
7. ចុងអង្គរ (*Raphistemma Hooperianum* (Bl.) Dec.)
8. ចំដែងមាស (*Psychotria* sp.)
9. ឆ្អឹងមាន់ (*Synedrella nodiflora* (L.) Gaertn.)
10. (វល្លិ)ជុំយញី (*Streptocaulon juventas* (Lour.) Merr.)
11. ដងដាវ (*Ardisia* sp.)
12. ដំឡូងបារាំង (*Solanum tuberosum* L.)
13. ត្រចៀកក្រាញ់ស្រែ (*Coldenia procumbens* L.)
14. ត្រមេង (*Garcinia* sp.)
15. ត្រមេងទឹក (*Ancinstrocladus* sp.)
16. ដោះក្របី (*Artabotrys* sp.)
17. ទ្រយឹងស (*Symplocos* sp.)
18. បង្គោលស្វា (*Aglaia* sp.)
19. បាយក្ដាំងភ្នំ, ខ្ញូភ្នំ (*Clerodendrum* sp.)
20. ប្រមាត់ដីព្រៃ (*Ammannia baccifera* L.)
21. ផ្ទីខ្មោច (*Gynura* sp.)
22. ផ្លែន (*Anadendron* sp.)

23. មមាំងស្បាត ( *Argyreia osyrensis* ( Roth ) Choisy
24. ពយ ( *Artemisia vulgaris* L. )
25. ពពាយព្រៃ ( *Thunbergia* aff. *grandiflora* Roxb. )
26. ពុកឆ្មាភ្នំ ( *Urophyllum longifolium* ( Wright ) Hook. f. var. *annamense* Pierre ex Pitard )
27. ពុកមាត់ឆ្មា ( *Ixora Finlaysoniana* Wall. ex. G. Don )
28. ព្រីងគ្រាប់ល្អិត, តាន ( *Hedyotis* aff. *congesta* R. Br. )
29. ព្រូក ( *Garcinia* aff. *ferrea* Pierre )
30. ប្រក្រុងឈ្មោល ( *Pericampylus glaucus* ( Lam. ) Merr. )
31. ភ្នែកត្រី ( *Ixora nigricans* R. Br. ex Wight et Arn. )
32. ភ្លូងដា ( *Symplocos elephantis* Guillaum. )
33. មមា ( *Vitex trifolia* L. )
34. ម្ជូរព្រៃព្រៃ ( *Abelmochus moschatus* Medi. )
35. ម្រះព្រៅបារាំង ( *Ocimum gratissimum* L. )
36. ម្អមព្រៃ ( *Angelomia biflora* Benth. )
37. យុថ្កាភ្នំ ( *Randia* asp. )
38. រងាងអាចម៍មាញ់ ( *Cratoxylon poplyanthum* Korth. )
39. រលោស្មុង ( *Clausena* sp. )
40. សខាលព្រៃ ( *Clerodendrum serratum* ( L. ) Moon

41. ស្គន់ទឹក ( *Ageratum conyzoides* L. )
42. ស្លង់ ( *Maesa membranacea* A. DC. )
43. ស្លាត ( *Callicarpa arborea* Roxb. )
44. ស្អុង ( *Lasianthus tamirensis Pierre* ex Pitard )
45. ប្រមាត់ដីភ្នំ ( *Limnophila Geoffrayi* Bonati )
46. (វល្លិ)អញ្ចាន់ព្រៃ ( *Thunbergia fragrans* Roxb. )
47. ឪឡោកព្រៃ ( *Crescentia* aff. *alata* H.B.K. )
48. ឪឡឹកព្រៃ ( *Crescentia cujete* L. )
49. សំបុកស្រមោច ( *Hymenopyramis cana* Craib )

## ៣. ពាក្យរុក្ខជាតិមួយចំនួនរបស់លោក ហ្សូល វីដាល់

លោក **ហ្សូល វីដាល់**[16] បានសិក្សារុក្ខជាតិមួយចំនួននៅប្រទេសកម្ពុជាតាមជាតិពន្ធុវិទ្យា។ បណ្តារុក្ខជាតិទាំង១៦០ យើងជ្រើសយកតែរុក្ខជាតិដែលគ្មានក្នុងសៀវភៅលោកស្រី **ឌី ផុន ប៉ូលីន**។

1. វល្លិត្រី ( *Ichnocarpus fructescens* Br. ou *I. oxypetalus* Pit. )

---

[16] Vidal Jules. Notes ethnobatiques abrégées sur quelque plantes du Cambodge. In: *Journal d'agriculture tropicale et de botanique appliquée,* vol. 14. n° 1-3, Janvier-février-mars 1967. pp. 21-66. ពីរឆ្នាំបន្ទាប់ លោក **វីដាល់** បានសហការសិក្សារួមគ្នានឹងលោក **ហ្គាប្រីយែល ម៉ាទែល** និង លោកស្រីបណ្ឌិត **សាវរស ឡឺវីត** ដោយបន្ថែមទិន្នន័យមួយចំនួនលើឈ្មោះរុក្ខជាតិទាំង១៦ និង បន្ថែមឯកសារក្នុងគន្ថនិទ្ទេស (Vidal J.-E., Martel Gabrielle, Lewitz Saveros. XII. Notes ethnobotaniques sur queles plantes en usage au Cambodge. In: *BFEO.* Tome 55, 1969. pp. 171-232. )។

2. ផ្កាឡូត ( *Ipomea hederacea* Jacq. )

3. ផ្លាក់ខ្មៅ ( *Solanum nigrum* L. )

4. ជីរផ្អាប ( *Houttuynia cordata* Thunb. )

5. ដំឡូងសាយស្នោត *Dioscorea pentaphylla* L. )

6. ផ្ទាល់ ( *Amorphophallus* sp. )

7. អាចម៍កុក ( *Eriocaulon nautiliforme* Lec. )

ឈ្មោះរុក្ខជាតិមួយចំនួនក្នុងសទ្ទានុក្រមនេះយើងបានស្រង់ពីសៀវភៅមួយចំនួនដែលសរសេរទាក់ទងនឹងរុក្ខជាតិ ជាពិសេស ឯកសាររបស់លោកស្រីបណ្ឌិត **ឌី ផុន ប៉ូលីន** និង របស់មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ។ រុក្ខជាតិខ្លះមានឈ្មោះហៅច្រើន ដែលទាមទារឱ្យយើងពិនិត្យតាមឈ្មោះ ជាវិទ្យាសាស្ត្រជាភាសាឡាតាំងដើម្បីបញ្ជាក់ឱ្យប្រាកដ៕

# ក

**កកុសន្ធោ** /ក-កុ-សន់-ធោ/ (បា.) *ន.* ព្រះនាមព្រះសម្មាសម្ពុទ្ធទីមួយក្នុងចំណោមព្រះសម្មាសម្ពុទ្ធប្រាំព្រះអង្គដែលត្រាស់ដឹងក្នុងភទ្ទកប្បនេះ។

**កកោះព្រៃក** /ក-កោះ-ព្រៃក/ *ន.* (ម.ព. *កកោះស្បែក* ។)

**កកោះស្បែក** /ក-កោះ-ស្បែក/ *ន.* ឈ្មោះឈើមួយប្រភេទដុះក្នុងព្រៃល្បោះក្បែរមាត់សមុទ្រ។ ផ្លែកកោះស្បែកគ្មានបន្លាដូចផ្លែកកោះធម្មតាទេ, គេអាចបរិភោគវាបានដូចគ្នា។ សាច់ឈើមិនល្អឡើយ គេប្រើសម្រាប់ធ្វើអុសដុត។ អ្នកខ្លះហៅឈើនេះថា *កកោះព្រៃក* ។

**កក្រើក** /ក-ក្រើក/ *ន.* ឈ្មោះចុល្លព្រឹក្សវារមួយប្រភេទដែលដុះក្នុងទីវាលកន្លែងដែលមានពន្លឺថ្ងៃ។ គេតែងយកផ្លែធ្វើជ្រក់ឬធ្វើទឹកខ្មេះ, ឫសធ្វើថ្នាំរំងាប់រោគស្វាយប្រមេះ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ទំពាំងបាយជូរព្រៃ* ។

**កង់បី** /កង់-បី/ *ន.* ទោចក្រយានយន្តមានសណ្តោងរ៉ឺម៉កពីក្រោយ។ អ្នកខ្លះហៅ *រ៉ឺម៉កកង់បី* ក៏មាន។

**កង្ហារ** /កង់-ហា/ *ន.* ឈ្មោះចុល្លព្រឹក្សមួយពួកដុះក្នុងព្រៃធំឬព្រៃស្រោង។ វាជាឈើរឹង, គេអាចប្រើធ្វើគ្រឿងផ្ទះរាយរងបាន។

**កញ្ចុះដង្កូវ** /កាញ់-ចុះ-ដង់-កូវ/ *ន.* ឈ្មោះឈើតូចមួយប្រភេទដុះក្នុងព្រៃក្រាស់។ ដើមវាគេច្រើនប្រើសម្រាប់ប្រើធ្វើជាបង្គោលរបង, ស្លឹកស្មោរ គេអាចប្រើធ្វើជាថ្នាំបំពោកលើជើងដៃដែលគ្រេច។

**កញ្ជ្រោល** /កាញ់-ជ្រោល/ *ន.* ឈ្មោះឈើតូចមួយប្រភេទដុះក្នុងព្រៃស្រោង, ដើមវាគេប្រើសម្រាប់ធ្វើបង្គោលរបង, មែកតូចៗ គេធ្វើអុសដុត។

**កន្ទុយកំប្រុក ១** /កន់-ទុយ-កំ-ប្រុក/ *ន.* ឈ្មោះគុម្ពព្រឹក្សមានរោមច្រើនមានរាងជាផ្កាយលើមែកជាងស្លឹក។ រុក្ខជាតិនេះច្រើនដុះក្នុងព្រៃស្រោង។ សំបកវា គេត្បាញធ្វើ ការុង បាវស្រូវ និង ខ្សែវេញ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ព្រាលជ្រូក* ។

កន្ទុយកំប្រុក ២ *ន.* ឈ្មោះស្មៅរឹងមួយប្រភេទ វារលើដី បែកមែកជាច្រើន, ដុះក្នុងព្រៃស្រោង។ គេប្រើដើមវាធ្វើជាថ្នាំ រម្ងាប់រោគរាក និង ដកដង្ហើមតឹង។

កន្ទុយក្ងោក /កន់-ទុយ-ក្ងោក/ *ន.* គុម្ពព្រឹក្សមួយប្រភេទដុះក្នុងព្រៃស្រោងឬព្រៃមាត់ព្រៃធំឬក្នុងព្រៃឫស្សី។ គេនិយមដាំដើមឈើនេះជាលម្អនិងជារុក្ខជាតិឱសថ។

កន្ទុយត្រក្លួត /កន់-ទុយ-ត្រ-ក្លួត/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្រោមឈើធំៗក្នុងព្រៃធំ។ គេស្ងោរផ្កាវាផឹកព្យាបាលជំងឺផ្លូវដង្ហើម, ឫសប្រើជាថ្នាំរម្ងាស់រោគហើមសម្រាប់ស្ត្រីកូនខ្ចី។

កន្ទុយល្វេ /កន់-ទុយ-ល្វេ/ *ន.* ឈ្មោះឈើតូចមួយប្រភេទជាចុល្លព្រឹក្សដុះក្នុងព្រៃរបោះជិតមាត់សមុទ្រ។ សំបកមានក្លិនក្រអូប, គេច្រើនប្រើធ្វើធូបនិងធ្វើថ្នាំរំងាប់រោគ។ ឈើនេះមានឈ្មោះហៅដទៃទៀតជា *បេកទុំផ្កាស* ឬ *ថ្លាង* ឬ *ទ្វាង* ។

កន្ទុយរ៉េ /កន់-ទុយ-រ៉េ/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់និងព្រៃល្បោះ។ សំបកមានក្លិនក្រអូប គេប្រើធ្វើធូប។

កន្ទួតប្រោងដើម /កន់-ទួត-ប្រោង-ដើម/ *ន.* ឈ្មោះព្រឹក្សធំមួយប្រភេទដុះក្នុងព្រៃជ្រៅ, ផ្លែមានរសជូរបន្តិច អាចបរិភោគបាន, ស្លឹកខ្ចីសម្រាប់ឱ្យសត្វពាហនៈស៊ី។ ឈើនេះសាច់មានពណ៌ប្រផេះក្រមៅឬលឿងភាវ, គេប្រើធ្វើគ្រឿងដំបូលផ្ទះ។ គេអាចប្រើធ្វើតួស្គរផងដែរ។

កន្ទោងរោយ /កន់-ទោង-រោយ/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃត្រជាក់ឬព្រៃស្រល់លើភ្នំ។ គេប្រើស្លឹកនិងសំបកវាសម្រាប់ធ្វើឱ្យត្រីឱ្យស្លឹកឬស្រវឹងមុននេសាទ ឬ សម្រាប់ដេញឈ្លើង។

កន្ទ្រាំងជារី /កន់-ទ្រាំង-ជា-រី/ *ន.* ឈ្មោះវល្លិមួយប្រភេទដុះក្នុងព្រៃស្រោងលើវាលស្មៅ ឬ លើដីសើមៗ។ ក្នុងក្បួនឱសថបុរាណ គេស្ងោរដើម ព្យាបាលជំងឺច្រើនមុខ ដូច

ជា គ្រុន មូល របេង និង រោគហឺត ជាដើម។ មើមជាថ្នាំឈឺក្បាលនិងព្យាបាលរោគបេះដូង។

**កន្ទ្រោករលោយខ្ចូរ** /កន់-ទ្រោក-រ-លាយ-ខ្ចូ/ *ន.* គុម្ពព្រឹក្សមួយប្រភេទដុះលើដីវាល និងក្នុងព្រៃគុម្ពោត។ ស្លឹកជាថ្នាំបុរាណព្យាបាលឱ្យដូវស្ត្រីបានទៀងទាត់។ គេប្រើស្លឹកដដែលនេះសម្រាប់ការពារកុំឱ្យជំបៅក្លាយនិងឃាត់សត្វល្អិតកុំឱ្យខាំ។

**កន្លង់រេស** /កន់-ឡង់-រេស/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់។ ផ្លែអាចបរិភោគបាន។

**កន្លើតចាស់** /កន់-ឡើត-ចាស់/ *ន.* គុម្ពព្រឹក្សមួយប្រភេទជាវល្លិឡើងដើមឈើដុះក្នុងព្រៃគម្ពោតនិងព្រៃល្បោះមែកវែងៗធ្លាក់ចុះក្រោម, ផ្លែប៉ុនម្រាមដៃមានគន្លាក់ ពេលទុំគេតែងបេះមកបរិភោគភ្លាមៗ ពីព្រោះ បើបើកទុកយូរ ផ្លែខ្យល់ចូលអាចធ្វើឱ្យចុកពោះ។ គេស្ងោរមែកផឹកដើម្បីព្យាបាលជំងឺទាស់ ក្រោយពេលសម្រាលកូន។

**កន្សែង** /កន់-សែង/ *ន.* ព្រឹក្សមួយប្រភេទដុះក្នុងព្រៃធំ។ ស្លឹកគេប្រើជំនួសសម្រាប់អប់ស្រាបៀរ។ តាមវេជ្ជសាស្ត្របុរាណខ្មែរ សំបកអាចឆុងផឹករំងាប់រោគអុតស្វាយ។

**កប្បាសពួង** /កាប់-បាស-ពួង/ *ន.* កប្បាសមួយប្រភេទមានដើមកំណើតក្នុងទ្វីបអាម៉េរិក។ អ្នកខ្លះដាំក្នុងភូមិជាលម្អ។ ជនជាតិភាគតិចពួងយកសរសៃផ្លែដើមនេះសម្រាប់ត្បាញសម្លៀកបំពាក់។

**កប្បាសហាប់** /កាប់-បាស-ហាប់/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានដើមកំណើតនៅប្រទេសឥណ្ឌា។ គេច្រើនដាំកប្បាសហាប់ដើម្បីយកសរសៃត្បាញសំពត់ឬក្រមា។

**កបិលមហាព្រហ្ម** /កាក់-បិល-មៈ-ហា-ព្រំ/ *ន.* នាមទេវតាជាន់ខ្ពស់មួយអង្គមាននិយាយក្នុងសង្ក្រាន្តសូត្រ។ ឧទាហរណ៍ *កាលកបិលមហាព្រហ្មជ្រាបពត៌មាននោះ ក៏ចុះមកសួរបញ្ហានឹងធម្មបាលកុមារ៣ខ សន្យាថា បើដោះប្រស្នាបាន នឹងកាត់ក្បាលបូជាធម្មបាលកុមារ បើដោះមិនបាន នឹងកាត់ក្បាលធម្មបាលកុមារវិញ។*

# ក

កម្រើកគុម្ព /កំ-រ៉ើក-គុំ / *ន.* គុម្ពព្រឹក្សដុះក្រោមឈើធំៗ ក្នុងព្រៃក្រាស់ឬព្រៃល្បោះ។ ដើមដុះត្រង់ពណ៌ក្រហមៗមានលក្ខណៈជាទ្រនុង, ទងផ្ការាងស្លួច, ផ្កាពណ៌សរីកបែកជាប្រាំសន្លឹក។ តាមវេជ្ជសាស្រ្តបុរាណ ទឹកស្ងោរឫសប្រើជាថ្នាំគ្រុន, អ្នកខ្លះជឿថា ជាថ្នាំប៉ូវសម្រាប់បុរសផង។ គេអាចត្រាំឫសក្នុងស្រា ដើម្បីធ្វើថ្នាំរីតដៃជើងហើម។ អ្នកស្រុកខ្លះហៅរុក្ខជាតិនេះថា *ព្រៃថ្នាំង* ។ គួរកុំច្រឡំរវាងកម្រើកគុម្ព-ព្រៃថ្នាំងនេះនិងកម្រើកគុម្ព-ខ្លុនខាប។

កម្រើកគុម្ព-ខ្លុនខាប /កំ-រ៉ើក-គុម-ខ្លុន-ខាប/ *ន.* ឈ្មោះគុម្ពព្រឹក្សដុះត្រង់ឡើងលើក្នុងព្រៃរបោះ។ ដើមមូលមានសាច់, ផ្កាច្រើនមានពណ៌សរីកជាសន្លឹកតែមួយ។ មើមវា គេប្រើសម្រាប់ស្ងោរផឹកជាថ្នាំលើកកម្លាំង។

កស្សបៈ /កាស់-សៈ-ប៉ាក់/ (បា.) *ន.* ព្រះនាមព្រះសម្មាសម្ពុទ្ធទីបីក្នុងចំណោមព្រះសម្មាសម្ពុទ្ធប្រាំព្រះអង្គដែលត្រាស់ដឹងក្នុងភទ្ទកប្បនេះ។

កស្សបោ /កាស់-សៈ-ប៉ោ/ (បា.) *ន.* (ម.ព. *កស្សបៈ* ។)

កាណា /កា-ណា/ *ន.* ឈើដុះក្នុងព្រៃក្រាស់ ផ្លែតូចរាងស្លួច, សំបកខ្មៅ, សាច់ក្រហមពេលវាទុំ។ គេអាចបរិភោគ ស្រស់ ឬ ក្រៀម ឬ ជ្រក់។

កាណឹ /កា-ណឹ/ *ន.* ឈ្មោះឧបករណ៍ភ្លេងមួយប្រភេទជាទ្រខ្សែមួយរបស់ជនជាតិភាគតិចទំពួន, គ្រឹង ហៅថា *កាណឹ* ។ គេកូតនឹងធាកធ្វើពីឫស្សី, កណ្តាលតួមានឃ្លោកទុំជាប្រអប់សូរ។ ដងធ្វើពីឈើ, លើដង គេចិតឱ្យចេញរាងរៅនិងខ្នង់សម្រាប់ចុច។ ព្រលួតធ្វើពីឈើហើយគេចងខ្សែឱ្យចុះមកខាងក្រោមត្រង់ចំណុចមូលអ៊ែន។ កាណឹមានសូរប្រហែលទ្រខ្សែបីដែរ។ គេលេងវា នៅពេលបញ្ចាន់អារក្សរួមគ្នានឹងប្រិក។

ការប្រគំខ្មោច /កា-ប្រ-គុំ-ខ្មោច/ *ន.* ពិធីស្រដៀងនឹងការលៀងអារក្សដែរ តែ ស៊ីពេលខ្លីជាងលៀងអារក្ស។ ក្នុងពិធីនេះ ខ្មោចដែលចូលនីមួយៗច្រើនស្តីបន្ទោសគ្រួសារអ្នកជំងឺថា មិនគិតគូរគេ ចង់រលងគេ ហើយ រកពេទ្យផ្សេងមកព្យាបាល។

# ក

**កិមិរា** /កិ-មិ-រ៉ា/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីមួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម, រឿងនេះមាននិទានក្នុងសង្ក្រាន សូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃសុក្រ ឆ្នាំនោះជាឆ្នាំដែលព្រះនាង កិមិរា គ្រប់គ្រង។ ព្រះនាង កិមិរា សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្បរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ន ឆ្វេងពិណ ពាហនៈក្របី។

**កិរិណី** /កិ-រិ-ណី/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីមួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម, រឿងនេះមាននិទានក្នុងសង្ក្រាន្តសូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃព្រហស្បតិ៍ ឆ្នាំនោះជាឆ្នាំដែលព្រះនាង កិរិណី គ្រប់គ្រង។ ព្រះនាង កិរិណី សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែកល្ង អាវុធស្តាំកង្វេរ ឆ្វេងកាំភ្លើង ពាហនៈដំរី។

**កុកម៉ាយ** /កុក-ម៉ាយ/ *ន.* តិណជាតិរីងមួយប្រភេទដុះទាបនឹងដី ស្ទើរគ្មានដើម មានស្លឹកធំ, ដុះក្នុងព្រៃស្រោងជិតមាត់ទឹក។ ផ្កាដុះផ្ដុំគ្នាជាសំណុំរាងដូចកន្ទុយឆ្មា។ គេនិយមដាំកុកម៉ាយក្នុងសួនដើម្បីលម្អ។

**កុមារពេជ្រ ១** /កុ-ម៉ា-ពិច/ *ន.* ឈ្មោះវល្លិធ្នារមួយប្រភេទ មើមធំរាងមូលពណ៌ត្នោត អាចមានទម្ងន់ដល់២០គីឡូក្រាម, ស្លឹកខៀវធំៗ, ផ្កាពណ៌បៃតងលាយសតូចៗ, ផ្លែមូលមានទឹកច្រើន។ តាមវេជ្ជសាស្ត្របុរាណ មើមវាគេច្រើនប្រើជាថ្នាំលើកកម្លាំង, ព្យាបាលជំងឺកន្ត្រាក់ញាក់សាច់ដុំ និង បង្កើនគ្រាប់ឈាមក្រហម។

**កុមារពេជ្រ ២** /កុ-ម៉ា-ពិច/ *ន.* ឈ្មោះគុម្ពព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់ឬព្រៃស្រោង, ផ្លែខ្ចីមានរសផ្អែម។ ឈើសម្រាប់ធ្វើខ្សៀដក់បារី ដែលផ្សែងបារីអាចព្យាបាលជំងឺរន្ធច្រមុះ, ទឹកដមនៃឫសអាចធ្វើថ្នាំបញ្ចុះ។ ឈើនេះមានប្រយោជន៍ច្រើនយ៉ាងទៀត។ រុក្ខជាតិនេះ គេហៅក្លាយជា *កុមារព្រេច* ក៏មាន។ វាមានឈ្មោះដទៃទៀតជា *ល្វាដី, ក្របីឈ្មោល* ។

# ក

**កុលាបភ្នំ** /កុ-ឡាប-ភ្នំ/ *ន.* ឈ្មោះគុម្ពព្រឹក្សតូចមួយប្រភេទ ដុះក្នុងព្រៃស្រោង។ ផ្ការីកជារង្វេល មិនមានស្រទាប់ច្រើន, ដើមតូចមិនមានបន្លាដូចកុលាបធម្មតានោះទេ។ រុក្ខជាតិនេះដុះច្រើនលើភ្នំគិរីរម្យ។ សរសៃសំបក គេប្រើធ្វើជាចំណង។ ឫស គេប្រើធ្វើថ្នាំព្យាបាលគ្រេចដៃជើង។ អ្នកខ្លះហៅផ្កានេះថា *វង្វាយភ្លើង*។

**កូនចាប** /កូន-ចាប/*ន.* (ព.មេ.) អ្នកជំងឺជាកូនក្មេង។

**កូនដៃបណ្ឌិត** /កូន-ដៃ-បន់-ឌឹត/ *ន.* គុម្ពព្រឹក្សតូចដុះក្នុងព្រៃជ្រុះស្លឹករដូវប្រាំងឬលើភ្លឺ។ ដើមតូចពណ៌ក្រហម, ស្លឹកមានពីរដុះចេញពីទងតែមួយ ស្លឹកតូចមួយបន្ទាប់មកស្លឹកធំ, ទម្រង់ផ្លែមានសណ្ឋានផ្លែក្ដម្ពទេសជាដើម តែ ដុះត្រង់ឡើងលើ, ផ្កាមានពណ៌ស្វាយ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើឫសជាថ្នាំគ្រុនឬលាបកន្លែងគ្រេចឬមួយស្ងោរឱ្យមនុស្សស្គមផឹកឱ្យធាត់។ អ្នកខ្លះហៅផ្កានេះថា *ក្របកចាស់*។

**កួយ** /កួយ/ *ន.* វល្លិធំមួយប្រភេទវារឡើងដើមឈើដុះក្នុងព្រៃក្រាស់។ គេប្រើមែកវាសម្រាប់ធុងផឹក ពេលសម្រាលកូនដើម្បីឱ្យការសម្រាលឆាប់។ វល្លិនេះមានគុណប្រយោជន៍ច្រើនយ៉ាងផ្នែកឱសថ។

**កោងកាងភ្នំ** /កោង-កាង-ភ្នំ/ *ន.* ឈ្មោះចុល្លព្រឹក្សដុះក្នុងព្រៃត្រជាក់ឆ្នេរសមុទ្រនិងលើភ្នំ, ផ្កាពណ៌ស្វាយស្រស់ស្អាត, ផ្លែទុំស្ងោរអាចទទួលទានបាននិងអាចធ្វើតំណាប់បាន។ តាមវេជ្ជសាស្ត្របុរាណ សំបករសចត់ប្រើសម្រាប់ធ្វើថ្នាំទប់កុំឱ្យរាកឬថ្នាំព្យាបាលផ្កាសាយធំ។

**កោនាគមនោ** /កោ-នា-គាក់-មៈ-នោ/ (បា.) *ន.* ព្រះនាមព្រះសម្មាសម្ពុទ្ធទីពីរក្នុងចំណោមព្រះសម្មាសម្ពុទ្ធប្រាំព្រះអង្គដែលត្រាស់ដឹងក្នុងកទ្ទកប្បនេះ។

**កោរ** /កោ/ *គុ.* ដែលមិនមានស្លឹក។ ឧ. *ឪឡឹកកោរ, ត្រសក់កោរ*។

# ក

កំប៉ុញ / កំ-ប៉ុញ / *ន.* ឈ្មោះស្មៅតូចមួយប្រភេទសន្តានក្តាត ដុះក្រោមដើមឈើក្នុងព្រៃក្រាស់ឬព្រៃស្រោង។ គេនិយមដាំដើមនេះជិតផ្ទះឬក្នុងសួនជាលម្អ។ តាមវេជ្ជសាស្ត្របុរាណ គេយកមែកជាងស្ងោរផឹកដើម្បីបន្ទន់លាមក។

កំបោរ /កំ-បោ/ *ន.* ឈ្មោះវល្លិរឹងមួយប្រភេទមានស្លឹកពណ៌សប្រផេះដុះក្នុងព្រៃល្បោះ។ តាមវេជ្ជសាស្ត្របុរាណ ដើមកាប់ជាដុំតូចៗ រោលភ្លើងហើយត្រាំស្រាស ឬ ស្ងោរផឹករំងាប់រោគសន្លាក់ឆ្អឹង។ ដើមវា គេផ្សំធ្វើថ្នាំរំងាប់រោគថ្លើមនិងឫសដូងបាត ឬ ដាំផ្នាំងឆ្លងសម្រាប់ព្យាបាលរោគដំបៅរលួយច្រមុះ។

កំប្រុក /កំ-ប្រុក/ *ន.* (ម.ព. *អង្រុត* ។)

កំប្រុកឆ្នូតខ្នង /កំ-ប្រុក-ឆ្នូត-ខ្នង/ *ន.* កំប្រុកមួយប្រភេទដែលមានមាឌមធ្យម។ នៅលើខ្នងនិងកន្ទុយមានពណ៌ប្រផេះដោយមានឆ្នូតធំពណ៌ក្រហមដាំ។

កំប្រុកធំ /កំ-ប្រុក-ធំ/ *ន.* កំប្រុកមួយប្រភេទដែលផ្នែកពោះមានពណ៌ចាប់ពីពណ៌ពងមាន់ដល់ទឹកក្រូចនិងផ្នែកខ្នងមានពណ៌ខ្មៅឬត្នោតចាស់ បំពង់កនិងថ្ពាល់មានពណ៌ភ្លឺដែលខណ្ឌដាច់ពីគ្នាដោយឆ្នូតពណ៌ខ្មៅ។

កំប្រុកពណ៌ /កំ-ប្រុក-ពណ៌/ *ន.* កំប្រុកមួយប្រភេទដែលមានមាឌមធ្យមនិងមានការប្រែពណ៌ពីពណ៌សទៅពណ៌ទឹកក្រូចឬខ្មៅនិងពណ៌ចម្រុះគ្នា។ សត្វញីមានដោះពីរគូនិងមានកូនម្តងពីមួយទៅពីរក្បាល។

កំប្រុកស្លាបតូច /កំ-ប្រុក-ស្លាប-តូច/ *ន.* កំប្រុកមួយប្រភេទដែលមានមាឌតូចមានថ្ពាល់ក្រហម។ នៅលើខ្នង មានពណ៌ក្រហមត្នោតនិងថ្ពាល់ពណ៌ក្រហម។ ផ្នែកខាងក្រោមមានពណ៌ប្រផេះស្រាលមានកន្ទុយរាងសំប៉ែតនិងមានពណ៌ទឹកក្រូច។

កំប្រុកស្លាបធំ /កំ-ប្រុក-ស្លាប-ធំ/ *ន.* កំប្រុកមួយប្រភេទដែលមានស្លាបនិងហោះសំកាំង។

# ក

**កំប្រុញ** / កំ-ប្រុញ / *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទ វារលើដីឬលើដើមឈើ ឬ ដុះត្រង់ឡើងលើ ក្រោមម្លប់ឈើធំៗនៃព្រៃក្រាស់ឬព្រៃ។ រុក្ខជាតិនេះ គេអាចដាំជាលម្អឬសម្រាប់ការពារដីវាល។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក គេបុកឱ្យល្អិតព្យាបាលជំងឺបូស។ រុក្ខជាតិនេះមានឈ្មោះដទៃទៀតជា *ប្រត់តសី, លំពាន់។*

**កំប្លោកប្លោង** /កំ-ប្លោក-ប្លោង/ *ន.* ឈ្មោះគុម្ពព្រឹក្សមួយប្រភេទដុះលើដីវាល។ សរសៃដើម គេអាចយកធ្វើអំបោះត្បាញ, ស្លឹកមានជាតិរំអិល គេលាយជាមួយអង្ករដំណើបបុកឱ្យល្អិតដើម្បីបិទលើដំបៅឬព្យាបាលរោគសន្លាក់ឆ្អឹង, សំបកស្ងោរផឹកដើម្បីឱ្យនោមច្រើន, គ្រាប់វាជាថ្នាំបញ្ចុះ។ ជនជាតិចិននៅស្រុកខ្មែរតែងជឿថា គ្រាប់ជាថ្នាំប៉ូវលើកកម្លាំងបុរស។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ត្បាល់កិន។*

**កំពាន** /កំ-ពាន/ *ន.* ស្មៅមួយប្រភេទដុះក្នុងព្រៃធំ។ ឫសខ្ចីអាចបរិភោគដូចខ្ចីបាន។ តាមវេជ្ជសាស្ត្របុរាណ ស្លឹកនិងឫសចាស់ដែលកិនម៉ត់ គេយកទៅធ្វើថ្នាំកម្ចាត់សត្វល្អិត, ឫសវា គេប្រើជាថ្នាំលើកកម្លាំង ថ្នាំរំងាប់រោគចុកពោះ និង រោគប្រគ្រីវ។ គេទំពាឫសសម្រាប់ការពារឆ្អល់ពោះនិងស្អកក។

**កំពីងពួយគោក** /កំ-ពីង-ពួយ-គោក/ *ន.* តិណជាតិទាបមួយប្រភេទស្រដៀងនឹងកំពីងពួយ ដើមដុះត្រង់លើដី ស្លឹកដុះបែកជាប្រាំមានរាងដូចស្លាបចក្រឬតាំងយូ។ ពេលខ្លះ គេអាចប្រើផ្កានេះសម្រាប់ថ្វាយព្រះ។ ដើមវា គេប្រើធ្វើថ្នាំព្យាបាលរោគជាច្រើន ដូចជា ជំងឺនោមឈាម ជំងឺលើសឈាម ជំងឺទឹកនោមផ្អែម ជំងឺមហារីកឈាម។ល។ គេស្ងោរស្លឹកឬដើមផឹកដើម្បីជាថ្នាំលាមកទន់ឬសម្រាប់ឱ្យរដូវស្ត្រីបានទៀងទាត់។ អ្នកខ្លះហៅផ្កានេះថា *ផ្កាតាំងយូ*។

**កំពេញ** /កំ-ពេញ/ *ន.* (ម.ព. *លម៉ើព្រៃ*។)

**កំព្រាម** /កំ-ព្រាម/ *ន.* គុម្ពព្រឹក្សមួយប្រភេទដុះក្នុងព្រៃស្រោង មានលក្ខណៈជាវល្លិ, មានបន្លាដុះរង្វើលៗលើដើម, ស្លឹកតូចៗរាងទ្រវែងទាលចុងដុះលើធាងដែលបែកញែកសងខាងលើមែក, គ្រាប់ដុះក្នុងកន្សោមផ្លែរាងទ្រវែងប្រហែលផ្លែក្ងម្ពទេស,

ផ្កាជាកញ្ចុំពណ៌សតូចៗ។ គេអាចយកសំបកវាប្រើសម្រាប់លាងសក់ឱ្យស្អាត។ តាមវេជ្ជសាស្ត្របុរាណ សំបកកំព្រាមត្រូវបានប្រើសម្រាប់ធ្វើថ្នាំរំងាប់រោគ។

កំភេម /កំ-ភេម/ *ន.* គុម្ពព្រឹក្សជាដើមតូច មានស្លឹកបីដុះឆ្លាស់គ្នា មានផ្កាស្វាយឬខៀវ។ ស្លឹកដើមកំភេម គោក្របី ចូលចិត្តស៊ីណាស់។ កំភេមមានច្រើនប្រភេទ។

កំភេមតូច /កំ-ភេម-តូច/ *ន.* គុម្ពព្រឹក្សជាដើមតូច មានផ្លែសំប៉ែតរាងទ្រវែង, មានស្លឹករាងជ្រលមស្តួចចុងចែកជាបី ស្លឹកពីរនៅខាងៗ, មានផ្កាពណ៌ស្ទើរស្វាយ, ច្រើនដុះជិតដើមកំភេមធម្មតា។ គេដាំកំភេមធ្វើជារុក្ខជាតិលម្អ។ ស្លឹកកំភេមតូចៗពីរនោះមានលក្ខណៈពិសេសដោយប្រតិកម្មនឹងពន្លឺនិងសូរដែលញ៉ាំងឱ្យវាធ្វើចលនា ដែលយើងមើលទៅហាក់ដូចវារាំ។ ចលនាឬការរាំជាលក្ខណៈពិសេសមួយរបស់កំភេមតូច។

កំភ្នាង /កំ-ភ្នាង / *ន.* ចុល្លព្រឹក្សដុះក្នុងព្រៃធំត្រជាក់។ ផ្លែមានសណ្ឋានជាក្ដឹប សាច់ក្នុងពណ៌លឿងអាចបរិភោគបាន។ តាមវេជ្ជសាស្ត្របុរាណ សំបកអាចផ្សំធ្វើថ្នាំសម្រាប់ឈឺធ្មេញ, ឫសលាយនឹងរុក្ខជាតិដទៃទៀតសម្រាប់ធ្វើថ្នាំព្យាបាលជំងឺទាស់ជាដើម។

កំទ្បែង /កំ-ទ្បែង/ *ន.* ឈើមួយប្រភេទដុះក្នុងព្រៃស្ទើធំឬព្រៃធំលើដីទួលនិងភ្នំទាបៗ, សាច់ឈើមានពណ៌លឿងលាយក្រហមភាវ។ ឈើនេះមិនសូវជាប់ទេ តែ គេអាចប្រើជាគ្រឿងផ្ទះរាយរងបាន។ ជ័រនៃដើមនេះហៅថា "ជ័រចុង" សម្រាប់លាបតុ ទូ ឬ សម្រាប់ធ្វើចន្លុះ។ អ្នកខ្លះហៅឈើនេះថា *ជ័រចុង* ឬ *ធ្មឹកភ្នំ* ។

កំភ្លៅនាង /កំ-ភ្លៅ-នាង/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទដុះក្នុងព្រៃល្បោះលើដីឥដ្ឋលាយខ្សាច់ មានសំបកសដូចប្រាក់, សាច់ឈើមានពណ៌លឿងឬដាំដែង រឹង ធ្ងន់សម្រាប់ធ្វើឈើគូស។

កាំរទេះ /កាំ-រ-ទេះ/ *ន.* គុម្ពព្រឹក្សលម្អមួយប្រភេទមាន ផ្កាតូចៗដុះជាកញ្ចុំដូចកង់រទេះ ពណ៌ផ្កាឈូកឬក្រហម, កម្រមានពណ៌សឬលឿង។ ផ្លែទុំ គេអាចបរិភោគ

បាន។ ផ្កានេះមានច្រើនប្រភេទ។ តាមវេជ្ជសាស្ត្របុរាណ ស្លឹកនិងផ្កា គេស្ងោរផឹក ដើម្បីព្យាបាលជំងឺឈឺក្បាលឬចុកពោះ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ផ្កាឈាមអន្ទង់* ។

**កាំរទេះដង** /កាំ-រ-ទេះ-ដង/ ន. ចុល្លព្រឹក្សមួយប្រភេទ ដើមប្រើការសម្រាប់ធ្វើកាំរទេះ។ តាមវេជ្ជសាស្ត្របុរាណ គេផុងផ្កានិងស្លឹកផឹកសម្រាប់ព្យាបាលរោគចុកពោះ។

**កាំរទេះធំ** /កាំ-រ-ទេះ-ធំ/ *ន.* ព្រឹក្សមួយប្រភេទជារុក្ខជាតិលម្អ គេច្រើនដាំជាឈើម្លប់ក្នុងសួន។ គេអាចយកឈើនេះធ្វើកង់និងកាំរទេះ, ស្លឹកខ្ចី គេបរិភោគជាអន្លក់។ តាមក្បួនឱសថបុរាណ ស្លឹកចាស់ៗ គេស្ងោរផឹកព្យាបាលជម្ងឺគ្រុន, សំបក គេទុកជាវត្ថុការពារអំពើអំពាន់។

**ក្រោកខ្មែរ** /ក្រោក-ខ្មែ/ *ន.* (ម.ព. *ក្រោកតូច។* )

**ក្រោកតូច** /ក្រោក-តូច/ *ន.* រុក្ខជាតិមានដើមធំ, ផ្កាមានពណ៌លឿងឬក្រហមភាវ។ នៅស្រុកខ្មែរ គេនិយមដាំដើមនេះលើវិថីនានាសម្រាប់លម្អ។ តាមវេជ្ជសាស្ត្របុរាណ ផ្កា ស្លឹក សំបក ឫស គេប្រើសម្រាប់ធ្វើថ្នាំ។ គេស្ងោរផ្កាផឹកដើម្បីឱ្យបាត់ក្អកឬបញ្ចុះព្រូន។ ស្លឹកជាថ្នាំបញ្ចុះឬសម្រាប់រលូតកូន។ សំបកវា គេប្រើជាថ្នាំធ្វើខែរដូវស្ត្រីឱ្យទៀងទាត់។ ឫសកិនល្អិតដូចម្សៅសម្រាប់ព្យាបាលរោគស្គន់កូនក្មេង។ អ្នកស្រុកខ្លះហៅរុក្ខជាតិនេះថា *ក្រោកខ្មែរ* ឬ *ក្រោកហោះ។*

**ក្រោកហោះ** /ក្រោក-ហោះ/ *ន.* (ម.ព. *ក្រោកតូច។* )

**ក្ទម្ពទេសព្រៃ** /ក្ទំ-ទេស-ព្រៃ/ *ន.* (ម.ព. *អង្កាញ់ព្រៃ។* )

**ក្បុង** /ក្បុង/ *ន.* រុក្ខជាតិវល្លិមួយប្រភេទ មានសន្ទានជាមួយវល្លិអាឡូនិងវល្លិឡៃឡូ, វាតោងមែករុក្ខជាតិ, ដុះក្នុងព្រៃរបោះ។ គេអាចដុតធ្វើទឹកក្បុងប្រើដូចសាប៊ូ។ តាមវេជ្ជសាស្ត្របុរាណ ដើមនិងស្លឹក គេអាចផុងផឹកព្យាបាលជំងឺកមរមាស់។

# ក

**ក្បៀស** /ក្បៀស/ *ន.* វល្លិមួយប្រភេទវារតាមដើមឈើធំៗក្នុងព្រៃក្រាស់។ គេលាយឫសវាជាមួយទឹកកំបោរប្រើ សម្លាប់សត្វល្អិតបំផ្លាញដើមម្រេច ហើយ អាចលាយជាមួយទឹកឃ្មុំធ្វើជាឱសថបុរាណព្យាបាលជំងឺរបេង។

**ក្រ** /ក្រ/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃកោងកាងនិងព្រៃស្នាច់តាមឆ្នេរទន្លេសាប និងដងទន្លេមេគង្គ។ មែកតូចៗ គេប្រើធ្វើអុស។ តាមវេជ្ជសាស្ត្របុរាណ ក្រមានសារជាតិអាចសម្លាប់មេរោគ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ក្រាស* ។

**ក្រកោស្បាត** /ក្រ-កោ-ស្បាត/ *ន.* រុក្ខជាតិមួយប្រភេទស្រដៀងគ្នានឹងស្លឹកស្រូវ។ គ្រាប់វា គេប្រើជាគ្រឿងទេស។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេត្រាំស្រាប្រើជាថ្នាំប៉ូវកម្លាំងឬសម្រួលដល់ការបន្ទោបង់ ហើយ ផ្លែប្រើផ្សំជាថ្នាំព្យាបាលដុំពកក្នុងសួន។

**ក្រចក ( ផ្កា )** /ក្រ-ចក/ *ន.* រុក្ខជាតិមួយប្រភេទប្រភេទជាប្រទាលដុះក្រោម ដើមឈើក្នុងព្រៃស្រោង ផ្កាមានពណ៌ស្វាយលាយសមានស្លឹកទ្រនាប់រាងដូចក្រចកពណ៌ផ្កាឈូកឬក្រហមភាវនៅបាំង។ ផ្កានេះដុះភាគច្រើននៅរដូវវស្សា។ អ្នកខ្លះហៅផ្កានេះថា *ផ្កាហួយ* ។

**ក្រចកចាស់** /ក្រ-ចក-ចាស់/ *ន.* (ម.ព. *កូនដៃបណ្ឌិត។*)

**ក្រដាសតូច** /ក្រ-ដាស-តូច/ *ន.* រុក្ខជាតិវល្លិមួយប្រភេទមានគល់រឹងវារឡើងទ្រើងឬដើមឈើ, ផ្កាវាមានពណ៌ក្រហមឆ្អៅឬផ្កាឈូក ហើយ មើមអាចស្ងោរបរិភោគបាន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ផ្កាអណ្ដាតនាគ។*

**ក្រដាសស្វាយ ( ផ្កា )** /ក្រ-ដាស-ស្វាយ/ *ន.* រុក្ខជាតិមួយប្រភេទជាវល្លិវារឡើងទ្រើង, ស្រទាប់ផ្កាមានពណ៌ស្វាយមិនងាយនឹងរោយ។

**ក្របីឈ្មោល** /ក្រ-បី-ឈ្មោល/ *ន.* (ម.ព. *កុមារពេជ្រ ២។* )

**ក្រពាត់ឈ្មាង** /ក្រ-ពាត់-ឈ្មាង/ *ន.* រុក្ខជាតិមួយប្រភេទជាវល្លិវារលើដីឬដើមឈើតូចៗ, មានផ្កាពណ៌សខាងក្រៅនិងពណ៌ត្នោតឬក្រហមខាងក្នុង។ គេច្រើនដាំវាជារុក្ខជាតិលម្អ។ តាមវេជ្ជសាស្ត្របុរាណ គេអាចប្រើវាជាឱសថសម្រាប់ធ្វើព្យាបាលជំងឺចុកដៃជើង។

**ក្រពុលបាយ** /ក្រ-ពុល-បាយ/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃក្រាស់និងក្រាស់មធ្យម។ ស្លឹក គេប្រើជាចំណីគោក្របីបាន។ តាមវេជ្ជសាស្ត្របុរាណ សំបកវា គេបុកប្រើសម្រាប់ព្យាបាលបូសរយ។

**ក្រពើ** /ក្រ-ពើ/ *ន.* រុក្ខជាតិមួយប្រភេទជាវល្លិធំរឹង មានប្រភេទខ្លះដុះនៅលើដើមឈើធំៗ ឫសចាក់ជាប់ដី។ គេដាំវាជារុក្ខជាតិលម្អ។

**ក្រពេនទឹក** /ក្រ-ពេន-ទឹក/ *ន.* រុក្ខជាតិមួយប្រភេទស្រដៀងនឹងកណ្តៀង[១]ដុះក្នុងស្រែឬលើដីសើម។ ត្រួយខ្ចី គេប្រើជាបន្លែបរិភោគបាន។ តាមវេជ្ជសាស្ត្របុរាណ គេប្រើស្លឹកសម្រាប់រំងាប់រោគដំបៅរលួយពោះវៀន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ទៀន។*

**ក្រយាបូជា** /ក្រ-យ៉ា-បូ-ជា/ *ន.* (ព.មេ.) សំណែនតង្វាយ។

**ក្រឡាភ្លើង** /ក្រ-ឡា-ភ្លើង/ *ន.* អាការៈចុកស្ទះ ក្តៅអន្ទះអន្ទែង រវើរវាយ អស់កម្លាំងស្លេកស្លាំង ហើមខ្លួន នៃស្ត្រីទើបឆ្លងទន្លេ ដោយឈាមធ្លាក់ច្រើនពេកឬដោយឈាមកកនៅក្នុងស្បូន។

**ក្រាស** /ក្រាស/ *ន.* (ម.ព. *ក្រ*។)

**ក្រាំង** /ក្រាំង/ *ន.* (ម.ព. *ខោស។*)

---

[១] តាមវចនានុក្រមខ្មែរ កណ្តៀងជាឈ្មោះវារិជាតិតិណជាតិមួយប្រភេទក្នុងពួកកន្ទាំងហែ មានផ្កាពណ៌ខៀវស្រស់ គេប្រើដើមនិងស្លឹកធ្វើជាបន្លែបាន។

# ខ

**ខាន់ម៉ា** /ខាន់-ម៉ា/ *ន.* វល្លិមួយប្រភេទមានដុះក្នុងព្រៃស្រោង។ មែកជាប់ល្អប្រហែលវល្លិខាន់ម៉ាដែរ គេនិយមប្រើសម្រាប់ធ្វើចំណងចងវត្ថុផ្សេងៗ។

**ខាន់ម៉ាញី** /ខាន់-ម៉ា-ញី/ *ន.* ឈ្មោះវល្លិធំមួយប្រភេទដុះក្នុងព្រៃក្រាស់ឬព្រៃស្រោង។ ដើមជាប់ល្អ គេប្រើសម្រាប់រុំចងធុងនានា ហើយពេលខ្លះសម្រាប់សង់ផ្ទះ។

**ខេម៉ា** /ខេ-ម៉ា/ *ន.* ព្រឹក្សមួយប្រភេទ គេនាំពីទ្វីបអាម៉េរិកកណ្ដាលមកដាំជាលម្អនិងជាដើមដំណាំឱ្យផ្លែបរិភោគបាន។

**ខោស** /ខោស/ *ន.* ឈ្មោះព្រឹក្សតូចមិនជ្រុះស្លឹកមួយប្រភេទដុះក្នុងព្រៃធំលើដីទំនាបនិងលើភ្នំ។ សាច់ខាងក្នុងនៃផ្លែ គេអាចបុកលម្អិជាម្សៅធ្វើជាអាហារបាន។ ឈើសម្រាប់សង់ផ្ទះ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ក្រាំង* ។

**ខោសជ្រូក** /ខោស-ជ្រូក/ *ន.* ដើមឈើមួយប្រភេទដុះក្នុងព្រៃត្រជាក់លើភ្នំស្រុកខ្មែរ គេតែងប្រទះឃើញខោសជ្រូកដុះជាច្រើនលើភ្នំបូគោ។ ផ្លែមានជាតិម្សៅ គេអាចស្ងោរបរិភោគបាន។ គេប្រើឈើសម្រាប់សង់ផ្ទះ។

**ខោសបាយក្រៀម** /ខោស-បាយ-ក្រៀម/ *ន.* ឈ្មោះឈើមួយប្រភេទដុះក្នុងព្រៃល្បោះលើដីទំនាប។ នៅប្រទេសកម្ពុជា ខោសបាយក្រៀមច្រើនដុះក្នុងខេត្តសៀមរាបនិងខេត្តព្រះវិហារ។ គេអាចប្រទះដើមនេះមួយៗនៅខេត្តជុំវិញរាជធានីភ្នំពេញ។ មែក ធាង ឈើ គេយកធ្វើអុសដុត។

**ខោសភ្នំ** /ខោស-ភ្នំ/ *ន.* ឈ្មោះឈើមួយប្រភេទច្រើនដុះក្នុងព្រៃភ្នំ។ ផ្លែ គេអាចលីងបរិភោគបាន។ ឈើសម្រាប់ធ្វើជាគ្រឿងដំបូលផ្ទះ។

**ខ្ទូវ** /ខ្ទូវ/ *ន.* (ម.ព. *ផ្ទឹកឧត្ដម* ។)

**ខ្នាស់** /ខ្នាស់/ *ន.* ឈ្មោះឈើមួយប្រភេទដុះក្នុងព្រៃស្រោង។ គ្រាប់ខ្នាស់អាចបរិភោគបាន។ ឈើខ្នាស់ធាប់ផុយណាស់ ទុកមិនបានយូរទេ គេអាចប្រើសម្រាប់សង់រោងបណ្ដោះអាសន្ន ឬ ជាពិសេស សម្រាប់ធ្វើធ្យូង។

# ខ

**ខ្ទីង** /ខ្ទីង/ *ន.* ព្រឹក្សមួយប្រភេទកម្ពស់១៥-៣០ម៉ែត្រដុះក្នុងព្រៃក្រាស់ ជាឈើសម្រាប់សង់ផ្ទះ។ សរសៃសំបក គេប្រើសម្រាប់ធ្វើ កញ្ជើ ល្អី តូច ធំ។ល។

**ខ្ទឹង** /ខ្ទឹង/ *ន.* ព្រឹក្សមួយប្រភេទកម្ពស់៥-១ម៉ែត្រដុះលើឆ្នេរសមុទ្រដែលមានដីខ្សាច់នៃប្រទេសក្តៅ។ គេនិយមដាំខ្ទឹងតាមវិថីនានា។ ឈើខ្ទឹងជាប់ល្អណាស់ សត្វខ្មូតស៊ីមិនបាន, គេប្រើសម្រាប់ធ្វើទូកធ្វើដងក្តោងនិងសង់ផ្ទះ។ គេយកស្លឹកខ្ទឹងស្ងោរឱ្យបាត់ឈឺក្បាល វិលមុខ។ ប្រេងនៃគ្រាប់លាយជាមួយប្រេងក្របៅ គេប្រើសម្រាប់ព្យាបាលជំងឺឃ្លង់។

**ខ្លាញ់ក្តាម** /ខ្លាញ់ក្តាម/ *ន.* (ម.ព. *ព្រះឆ្លក*។)

**ខ្លែងកង្កែប** /ខ្លែង-កង់-កែប/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងកណ្តូង** /ខ្លែង-កន់-ដូង/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងកន្ទោង** /ខ្លែង-កន់-ទោង/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងកូនមាន់** /ខ្លែង-កូន-មាន់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងខ្លោះ** /ខ្លែង-ខ្លោះ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងគោម** /ខ្លែង-គោម/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងឃ្លោក** /ខ្លែង-ឃ្លោក/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងនាគ** /ខ្លែង-នាក/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងបណ្តើរកូន** /ខ្លែង-បន់-ដើ-កូន/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងប៉ោត** /ខ្លែង-ប៉ោត/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងបៅ** /ខ្លែង-បៅ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។ ខ្លះហៅ *ខ្លែងប្រប៉ៅ*។

**ខ្លែងប្រចៀវ** /ខ្លែង-ប្រ-ចៀវ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

**ខ្លែងប្រមង់** /ខ្លែង-ប្រ-ម៉ង់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

# ខ

ខ្លែងប្រយុទ្ធ /ខ្លែង-ប្រ-យ៉ុត/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងផ្កាយ /ខ្លែង-ផ្កាយ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងពស់ /ខ្លែង-ពស់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងព្នង /ខ្លែង-ព្នង/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងព្រះខែ /ខ្លែង-ព្រះ-ខែ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងមេអំបៅ /ខ្លែង-មេ-អំ-បៅ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងយក្ស /ខ្លែង-យាក់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

ខ្លែងសាក់ /ខ្លែង-សាក់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។ ខ្លះហៅខ្លែងនេះថា *ខ្លែងចាក់*។

ខ្លែងស្វាប្រសាក់ /ខ្លែង-ស្វា-ប្រ-សាក់/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។ ខ្លះហៅ *ខ្លែងស្វាប្រចាក់*។

ខ្លែងហោប៉ៅ /ខ្លែង-ហោ-ប៉ៅ/ *ន.* ឈ្មោះខ្លែងបង្ហោះមួយប្រភេទ។

# គ

គគីរខ្សាច់ /គ-គី-ខ្សាច់/ *ន.* ឈើមួយប្រភេទគល់មានឫសធំបួនប្រាំចេញខាងក្រៅ ដុះក្នុងព្រៃក្រាស់មាត់សមុទ្រ។ សត្វល្អិតពុំអាចស៊ី គេអាចប្រើសម្រាប់សង់ផ្ទះ។ សំបករលីងមានពណ៌ត្នោតខ្ចី គេប្រើធ្វើកណ្ដាប់ ធ្វើជើងខ្សែ និង ធ្វើក្រដាស។

គគីរដែក /គ-គី-ដែក/ *ន.* ឈើមួយប្រភេទដុះក្នុងព្រៃជ្រុះស្លឹកនៃដីទំនាបឬលើភ្នំទាប។ ឈើមានពណ៌ត្នោតភាវឬត្នោតលឿងភាវ រឹងល្មម ស្រួលអារ មិនប្រេះ គេប្រើសម្រាប់ សង់ផ្ទះបានយូរប្រហែល៧-៨ឆ្នាំ ឬ សង់នាវាជាប់យូររហូត៣០ឆ្នាំ។

គគីរថ្ម /គ-គី-ថ្ម/ *ន.* ឈ្មោះព្រឹក្សធំមួយដុះក្នុងព្រៃក្រាស់នៃដីទំនាប, ច្រើនដុះតាមមាត់ទឹកដែលមានព្រៃស្រោង។ គគីរថ្មជាឈើជាប់បានយូរ។ សាច់ឈើមានពណ៌ក្រហម ឬ សម្បុរត្នោត សត្វល្អិតស៊ីមិនបាន គេប្រើសម្រាប់ធ្វើ បន្ទះក្ដារ ក្ដារជើសសរផ្ទះ និង នាវា។

គគីរម្សៅ /គ-គី-ម្សៅ/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់។ គេនិយមដាំដើមគគីរតាមដងផ្លូវក្នុងក្រុងនិងស្រុកជាលម្អនិងសម្រាប់ឱ្យមានម្លប់។ ពូជគគីរត្រូវបានគេចាត់ទុកដូចជារុក្ខជាតិពិសិដ្ឋ ដែល ដើមឡើយ តាមទំនៀមខ្មែរបុរាណនៅប្រទេសកម្ពុជា មានតែមហាក្សត្រឬភិក្ខុសង្ឃទេដែលដាំដើមគគីរនេះបាន។ ឈើ គេយកធ្វើធ្វើទូកង។ ពេលមិនសូវមានដើមគគីរ គេយកឈើផ្ចឹកធ្វើទូកងវិញ។ សំបកគគីរមានជាតិចត់ជាថ្នាំរម្ងាប់រោគរាក,សំបកអាចប្រើជំនួសស្លាបានសម្រាប់ទទួលទានជាមួយម្លូ។ តាមវេជ្ជសាស្ត្របុរាណ គេថ្នាំប្រើសំបកគគីរផ្សំធ្វើថ្នាំព្យាបាលជំងឺរាក់ស៊ីធ្មេញនិងជំងឺនោមមិនដឹងខ្លួន។

គគីរភ្នំគូលេន /គ-គី-ភ្នំ-គូ-លេន/ *ន.* ប្រភេទគគីរមួយប្រភេទតូចដុះក្នុងព្រៃក្រាស់មិនជ្រុះស្លឹកលើភ្នំទាប។ សំបកវារលោងហើយរបកៗ, ជ័រដែលចេញមានពណ៌សក្រអូប។ គេប្រើវាជាឈើសម្រាប់សង់ ផ្ទះ, ស្ពាន និង គ្រឿងតុទូ ជាដើម។

# គ

គុមភ្វាត /គុំ-ភ្វាត/ *ន.* ឈ្មោះចុល្លព្រឹក្សពួកមួយមានបន្លា។ ផ្លែទុំពណ៌ក្រហមរាងមូល គេតែងធ្វើតំណាប់ទុកបរិភោគ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើស្លឹកធ្វើថ្នាំព្យាបាលជំងឺផ្លូវដកដង្ហើម។

គូទស្លា /គូត-ស្លា/ *ន.* បណ្ណង្គជាតិមួយប្រភេទដុះក្រោមដើមឈើព្រៃក្រាស់។ វាមានស្លឹកវែងឆែកៗបន្តិច។ គេនិយមយកដើមនេះដាំលម្អក្នុងផ្ទះ ជាពិសេស នៅគល់ដើមស្លា។

គោមួយ ១ /គោ-មួយ/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់និងព្រៃស្រោង។ ត្រាំសំបកក្នុងស្រាផឹកដើម្បីឱ្យបរិភោគបាយបាន។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេស្ងោរផឹកជាថ្នាំធ្វើឱ្យមានកម្លាំងប្រហែលគោ។

គោមួយ ២ /គោ-មួយ/ *ន.* វល្លិធំមួយប្រភេទ វារឡើងឈើធំៗ ដុះក្នុងព្រៃធំ។ ជ័រវល្លិនេះអាចប្រើធ្វើកៅស៊ូស្បែកជើង។ តាមវេជ្ជសាស្ត្របុរាណ គេប្រើជ័រសម្រាប់ធ្វើថ្នាំរំងាប់ ជំងឺក្រពះ ជំងឺគ្រុន និង ប្រើជាថ្នាំកម្លាំង។ គេប្រើផ្សំធ្វើថ្នាំប្រឆាំងជំងឺគ្រុនចាញ់។

គោរាគៈ /គោ-រា-គាក់/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីមួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម។ រឿងនេះមាននិទានក្នុងសង្រ្កានសូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃចន្ទ ឆ្នាំនោះជាឆ្នាំដែលព្រះនាង គោរាគៈ គ្រប់គ្រង។ ព្រះនាង គោរាគៈ សៀតផ្កាអង្គាបុស្ប គ្រឿងប្រដាប់មុក្តា ភក្សាហាររប្រេង អាវុធស្តាំព្រះខ័ន ឆ្វេងឈើច្រត់ ពាហនៈខ្លា។

គោល /គោល/ *ន.* ដើមឈើមួយប្រភេទដុះក្នុងព្រៃស្រោងនិងល្បោះ។ គេច្រើនដាំដើមគោលធ្វើម្លប់ក្នុងចម្ការដើមតែនិងកាហ្វេ។ ដើមតូចៗ គេកាប់ធ្វើបង្គោលរបង។ គេដាំសម្រាប់លម្អសួនសាធារណៈ។ ដើមគោល គេអាចធ្វើក្រដាសបាន។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក ផ្លែ គ្រាប់ គេប្រើសម្រាប់ធ្វើថ្នាំ។ ស្លឹកស្ងោរផឹកដើម្បីបន្ទន់លាមក។

# គ

គ្រាប់បែក /គ្រាប់-បែក/ *ន.* ព្រឹក្សមួយប្រភេទមានប្រភពពីអាម៉េរិកកណ្ដាល គេច្រើនដាំលម្អវិថីក្នុងក្រុងក្នុងសួននិងសម្រាប់ជាម្លប់ផង។ ឈ្មោះខ្មែរនេះប្រហែលជាប្រជាជនដាក់តាមទម្រង់សាច់ខាងក្នុងនៃផ្លែដែលមានរាងមូលនៃរុក្ខជាតិនេះ ពីព្រោះ នៅពេលសំបករបើកចេញ វាស្រដៀងគ្នាទៅនឹងគ្រាប់បែក។ ប្រជាជននៃប្រទេសមួយចំនួននៅអាស៊ីប្រើគ្រាប់គ្រាប់បែកធ្វើជាថ្នាំព្យាបាលជំងឺលើសសម្ពាធឈាម, ជំងឺទឹកនោមផ្អែម និង ជំងឺគ្រុនចាញ់ជាដើម។

គ្រុង /គ្រុង/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃល្បោះលើដីរាបឬដុះលើភ្នំទាប។ តាមវេជ្ជសាស្ត្របុរាណ គេប្រើឫសវាសម្រាប់ធ្វើថ្នាំស្វាយប្រមេះ។ អ្នកហៅរុក្ខ-ជាតិនេះថា *គ្រុងក្រហម* ឬ *គ្រុងវល្លិ*។

គ្រុងទេស /គ្រុង-ទេស/ *ន.* រុក្ខជាតិលម្អសួនមួយប្រភេទ។ ដើមនេះ គេអាចធ្វើក្រដាសបាន។ ស្លឹក ផ្លែ គ្រាប់ សម្រាប់ធ្វើថ្នាំ, ស្លឹកស្ងោរផឹកដើម្បីបន្ទន់លាមកក្មេងៗ។ ផ្លែវា គេហូបដើម្បីធ្វើឱ្យមានកម្លាំង។ គេស្ងោរគ្រាប់ផឹកដើម្បីឱ្យនោមច្រើន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *មនបារាំង*។

គ្រុមពួក /គ្រុម-ពួក/ *ន.* គ្រុមមួយពួកដុះក្នុងព្រៃត្រជាក់ឥតជ្រុះស្លឹករដូវប្រាំង។ ផ្កាសមានតែមួយស្រទាប់រីករាងជារង្វេលក្រសោប, ស្លឹករាងរៀវពីគល់រីកធំនៅចុង, ផ្លែអាចបរិភោគបានពេលចម្អិនហើយ។ ឈើគ្រុមពួកអាចប្រើសង់ផ្ទះបាន។

គ្រើល /គ្រើល/ *ន.* ឈ្មោះឈើធំមួយប្រភេទដុះក្នុងព្រៃស្រោង។ មែកនិងដើមមានជ័រមួយប្រភេទដែលគេអាចយកចេញដោយកាត់នឹងកាំបិតឬដុត។ ជ័រឬម្រ័ក្សណ៍នេះ គេប្រើសម្រាប់លាបវត្ថុផ្សេងៗដូចជា កញ្ជើ ល្អី ។ល។ ដើម្បីធ្វើមិនឱ្យជ្រាបទឹក។ ឈើជាប់ល្អមានតម្លៃ គេប្រើធ្វើសសរផ្ទះ និង តុ ទូ ល្អប្រណីត។ សំបកគ្រើលសម្រាប់ធ្វើថ្នាំដក់ឬឃាត់មិនឱ្យរាកជាដើម។ គួរសម្គាល់ថា ដើមគ្រើល គឺ ដើមរស់ ឬ ម្រ័ក្សណ៍ គឺ ដើមកាប់ហើយ។

# គ

គ្រឿងឥស្សរិយយស /គ្រឿង-អ៊ិស-សាក់-រ៉ិ-យ៉ាក់-យស/ *ន.* អាភរណភណ្ឌ សម្រាប់យស។ ប្រទេសកម្ពុជាចែកគ្រឿងឥស្សរិយយសជាពីរប្រភេទធំៗ គឺ លំដាប់ថ្នាក់ពិសេស និង លំដាប់ថ្នាក់ធម្មតា។ លំដាប់ថ្នាក់ពិសេសមាន ជាតូប ការ និង មហាកណ្ឋាភណ្ឌ ឯករាជ្យជាតិ។ លំដាប់ថ្នាក់ធម្មតាមាន១៦។ លំដាប់ ថ្នាក់ទី១ គឺ គ្រឿងឥស្សរិយ យស ព្រះរាជាណាចក្រកម្ពុជា ៖ អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរសេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ថ្នាក់ទី២ គឺ គ្រឿងឥស្សរិយយស ឯករាជ្យជាតិ ៖ អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរសេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ ថ្នាក់ទី៣ គឺ គ្រឿងឥស្សរិយយស សហមេត្រី ៖ អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរ-សេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ថ្នាក់ទី៤ គឺ គ្រឿងឥស្សរិយយស សេនាជយ សិទ្ធិ។ លំដាប់ថ្នាក់ទី៥ គឺ គ្រឿងឥស្សរិយយស ការពារប្រទេស ៖ ផ្នែកកងវរ-សេនាតូច ឬ ផ្នែកឃុំសង្កាត់, ផ្នែកកងទ័ព ឬ ផ្នែកខេត្តរាជធានី និង ផ្នែកព្រះរាជា ណាចក្រ។ លំដាប់ថ្នាក់ទី៦ គឺ គ្រឿង ឥស្សរិយយស មកុដរាជ្យ។ លំដាប់ ថ្នាក់ទី ៨ គឺ គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ មុនីវង្ស កុសុមៈ ៖ សំរឹទ្ធិ, ប្រាក់, អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរសេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ ថ្នាក់ទី៩ គឺ គ្រឿងឥស្សរិយយស សុវត្ថា ៖ អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរសេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ថ្នាក់ទី១០ គឺ គ្រឿងឥស្សរិយយស មុនីសារាភណ ៖ អស្សប្ញទ្ធិ, សេនា, ធិបតិន្ទ, វរសេនា និង មហាសិរីវឌ្ឍន៍។ លំដាប់ថ្នាក់ទី១១ គឺ គ្រឿងឥស្សរិយយស អនុស្សរា ៖ សំរឹទ្ធិ, ប្រាក់ និង មាស។ លំដាប់ថ្នាក់ទី១២ គឺ គ្រឿងឥស្សរិយយស ខេមរបតិការ ៖ ប្រាក់ និង មាស។ លំដាប់ថ្នាក់ទី១៣ គឺ គ្រឿងឥស្សរិយយស វឌ្ឍនការ ៖ សំរឹទ្ធិ, ប្រាក់ និង មាស។ លំដាប់ថ្នាក់ទី១៤ គឺ គ្រឿងឥស្សរិយយស ខេមរកីឡាប្ញទ្ធិ ៖ សំរឹទ្ធិ, ប្រាក់ និង មាស។ លំដាប់ថ្នាក់ទី ១៥ គឺ គ្រឿងឥស្សរិយយស សុទ្ធការ ៖ សំរឹទ្ធិ, ប្រាក់ និង មាស។ ព្រមទាំង លំដាប់ពិសេស ក្រៅការចាត់ថ្នាក់មួយទៀត គឺ គ្រឿងឥស្សរិយយស ស្ត្រីវឌ្ឍនា ៖ សំរឹទ្ធិ, ប្រាក់ និង មាស។

# គ

គ្រេប /គ្រេច/ *ន.* ស្មៅទាបមួយប្រភេទដុះដោយសារដើមដទៃទៀតគឺដើមបញ្ជើខ្លួនលើគេ ច្រើនដុះលើឫសសន្ទាន ដើមស្រូវ ដើមពោត។ តាមវេជ្ជសាស្ត្របុរាណ ស្មៅនេះប្រើដើម្បីព្យាបាលរោគដំបៅនិងគ្រេចជើងដៃ។ គេទំពាដើមឱ្យម៉ត់ ទើបខ្ចាក់ក្នុងស្លឹកចេកហើយយកទៅអ៊ើរភ្លើង មុននឹងយកទៅស្អំកន្លែងឈឺ។

# ឃ

ឃ្នត់ /ឃ្នត់/ *ន.* ព្រឹក្សធំដុះក្នុងព្រៃល្បោះ។ ដើមនេះច្រើនទាញអារម្មណ៍អ្នកដើរព្រៃ ដោយបញ្ចេញក្លិនក្រអូប។ គេប្រើសំបកសម្រាប់ធ្វើធូប។

ឃ្លាយ /ឃ្លាយ/ *ន.* ចុល្លព្រឹក្ស ពេលខ្លះ ជាវល្លិរឹងមានកង្វាតោងរុក្ខជាតិដទៃ ដុះក្នុង ព្រៃស្រោងព្រៃក្រាស់ឬព្រៃល្បោះ។ សំបកវា គេធ្វើខ្សែពួរនាវា។ តាមវេជ្ជសាស្ត្របុរាណ រុក្ខជាតិនេះ គេប្រើសម្រាប់ព្យាបាលជំងឺជាច្រើន ដូចជា ក្អក, ខ្លួន, ឃ្លង់,ហឺត, ទល់លាមក, រមាស់, រលាកទងសួត, ឫសដូង, សរសៃប្រសាទ ជាដើម។ ផ្នែកទុំ បើទទួលទានតែផ្លែមួយជាថ្នាំបញ្ចុះ បើទទួលទានដល់បី ធ្វើឱ្យរាកជាច្រើន អាចបណ្តាលឱ្យស្លាប់។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ឆ្លាយ*។

ឃ្នាស /ឃ្នាស/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់ជ្រុះស្លឹកនិងព្រៃល្បោះ។ ផ្លែបរិភោគបានស្លឹកជូរតិចៗ អាចស្ងោរលាងសំពត់បាន។ តាមវេជ្ជសាស្ត្របុរាណ ស្លឹកនេះគេប្រើធ្វើថ្នាំបុរាណសម្រាប់ព្យាបាលជំងឺភ្នែកក្រហម។ ឈើប្រើធ្វើក្តារក្រាលផ្ទះនិងខ្នម។

ឃ្លេ /ឃ្លេ/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទមានបន្លាច្រើនវារឡើងលើដើមជិតខាងក្នុងព្រៃនាមឥណ្ឌូចិន។ ស្លឹកនិងឫសជាឱសថ ស្លឹកអាចបុកបំពោកលើដំបៅឱ្យឆាប់ជា ឯឫស គេស្ងោរផឹកដើម្បីរម្ងាស់រោគហឺតនិងសន្លាក់ឆ្អឹង។ ខ្លឹមឈើអាចស្ងោរជ្រលក់សូត្រ។

ឃ្លៃ /ឃ្លៃ/ *ន.* ចុល្លព្រឹក្ស ពេលខ្លះ ជាវល្លិរឹងមានកង្វារដុះក្នុងព្រៃស្រោងព្រៃក្រាស់ ឬព្រៃល្បោះនៃទ្វីបអាស៊ីអាគ្នេយ៍។ សំបកសម្រាប់ធ្វើខ្សែពួរនាវា។ គេយកទឹកស្ងោរស្លឹកដើមនេះបិទលើភ្នែកដែលឈឺ។ ផ្នែកទុំបើទទួលទានតែផ្លែមួយ វាជាថ្នាំបញ្ចុះ បើទទួលទានដល់បីផ្លែ ធ្វើឱ្យរាកជាច្រើន អាចបណ្តាលឱ្យស្លាប់។

# ចខ-ឆ

ចេកទុំផ្កាស /ចេក-ទុំ-ផ្កា-ស/ *ន.* (ម.ព. *កន្ទុយល្វេ*។)

ចៅហ្វាយក្រុង /ចៅ-វ៉ាយ-ក្រុង/ *ន.* ឈ្មោះតំណែងរដ្ឋបាលនៃអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងក្រុង។ (ម.ព. *ចៅហ្វាយខេត្ត* បន្ថែម។)

ចៅហ្វាយខេត្ត /ចៅ-វ៉ាយ-ខែត/ *ន.* ឈ្មោះតំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងខេត្ត។ តាមព្រះរាជក្រមលេខ៣០៨-បរ ចុះថ្ងៃទី១៨-០៧-១៩៦៧ របស់សម្តេចព្រះនរោត្តម សីហនុ ពាក្យ *ចៅហ្វាយខេត្ត ចៅហ្វាយក្រុង ភូឈួយក្រុង ចៅហ្វាយស្រុក មេឃុំ* និង *ឃុំ* ត្រូវបានប្តូរជា *អភិបាលខេត្ត អភិបាលក្រុង អភិបាលខេត្តរង អភិបាលក្រុង អភិបាលក្រុងរង អភិបាលស្រុក ចៅសង្កាត់* និង *សង្កាត់* ។ បច្ចុប្បន្ន ពាក្យចៅហ្វាយខេត្ត ចៅហ្វាយក្រុង ជាដើម នៅប្រើជាសម្តីប្រជាជនក្រៅពីលិខិតរដ្ឋបាល។ ចំណែកពាក្យ *សង្កាត់* គេប្រើសម្រាប់រដ្ឋបាលថ្នាក់ក្រុងរាជធានី ដោយពាក្យ *ឃុំ* គេប្រើសម្រាប់រដ្ឋបាលក្រៅពីក្រុងនិងរាជធានី។

ប្រត់ព្រះធរណី /ប្រត់-ព្រះ-ធ-រៈ-នី/ *ន.* ឈ្មោះមេអុតទីប្រាំបួនកើតនៅជង្គង់។

ប្រត់ឥសី /ប្រត់-អ៊ិ-សី/ *ន.* (ម.ព. *កំប៉ុញ*។)

ប្រ៊ុះ /ប្រ៊ុះ/ *ន.* ចានជងមួយគូមានស្លឹកម្លូតម្រៀបជុំវិញនិងមានស្លាខ្ចីឬស្លាទុំមួយដៃ។

ធីស្រុក /ធី-ស្រុក/ (ភាសាខ្មែរសម័យកណ្តាល) កាន់កាប់ដែនដីសម្រេចរាជការ, គ្រប់គ្រងដែនដី។ *ឧ. ឧកញ៉ាអរជូនធីស្រុកត្បូងឃ្មុំ។*

ធៀងប្រាសាទ /ធៀង-ប្រា-សាត/ *ន.* ឈ្មោះមេអុតទីបួនកើតនៅកញ្ចឹងក។

ធាំធា /ធាំ-ធា/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទ ពេលខ្លះ ដុះក្នុងព្រៃត្រជាក់ក្បែរមាត់សមុទ្រឬលើភ្នំ។ ឈើមានពណ៌ប្រផេះ ក្លិនក្រអូបមានតម្លៃសម្រាប់ប្រើសង់ជាគ្រឿងផ្ទះ។

ធាំធាខ្លឹមចន្ទន៍ /ធាំ-ធា-ខ្លឹម-ចាន់/ *ន.* ព្រឹក្សមួយប្រភេទដុះក្នុងព្រៃធំមាត់សមុទ្រ។ ឈើមានក្លិនក្រអូបដូចខ្លឹមចន្ទន៍ធ្វើឱ្យសត្វល្អិតគេចទៅឆ្ងាយ។ វាជាឈើមាន

តម្លៃគេប្រើសម្រាប់ធ្វើជា តុ ទូ និង គ្រឿងផ្ទះ។ គេស្ងោរសំបកនិងឫសផឹកជាថ្នាំរំងាប់រោគគ្រុននិងរាក។

ឆ្កែង /ឆ្កែង/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះតែក្នុងស្រុកខ្មែរទេ តាមមាត់ទឹកក្នុងព្រៃរនាមជុំវិញទន្លេសាប, ឈើជាប់ល្អសម្រាប់ធ្វើគ្រឿងសង់ផ្ទះ។ សំបកប្រើសម្រាប់ជ្រលក់សំពត់។

ឆ្កោទន់ /ឆ្កោ-ទន់/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះក្រោមឈើធំៗ។ ដើមនេះគេប្រើធ្វើឱសថ។ ស្លឹកនិងឫសប្រើជាថ្នាំរំងាប់ជំងឺឈឺក្បាលកូនក្មេង។ គេស្ងោរឫសផឹកដើម្បីព្យាបាលជំងឺឈឺចាប់ខ្លាំង ជាពិសេស ជំងឺចុកខ្លួនប្រាណ។

ឆ្នាលមន /ឆ្នាល-មន/ *ន.* ឈ្មោះវល្លិធំមួយប្រភេទវារឡើងដើមឈើ ពេលខ្លះ ជាចុល្លព្រឹក្សដុះត្រង់ទៅលើ ច្រើនដុះក្នុង ព្រៃមាត់សមុទ្រលើដីមានភក់ល្បាប់។ ក្នុងប្រទេសលាវ ដើមនេះដុះក្នុងមាត់ទឹកសាប។ ស្លឹកខ្ចីអាចប្រើធ្វើអន្លក់របោយ។ តាមវេជ្ជសាស្ត្របុរាណ គេយកឫសដាំផឹករម្ងាប់រោគគ្រុន។

ឆ្នាលមនស្បាត /ឆ្នាល-មន-ស្បាត/ *ន.* ឈ្មោះគុម្ពព្រឹក្សមួយប្រភេទ ដុះក្នុងព្រៃស្រោងឬព្រៃស្រស់។ ដើមសម្រាប់ធ្វើបង្គោលរបង មែកតូចៗ សម្រាប់ធ្វើអុសដុត។

ឆ្នុកត្នាតបាត /ឆ្នុក-ត្នាត-បាត/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទមានស្លឹកដុះជាកញ្ចុំនៅខាងលើដើមជារុក្ខជាតិដែលគេប្រទះក្នុងព្រៃក្រាស់មាត់សមុទ្រ។ ផ្លែ គេអាចបរិភោគបាន, មែកជាង គេប្រើធ្វើអុសដុត។

ឆ្នូត /ឆ្នូត/ *ន.* ចុល្លព្រឹក្សមួយប្រភេទ ពេលខ្លះ ជាវល្លិវារលើរុក្ខជាតិជិតខាង ដុះក្នុងព្រៃស្រោង។ ខ្លឹមដើមមានក្លិនក្រអូប គេយកធ្វើធូប។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំតែងយកខ្លឹមឈើសម្រាប់ឱ្យគេឆ្អុងរំងាប់រោគឈឺក្បាល។ វត្ថុរំអិលចំរាញ់ចេញពីស្លឹក គេប្រើធ្វើជាថ្នាំសម្រាប់ធ្វើឱ្យក្អួត (ពេលពុលអាហារ)។

ឆ្នូតគ្រាប់ /ឆ្នូត-គ្រាប់/ *ន.* ចុល្លព្រឹក្សមួយប្រភេទកម្ពស់ពី២-៦ម៉ែត្រ ពេលខ្លះជាវល្លិដុះក្នុងព្រៃល្បោះ។ ផ្កាមានពណ៌លឿងក្លិនក្រអូបសម្រាប់ក្រងខ្សែក។ ឈើវាមានក្លិនក្រអូបដែរ គេប្រើសម្រាប់ធ្វើរូបចម្លាក់តូចៗឬប្រើជាគ្រឿងក្រអូប សម្រាប់ដុត

ក្នុងវត្តវិហារ។ តាមវេជ្ជសាស្ត្របុរាណ គេអាចស្ងោរថ្នាំឆ្កុងជាមួយឈើធ្នូតគ្រាប់ដើម្បីព្យាបាលជំងឺឈឺក្បាលវិលមុខ។

**ឆ្វាង** /ឆ្វាង/ *ន.* (ម.ព. *កន្ទុយល្វេ។*)

**ឆ្វេះ** /ឆ្វេះ/ *ន.* ព្រឹក្សមួយប្រភេទកម្ពស់ខ្ពស់ដុះក្នុងព្រៃស្រោង។ ដើមធំដុះត្រង់, លើដើមមានក្រឡាសណ្ឋានជាស្រកាពស់ធំៗ។ ជ័រស្លឹកនិងសំបក គេផ្សំធ្វើទឹកថ្នាំខាប់សម្រាប់លាបក្បាលព្រួញបាញ់សត្វ។ សត្វដែលត្រូវគ្រាប់ព្រួញស្លាប់ គេអាចបរិភោគបាន តែ ត្រូវកាត់សាច់ដែលត្រូវព្រួញចោលសិន ឬ ត្រូវបន្សាបពិសជ័រនេះ ដោយយកសាច់ក្ដាមបិទស្នាមរបួស។ ដើមឆ្វេះអាចធ្វើឱ្យមានរមាស់នៅខ្លួនដល់អ្នកដែលស្ទាបវាយូរ។

**ឆ្អឹងពស់** /ឆ្អឹង-ពស់/ *ន.* ឈ្មោះគុម្ពព្រឹក្សមួយប្រភេទមែកមានបន្លាស្រួចៗ។ នៅប្រទេសកម្ពុជា គេច្រើនដាំក្នុងផើងជិតផ្ទះ។ ផ្កាពណ៌ក្រហមឆ្អៅ ពេលខ្លះ ដុះជុំវិញមែក អ្នកខ្លះមានជំនឿថាដើមនេះធ្វើឱ្យអ្នកដាំចម្រុងចម្រើនពេលដែលមានផ្កា។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ទេវតាប្រាំបីទិស* ឬ *ដើមសេដ្ឋី*។

**ឆ្អឹងពស់ភ្នំ** /ឆ្អឹង-ពស់-ភ្នំ/ *ន.* ឈ្មោះចុល្លព្រឹក្សមួយស្ទើរវារដុះក្នុងព្រៃក្រាស់លើភ្នំ។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំបុរាណប្រើដើមនេះសម្រាប់ធ្វើថ្នាំទឹកព្យាបាលរបួសពស់ចឹក។

**ឆ្អឹងពស់ស្វា** /ឆ្អឹង-ពស់-ស្វា/ *ន.* ចុល្លព្រឹក្សវារតោងដើមជិតខាង ដុះក្នុងព្រៃល្បោះ។ ដើម គេប្រើសម្រាប់ធ្វើលបនិងធ្វើចំណងផ្សេងៗ។ តាមវេជ្ជសាស្ត្របុរាណ គេអាចយកដើមកាត់តូចៗស្ងោរផឹកព្យាបាលជំងឺគ្រុន។

# ជ-ឈ-ញ

ជង្គង់ប្រើស /ជង់-គង់-ប្រើស/ *ន.* តិណជាតិតូចវារលើដីមួយប្រភេទ មានមែកខ្លះតូចៗបញ្ឈរឡើងលើរាងដូចជង្គង់ប្រើសឬរមាំង។ តាមធម្មតា គេយកដើមទាំងមូលទុកលាយបាយជ្រូក មនុស្សអាចបរិភោគដើមបាន។ នៅប្រទេសដទៃ គេតែងបរិភោគដើមជង្គង់ប្រើសជារៀងរាល់ថ្ងៃជាបន្លែឆ្អិន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ជង្គង់រមាំង* ឬ ផ្ទីថ្ម ។

ជង្គង់អណ្តើក /ជង់-គង់-អន់-ដើក/ *ន.* ចុល្លព្រឹក្សដុះរៀចរ៉ចមួយប្រភេទ គេប្រទះក្នុងព្រៃស្រោងនៃឥណ្ឌូចិន។ ផ្លែ គេបរិភោគបាន។ គេនិយមយកមែកជាងធ្វើឧសដុត។

ជណ្តើរស្វាតូច /ជន់-ដើរ-ស្វា-តូច/ *ន.* ចុល្លព្រឹក្សមានមែកបែកសាខាឬមួយជាវល្លិវារឡើងលើរុក្ខជាតិជិតខាង។ វាដុះតាមមាត់ព្រៃឬក្នុងព្រៃជ្រុះស្លឹកលើដីរាបឬលើទួល, ពេលដុះតាមចន្លោះព្រៃ ដើមនេះអាចក្លាយជាចុល្លព្រឹក្សវិញ។ សំបកដើមសម្រាប់វិញខ្សែជាប់ល្អណាស់។ ដើម គេកាត់កង់ៗយកស្ងោរផឹកព្យាបាលជំងឺមួល។

ជម្ពូជ្រលក់ /ជំ-ពូ-ជ្រ-លក់/ *ន.* ចុល្លព្រឹក្សមានប្រភពពីពីអាម៉េរិកក្តៅ គេដាំជុំវិញគេហដ្ឋានជាលម្អ។ គ្រាប់ជម្ពូជ្រលក់មានជាតិជ្រលក់ពណ៌ក្រហមលាយពណ៌លឿងភាវ គេប្រើសម្រាប់ជ្រលក់សំពត់អាវឬរបស់ផ្សេងៗ។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក គេយកដាំទឹកងូតឬត្រាំពេលកើតជំងឺ គ្រុនចាញ់ គ្រុនមានពិសស្បែក ឬ គ្រុនក្តៅ ជាដើម។

ជ័រចុង /ជ័រ-ចុង/ *ន.* (ម.ព. *កំឡែង។* )

ជ័របាញ់ /ជ័រ-បាញ់/ *ន.* លតាជាតិធំមួយប្រភេទវារលើដើមខ្ពស់ពីដីក្នុងព្រៃស្រោងឬព្រៃល្បោះ។ ដើមជ័របាញ់មានបញ្ចេញជ័រពណ៌សសម្រាប់លាបព្រួញបាញ់សត្វព្រៃ។

# ជ-ឈ-ញ

ជាតូបការ /ជា-តូ-ប៉ៈ-កា/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយយស* ផង។)

ជើងគោព្រៃ /ជើង-គោ-ព្រៃ/ *ន.* ចុល្លព្រឹក្សស្ទើរវារដុះនៅព្រៃល្បោះតាមមាត់ផ្លូវមាត់ព្រៃសមុទ្រក្នុងប្រទេសកម្ពុជា។ ស្លឹកអាចមូរបារីជក់បាន។ មែកនិងសំបកគេធ្វើខ្សែព្យួរ។ នៅប្រទេសដទៃទៀត ជើងគោព្រៃដុះឆ្ងាយពីមាត់សមុទ្រ។

ជើងគោស /ជើង-គោ-ស/ *ន.* ចុល្លព្រឹក្សមានកំណើតក្នុងប្រទេសឥណ្ឌូណេស៊ី ឬដាំយូរណាស់ហើយ។ គេតែងដាំជិតផ្ទះម៉ត់សម្រាប់ព្យាបាលជំងឺដំបៅច្រមុះ។ គេឱ្យស្ងោរស្លឹកផឹកដើម្បីឱ្យបាត់ក្អក។

ជើងគោផ្កាស /ជើង-គោ-ផ្កា-ស/ *ន.* ចុល្លព្រឹក្សដុះក្នុងព្រៃជ្រុះស្លឹកលើដីទំនាប។ នៅប្រទេសកម្ពុជា គេយកសំបកជើងគោផ្កាសស្ងោរស្ងូត្រឱ្យបានសល្អ។ ស្លឹកសម្រាប់ព្យាបាលជំងឺរមាស់។

ជេងគ្រេងក្រហម /ជេង-គ្រេង-ក្រហម/ *ន.* (ម.ព. *ម្លូវក្រហម* ។)

ញិញ /ញិញ/ *ន.* (ម.ព. *រមាំង* ។)

# ដ-ថ-ឌ-ឍ-ណ-ត-ថ-ទ-ធ-ន

ដាវក្រពើ /ដាវ-ក្រ-ពើ/ *ន.* (ម.ព. *ពុំសែន*។)

ដើមប្រើស /ដើម-ប្រើស/ *ន.* (ម.ព. *លម៉ើព្រៃ*។)

ដើមសេដ្ឋី /ដើម-សេត-ឋី/ *ន.* (ម.ព. *ធ្មឹងពស់*។)

ដំ /ដំ/ *កិ.* ជ្រាបជាតិដំបែទៅក្នុងបាយដំណើបហើយប្រែក្លាយជាបាយដំណើបទៅជាត្រប៉ែមានក្លិនប្រហាក់ប្រហែលនឹងស្រា។

ដំឡូងគ្រឹង /ដំ-ឡូង-គ្រឹង/ *ន.* (ម.ព. *ប្រទាលនាងស*។)

ឌីងប៊ុក /ឌីង-ប៊ុក/ *ន.* ស្គរបំពង់ឫស្សី, ឧបករណ៍ភ្លេងមួយប្រភេទរបស់ជនជាតិដើមភាគតិចខ្មែរ។ នៅពេលគេលេង គេទះផ្នែកសងខាងនៃបំពង់ឫស្សី។

តាត្រៅទឹក /តា-ត្រៅ-ទឹក/ *ន.* (ម.ព. *ព្រហូតទឹក*។)

ត្បាល់កិន /ត្បាល់-កិន/ *ន.* (ម.ព. *កំប្លោកប្លោង*។)

ត្រប់មមីស /ត្រប់-មៈ-មីស/ *ន.* ត្រប់មួយប្រភេទមានប្រភពមកពីអាម៉េរិកក្ដៅ ហើយត្រូវបានយកទៅដាំនៅប្រទេសក្ដៅ។ វាអាចដាំជារុក្ខជាតិលម្អ។ មែកខ្ចីគេបរិភោគជាមួយស៊ុតមាន់ឫទា ដើម្បីព្យាបាលជំងឺផ្លូវដង្ហើម ឯស្លឹកបុករោលភ្លើងគេប្រើជាថ្នាំសម្រាប់រីតក្មេងខ្យល់គរ ហើយ ស្លឹកនេះ គេប្រើជាសាប៊ូបាន។ ត្រប់នេះមានប្រយោជន៍ព្យាបាលជំងឺច្រើនយ៉ាងតាមបែបវេជ្ជសាស្ត្របុរាណ។ អ្នកខ្លះហៅត្រប់នេះថា *អាមែកន្ទួល*។

ត្រួន /ត្រួន/ *ន.* រោងតូចមាន៣ថ្នាក់, បង្គោលរោងមានដោតបាយសីច្រើនថ្នាក់; នៅថ្នាក់លើបំផុត គេដាក់ឆត្រពណ៌បាំងពីលើនិងមានដោតមាន់ឆ្កាងនឹងសសរត្រួន។

ថ្មបង្គ្រាន /ថ្ម-ចង់-ក្រាន/ *ន.* (ម.ព. *ពង្រភ្នំ*។)

ថ្មរាប់ /ថ្ម-រាប់/ *ន.* (ម.ព. *ប្រទាលបូស*។)

ថ្លាង /ថ្លាង/ *ន.* (ម.ព. *កន្ទុយល្មេ*។)

# ដ-ឋ-ឌ-ឍ-ណ-ត-ថ-ទ-ធ-ន

ទុង្សា /ទុង-សា/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីច្បងក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម។ រឿងនេះមាននិទានក្នុងសង្ក្រានសូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃអាទិត្យ ឆ្នាំនោះជាឆ្នាំដែលព្រះនាង *ទុង្សា* គ្រប់គ្រង។ ព្រះនាង *ទុង្សា* សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភាក្សាហារផ្លែឧទុម្ពរ អាវុធស្តាំចក្រ ឆ្វេងសង្ខ ពាហនៈគ្រុឌ។

ទៀន /ទៀន/ *ន.* (ម.ព. *ក្រពេនទឹក។* )

ទេវតាប្រាំបីទិស /ទេ-វៈ-ដា-ប្រាំ-បី-ទឹស/ *ន.* (ម.ព. *ឆ្អឹងពស់* ។)

ទំពាំងបាយជូរព្រៃ /ទំ-ពាំង-បាយ-ជូ-ព្រៃ/ *ន.* (ម.ព. *កក្រើក* ។)

ធិបតិន្ទ /ធិប-ប៉ៈ-ដិន/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយយស* ផង។)

ធ្លាយ /ធ្លាយ/ *ន.* (ម.ព. *ឃ្លាយ* ។)

នក /នក/ *កិ.* អស់តំណែងដោយចាស់ឬដោយផុតបុណ្យ។ ឧ. *មេស្រុកនក។*

នប់ /នប់/ *ន.* ពិធីការពារឬបណ្តេញខ្មោចព្រាយបិសាចតាមរយៈការប្រើមន្តអាគមដោយបោះដែកគោលឬព័ទ្ធសីមាត្រង់កន្លែងដែលគេត្រូវបង្កាត់ភ្លើងឱ្យស្រីកូនខ្ចីអាំង។

នុងឃៀល /នុង-ឃៀល/ *ន.* ឧបករណ៍តន្ត្រីផ្លុំមួយប្រភេទ ក្នុងពពួកឧបករណ៍ស្នែងរបស់ជនជាតិព្នង។ ឧបករណ៍នេះធ្វើពីស្នែងក្របី, អណ្តាតធ្វើពីឫស្សីបិទក្រមួនសត្វម្រោមត្រង់កណ្តាលតួ។ ផ្នែកចុងត្រូវចិតឱ្យមានរន្ធ។ ពេលផ្លុំ គេប្រើមាត់និងដៃ។ វាជាឧបករណ៍មានសូរគ្រលួចចាងស្នែងទាក់ដំរី។ គេផ្លុំវាតែក្នុងពិធីអន្ទងហៅព្រលឹងសក្តិសិទ្ធិ ព្រលឹងបុព្វបុរស។

ន្ទូម /នៈ-ហ៊ូម/ *ន.* ឧបករណ៍តន្ត្រីផ្លុំមួយប្រភេទ ក្នុងពពួកខ្លុយ ជារបស់ជនជាតិព្នង។ ន្ទូមមានរន្ធដែលគេចោះខាងមុខចំនួនបួននិងរន្ធផ្នែកខាងក្រោមចំនួនមួយ, រន្ធ

# ជ-ថ-ឌ-ឆ-ឈា-ឥ-ថ-ឧ-ឆ-ន

ខាងលើសម្រាប់បញ្ចេញសូរ  រន្ធខាងក្រោមសម្រាប់បង្ហើរខ្យល់ចោល។  សូរន្ទូម មានលក្ខណៈបង្ហើរ។ វាជាឧបករណ៍កម្សាន្តមួយបែប ប៉ុន្តែ មានត្រណមមិនឱ្យផ្លុំន្ទូមលើផ្ទះក្នុងភូមិទេ។ ក្រោយពេលចប់ពិធី គេអាចទុកប្រើក្នុងពិធីលើកក្រោយ សែនព្រេនលើកក្រោយទៀត។

# ប

**បក្សីឋានសួគ៌** /បាក់-សី-ឋាន-សួ/ *ន.* ឈ្មោះស្មៅរឹងដូចដើមចេកមួយប្រភេទមាន ដើមកំណើតក្នុងប្រទេសអាហ្វ្រិកខាងត្បូង។ វាជារុក្ខជាតិលម្អផ្កា។ ឈ្មោះផ្កានេះ គេដាក់តាមរូបរាងផ្កាដែលមានលក្ខណៈដូចជាកូនបក្សីដ៏ស្រស់ស្អាត។

**បង្គោដំរី** /បង់-គោ-ដំ-រី/ *ន.* ឈ្មោះដើមឈើមួយដុះក្នុងព្រៃជ្រៅ, ឫសឈើនេះ ដុះពី គល់ចេញមកក្រៅដី មានទំហំធំណាស់ គេឱ្យឈ្មោះជាឫសជើងទោម ដែលគេ និយមយកមកប្រើសម្រាប់ធ្វើកង់រទេះគោ។ វាជាប្រភេទឈើល្អហើយជាប់បាន យូរ គេប្រើសម្រាប់សង់ផ្ទះ។ អ្នកខ្លះហៅឈើនេះថា *បង្កៃ*។

**បង្គោស៊ីផ្លែ** /បង់-គោ-ស៊ី-ផ្លែ/ *ន.* ឈ្មោះដើមឈើមួយប្រភេទដុះក្នុងព្រៃក្រាស់។ ផ្លែ វាតូចៗ មានរសផ្អែម គេចូលចិត្តបរិភោគណាស់។ ឈើអាចប្រើសម្រាប់សង់រោង បណ្ដោះអាសន្នបាន។ មែកជាងស្ងួតៗប្រើធ្វើឧសដុតឆេះល្អ។ អ្នកខ្លះហៅឈើ នេះថា *បង្កៃ* ឬ ហៅថា *ម្ទុល*។

**បង្វល់** /បង់-វ៉ល់/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់ឬព្រៃឈ្មោះលើដីមាន ថ្មច្រើន ឬ តាមមាត់អូរឬលើភ្លឺស្រែ។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក គេប្រើសម្រាប់ ធ្វើថ្នាំព្យាបាលកមរមាស់។

**បញ្ញាសជាតក** /ប៉ាញ់-ញ៉ា-សាក់-ជា-ដក់/ (បា. *បញ្ញាស* «ហាសិប» + *ជាតក* «រឿងរ៉ាវអតីតជាតិរបស់ព្រះពុទ្ធ») *ន.* ជាតកមួយប្រភេទដែលនិទានពីរឿងរ៉ាវ អតីតជាតិ៥០រឿងរបស់ព្រះពុទ្ធ។ ជាតកជាស្នាដៃរបស់អ្នកនិពន្ធពុទ្ធសាសនា នៅប្រទេសកម្ពុជា ប្រទេសថៃ ប្រទេសឡាវ និង ប្រទេសភូមា។ បណ្ដាឈ្មោះ រឿងទាំង៥០ដែលចេញពីប្រទេសទាំងបី មានតែ១៥ឈ្មោះទេដែលដូចគ្នា។ ឈ្មោះបញ្ញាសជាតកខ្មែរមាន ១. សមុទ្ទឃោស, ២. សុធនកុមារ, ៣. សុត្តធនុ, ៤. រតនប្បជោត, ៥. សិរីវិបុលកិត្តិ, ៦. វិបុលរាជ, ៧. សិរិចូឡាមណី, ៨. ចន្ទ-រាជ, ៩. សុភមិត្ត, ១០. សិរីធរសេដ្ឋី, ១១. សព្វសិទ្ធិ, ១២. ទុលកបណ្ឌិត, ១៣. អាទិត្តរាជ, ១៤. ទុកមានិក, ១៥. មហាសុរសេន, ១៦. សុវណ្ណកុមារ, ១៧. កនក-

រាជ, ១៨. វិរិយបណ្ឌិត, ១៩. ធម្មសោណ្ឌក, ២០. សុទស្សនមហារាជ, ២១. វត្តង្គុលីរាជ, ២២. បោរាណកបិលបុរនរិន្ទ, ២៣. ធម្មិកបណ្ឌិត, ២៤. មហាបុរិស, ២៥. ធម្មរាជ, ២៦. នរជីវ, ២៧. សុរូប, ២៨. មហាបទុមកុមារ, ២៩. ភណ្ឌាគារកុមារ, ៣០. ពហុលគាវី. ៣១. សេតបណ្ឌិត, ៣២. បុប្ផរាជ, ៣៣. ពារាណសិរាជ, ៣៤. ព្រហ្មឃោសរាជ, ៣៥. ទេវរុក្ខកុមារ, ៣៦. សលភ, ៣៧. សិទ្ធិសារ, ៣៨. នរជីវ, ៣៩. អតិទេវរាជ, ៤០. សិម្ពនាទ, ៤១. សុវណ្ណសង្ខរាជកុមារ, ៤២. សុវណ្ណ, ៤៣. ទេវន្ទ, ៤៤. សុវណ្ណកច្ឆប, ៤៥. សុបិនកុមារ, ៤៦. សុវណ្ណហង្ស, ៤៧. សិទ្ធិសារ (វរនុជវរនេត្រ), ៤៨. សិរីសរាជកុមារ, ៤៩. ចន្ទឃាត, ៥០. សទ្ធាតិស្សចក្កវត្តិ។

បញ្ញើក្អែកធំ /បាញ់-ញ៉ើ-ក្អែក-ធំ/ *ន.* ឈ្មោះគុម្ពព្រឹក្សផ្ញើប្រាណលើឈើធំៗក្នុងព្រៃក្រាស់។ តាមវេជ្ជសាស្ត្រក្បួនបុរាណ គេស្ងោរដើមនេះឱ្យនារីទើបសម្រាលកូនផឹក។

បណ្ដូលពេជ្រ /បន់-ដូល-ពិច/ *ន.* ឈ្មោះវល្លិរឹងមួយប្រភេទដុះក្នុងព្រៃក្រាស់ និងព្រៃល្បោះ។ ដើមមានរសល្វីងណាស់ គេប្រើសម្រាប់ជាថ្នាំផឹកឱ្យបរិភោគបាយបាននិងផឹកក្រោយ ពេលបាយដើម្បីឱ្យរលាយអាហារ។ គេច្រើនត្រាំដើមក្នុងស្រាជាថ្នាំលើកកម្លាំង។ តាមវេជ្ជសាស្ត្រក្បួនបុរាណ គេប្រើដើមផ្សំធ្វើជាថ្នាំរំងាប់រោគសន្លាក់ឆ្អឹង។ គេឆុងឫសផឹកព្យាបាលជំងឺគ្រុនចាញ់។

បន្ទូលឆត្រ /បន់-ទូល-ឆាត់/ *ន.* ឈ្មោះមេអុតទីមួយកើតនៅចំបន្ទូលក្បាល។

បន្លា(ដើម) /បន់-ឡា/ *ន.* ឈ្មោះចុល្លព្រឹក្សនាំពីប្រទេសអាម៉េរិកក្ដៅមកដាំជាលម្អ។

បន្លាក្បាលយក្ស /បន់-ឡា-ក្បាល-យាក់/*ន.* ចុល្លព្រឹក្សស្ទើរវារមួយប្រភេទដុះក្នុងព្រៃគុម្ពោត។ ផ្កាស្រស់ គេអាចបរិភោគជាបន្លែបាន។ ឈើដែលបុកឱ្យម៉ត់ គេយកឆ្អុងពេលមានរោគងេងងោងឬរឹងស៊ុង។

បន្លាមាស /បន់-ឡា-មាស/ *ន.* គុម្ពព្រឹក្សវារឡើងដើមឈើដុះក្នុងព្រៃធំឬក្នុងព្រៃចុល្លព្រឹក្ស។ ពេលខ្លះ គេដាំសម្រាប់ធ្វើរបង។

# ប

**បន្លាយក្ស** /បន់-ឡា-យាក់/ *ន.* គុម្ពព្រឹក្សមានបន្លាច្រើន មានកំណើតក្នុងប្រទេសអាម៉េរិកក្តៅ។ នៅអាស៊ីអាគ្នេយ៍ ដើមបន្លាយក្សដុះដេរដាលគ្រប់កន្លែង។ គុម្ពព្រឹក្សបន្លានេះច្រើនដុះលើដីសើមណាដែលគេកាប់ឈើអស់ឬជិតអស់, កន្លែងណាមានឈើច្រើន បន្លាយក្សពុំអាចដុះបានឡើយ។ ដើមនេះអាចប្រើជាជីស្រស់។ អ្នកខ្លះហៅបន្លានេះថា *ព្រះខ្លបយក្ស,* អ្នកខ្លះហៅថា *បន្លាយួន* ។

**បន្លាស្អិត** /បន់-ឡា-ស្អិត/ *ន.* វល្លិធំមួយប្រភេទមានមែករឹងដុះក្នុងព្រៃស្រោង។ ស្លឹកខ្ចីធ្វើបន្លែ ឬ របោយបាន, ផ្លែសម្រាប់លាងសក់, សំបកអាចស្ងោរជ្រលក់សំណាញ់។ ផ្លែគេប្រើជាថ្នាំច្រើនមុខណាស់ ដូចជា បូស ស្រែង ឃ្លង់ ជាដើម។ តាមវេជ្ជសាស្ត្របុរាណ គេផឹកទឹកត្រាំផ្លែធ្វើឱ្យទន់លាមក ផ្លែជាគ្រឿងផ្សំថ្នាំសម្រាប់ព្យាបាលជំងឺតម្រងទឹកនោម និង ប្លោកនោម, សាច់នៃគ្រាប់ ពេលប្រឡេះគ្រាប់ចោល ជាថ្នាំធ្វើឱ្យនោមច្រើន និង ប្រើជាថ្នាំធ្វើឱ្យក្អួត, គ្រាប់ជាថ្នាំ គេប្រើសម្រាប់សម្រួលការសម្រាលកូន។ អ្នកខ្លះហៅដើមនេះថា *បាយដំណើប, សំប៉ុយ* ឬ *សណ្តែកកំប៉ើយ* ។

**បណ្ណង្គជាតិ** /ប៉ាក់-ណង់-គៈ-ជាត/ *ន.* រុក្ខជាតិពួកមួយមានសន្លឹកទ្រុបទ្រុល, ច្រើនដុះក្រោមម្លប់លើភ្នំឬលើដីជាំទឹក មានមាត់ជ្រោះជាដើម។ វាជាប្រភេទរុក្ខជាតិមិនបន្តពូជដោយផ្កាឬគ្រាប់ទេ។ ឧទាហរណ៍ *ប៉ប្រ៉កជាបណ្ណង្គជាតិមួយប្រភេទ។*

**បរាភវសូត្រ** /ប៉ាក់-រ៉ា-ភាក់-វាក់-សូត/ *ន.* ឈ្មោះព្រះសូត្រមួយសម្តែងអំពីសេចក្តីវិនាស១២យ៉ាង។ ព្រះសូត្រនេះជាសំណួរចម្លើយរវាងទេវតានិងព្រះពុទ្ធសមណគោតម។

**ប៉ប្រើស ១** /ប៉-ប្រើស/ *ន.* ឈ្មោះវល្លិមានបន្លាមួយប្រភេទ វារឡើងឈើធំៗក្នុងព្រៃក្រាស់និងព្រៃស្រោងដុះលើដីថ្មលើភ្នំ។ ដើមប៉ប្រើសអាចប្រើធ្វើចំណងបាន។ តាមវេជ្ជសាស្ត្របុរាណ មើមវា គេយកត្រាំស្រាផឹកធ្វើជាថ្នាំលើកកម្លាំង។

# ប

**ប៉ប្រើស(វល្លិ)** ២ /ប៉-ប្រើស/ *ន.* វល្លិរឹងមួយប្រភេទវារឡើងមែកឈើក្នុងព្រៃក្រាស់លើភ្នំខ្ពស់។ ពន្លកមែកខ្ចីៗ គេអាចបរិភោគជាបន្លែបាន។ ដើម គេប្រើសម្រាប់ធ្វើខ្សែចងរបស់ផ្សេងៗ។

**បលិពោធ** /ប៉ាក់-លិ-ពោត/ *ន.* (បា.) គ្រឿងរារាំង, ការរារាំង, ឧបសគ្គ; កង្វល់។ (ព.ពុ.) បលិពោធ១៦ គឺ ១. អាភរណបលិពោធ *កង្វល់ដោយស្លៀកពាក់,* ២. អលង្ការបលិពោធ *កង្វល់ដោយតុបតែងកាយ,* ៣. កម្មារបលិពោធ *កង្វល់ដោយទាក់ទងនឹងជាងមាស,* ៤. មជ្ជនបលិពោធ *កង្វល់ដោយដុសខាត់រាងកាយ,* ៥. និក្ខិបនបលិពោធ *កង្វល់ដោយទុកដាក់ទ្រព្យធន,* ៦. ធោវនបលិពោធ *កង្វល់ដោយលាងសម្អាតទ្រព្យរបស់,* ៧. មាលាបលិពោធ *កង្វល់ដោយរកផ្កាមកក្រងតុបតែង,* ៨. គន្ធបលិពោធ *កង្វល់ដោយរកក្លិនក្រអូបមកអប់,* ៩. វាសនបលិពោធ *កង្វល់ដោយរកគ្រឿងអប់,* ១០. ហរិតកបលិពោធ *កង្វល់ដោយរកផ្លែសម៉មកប្រោះព្រំសក់,* ១១. អាមលកបលិពោធ *កង្វល់ដោយរកផ្លែកន្ទួតព្រៃមកប្រោះព្រំសក់,* ១២. មត្តិកបលិពោធ *កង្វល់ដោយរកដីមកផ្សំនឹងសម៉និងកន្ទួតព្រៃសម្រាប់ប្រោះព្រំសក់,* ១៣. សុចិកបលិពោធ *កង្វល់ដោយថ្ញៀបសក់,* ១៤. ពន្ធកបលិពោធ *កង្វល់ដោយ បួង ចង ក្រងសក់,* ១៥. កោច្ឆបលិពោធ *កង្វល់ដោយសិតសក់,* ១៦. កប្បកនហាបកបលិពោធ *កង្វល់ដោយកាត់សក់ឬលាងសក់* ។

**បាក់ដង** /បាក់-ដង/ *ន.* ឈ្មោះចុល្លព្រឹក្សឬព្រឹក្សតូចមួយប្រភេទដុះក្នុងព្រៃស្រោង។ ជ័រនៅចុងត្រួយសម្រាប់ធ្វើការបិទភ្ជាប់មុខនិងដងកាំបិត។

**ប៉ាងកាចាក់** /ប៉ាង-កា-ចាក់/ *ន.* ឈ្មោះដើមឈើមួយប្រភេទកម្ពស់ពី២៥ទៅ៣០ម៉ែត្រដុះក្នុងព្រៃជ្រៅ។ ឫសវាដុះពីគល់ចេញមកក្រៅដីមានទំហំធំៗ, គេឱ្យឈ្មោះជាឫសជើងទោម ដែលគេនិយមយកមកប្រើ សម្រាប់ធ្វើកង់រទេះគោ។ ឈើល្អហើយជាប់បានយូរ គេប្រើសម្រាប់សង់ផ្ទះ។

# ប

**ប៉ាងកាចាត** /ប៉ាង-កា-ចាត/ *ន.* ឈ្មោះស្មៅមួយប្រភេទ មែករឹងមានកម្ពស់ពី១ទៅ២ម៉ែត្រ មានដើមកំណើតក្នុងប្រទេសអាម៉េរិកកណ្ដាលខាងត្បូង, គេដាំជារុក្ខជាតិលម្អនៅទ្វីបអាស៊ី។ ស្លឹកវា គេអាចផុងផឹកដូចតែ។ តាមវេជ្ជសាស្ត្របុរាណគេយកស្លឹកមកផ្លុងដើម្បីឱ្យមានកម្លាំង និង សាច់មុខល្អ។ គ្រូថ្នាំតែងប្រើដើមនេះផ្សំជាមួយរុក្ខជាតិឯទៀតធ្វើថ្នាំបំបាត់គ្រុន។

**ប៉ាងផែក** /ប៉ាង-ផែក/ *ន.* ព្រឹក្សពួកមួយប្រភេទ មានកម្ពស់ពី២០ទៅ២៥ម៉ែត្រ មានសំបកពណ៌ក្រហមភាវ ដុះក្នុងព្រៃក្រាស់និងព្រៃល្បោះ។ សំបកក្រាស់ គេអាចទទួលទានម្លូជំនួសស្លាបាន។ ឈើសាច់ម៉ដ្ឋ ធ្ងន់ ពណ៌ត្នោត មានតម្លៃសម្រាប់ធ្វើជាសសរផ្ទះ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ព្រាលប្រើស*។

**ប៉ាតព្រុម** /ប៉ាង-ព្រុម/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទកម្ពស់ពី០.៥ទៅ១.៥០ម៉ែត្រ មានមែកទន់ល្មៀយពណ៌លឿង ដុះក្នុងព្រៃស្ងួត ព្រៃល្បោះ។ តាមវេជ្ជសាស្ត្របុរាណ គេផុងស្លឹកផឹកដើម្បីព្យាបាលឱ្យបាត់សក់សក្មេងៗ។

**បាយក្ដាំងស** /បាយ-ក្ដាំង-ស/ *ន.* (ម.ព. *ផ្កាម្កុលប្រាក់*។)

**បាយដំណើប** /បាយ-ដំ-ណើប/ *ន.* (ម.ព. *បន្ទាយក្ស*។)

**ប៉ិឆាយ** /ប៉ិ-ឆាយ/ *ន.* ឈ្មោះស្ពៃមួយប្រភេទមានដើមកំណើតនៅបណ្ដាប្រទេសនៅជុំវិញសមុទ្រម៉េឌីទែរ៉ាណេ។ គេនាំចូលមកដាំ ស្រុកចិនរាប់ពាន់ឆ្នាំហើយដោយកាត់តាមទ្វីបអាស៊ីខាងលិចឬប្រទេសម៉ុងហ្គោលី។ ស្ពៃនេះមានពូជច្រើន តែ នៅប្រទេសកម្ពុជា យើងអាចស្គាល់ពូជពីរច្រើនជាងគេ គឺ *ប៉ិឆាយ* (ហៅតាមជនជាតិចិននៅប្រទេសកម្ពុជា) និង *ស្ពៃចិន* ស្លឹកផែកៗ, *ស្ពៃចិន* ស្លឹកឥតផែក។

**ប៉ូចកាក់** /ប៉ូច-កាក់/ *ន.* ឈ្មោះឈើមួយប្រភេទកម្ពស់ពី៨ទៅ១០ម៉ែត្រ មានដើមកំណើតនៅប្រជុំកោះម៉ូលុក (Moluques) ប្រទេសឥណ្ឌូណេស៊ី។ គេនាំមកដាំនៅប្រទេសខ្មែរ និង វៀតណាមខាងត្បូង ជារុក្ខជាតិលម្អ។ តាមវេជ្ជសាស្ត្របុរាណ

**ប**

គេយកគ្រាប់ប្រើធ្វើជាថ្នាំ លើកកម្លាំង ព្យាបាលជម្ងឺក្រពះ, ព្យាបាលរាក។ ប្រេងនៃគ្រាប់ គេប្រើសម្រាប់រឹតសម្រាប់អ្នកមានជំងឺសន្លាក់ឆ្អឹង។

ប៉េះឡេះ /ប៉េះ-ឡេះ/ *ន.* បណ្ណង្គជាតិមួយប្រភេទកម្ពស់ពី០.៨ទៅ១.៥ម៉ែត្រ មានមែកអាចវារលើរុក្ខជាតិនៅជិត ដុះក្នុងព្រៃជំនៃអាស៊ីអាគ្នេយ៍។ គេយកស្លឹកខ្ចីៗធ្វើជាបន្លែទឹកគ្រឿង។

បាតប្រាំ /បាត-ប្រាំ/ *ន.* ឈ្មោះមេអុតទីប្រាំពីរកើតនៅបាតដៃ។

បាត់កូន /បាត់-កូន/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទមានរោមច្រើនដុះក្នុងព្រៃជ្រៅត្រជាក់។ ឈើគេនិយមប្រើសម្រាប់ធ្វើគ្រឿងផ្ទះ។

បាត់មាត់ /បាត់-មាត់/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទដុះក្នុងព្រៃក្រាស់។ ត្រួយវា គេអាចបរិភោគជាបន្លែបាន។ ឈើជាឈើប្រណីតលេខ៣មានពណ៌ក្រហមភាវ គេប្រើសម្រាប់ធ្វើគ្រឿងផ្ទះ ដូចជា ក្តារក្រាល ជញ្ជាំង គ្រោងទ្វារ បង្អួច។ល។

បាយកក /បាយ-កក/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃមាត់សមុទ្រ។ ផ្លែមានរាងមូលត្រមៀចតូចៗដុះជាចង្កោមជាកញ្ចុំៗ អាចបរិភោគបាន។

បាយដំណើប (វល្លិ) /បាយ-ដំ-ណើប/ *ន.* ចុល្លព្រឹក្ស ជួនកាល ជាវល្លិមានបន្លាច្រើន វារឡើងដើមឈើ។ វល្លិបានដំណើបច្រើនដុះនៅជុំវិញទន្លេសាបក្នុងវាល ដីខ្សាច់ដែលមានឧព្វេធទាបក្នុងប្រទេសកម្ពុជានិងប្រទេសសៀម។ ស្លឹកខ្ចីៗ គេយកធ្វើបន្លែឬរបោយបាន។ មែកជាង គេដុតជាឧស។

បាយទា /បាយ-ទា/ *ន.* បណ្ណង្គជាតិមួយប្រភេទដុះអណ្តែតក្នុងទឹកមិនហូរ ជារុក្ខជាតិមួយដុះរហ័ស។ បណ្ណង្គជាតិល្អិតនេះជាអាហារសម្រាប់សត្វទា។ គេយកវាធ្វើដីស្រស់ក៏បាន។

បាយភូវាំង /បាយ-ភូ-វាំង/ *ន.* ឈ្មោះឈើមួយ មានកម្ពស់ពី២៥ទៅ៣០ម៉ែត្រ ដុះក្នុងព្រៃជ្រៅនៃឥណ្ឌូចិន។ ឫសឈើនេះដុះពីគល់ ចេញមកក្រៅដីមានទំហំធំៗ

## ឞ

គេឱ្យឈ្មោះដាប្ញសជើងទោមដែលគេនិយមយកមកប្រើសម្រាប់ធ្វើកង់រទេះគោ។ ឈើល្អហើយជាប់បានយូរគេប្រើសម្រាប់សង់ផ្ទះ។

បាយរមាស /បាយ-រ-មាស/ *ន.* ចុល្លព្រឹក្សមួយប្រភេទ មានកម្ពស់ពី២ទៅ៥ម៉ែត្រ ដុះក្នុងព្រៃស្រោងនៃ ប្រទេសកម្ពុជា ប្រទេសឡាវ និង ប្រទេសវៀតណាមភាគខាងត្បូង។ ស្លឹកខ្ចីៗនិងផ្លែឆ្អិនហើយ គេអាចបរិភោគបាន។ ឈើ គេអាចប្រើធ្វើបង្គោលរបង។

បីសន្លឹក-អំព្រំ /បី-សន់-ឡឹក-អំ-ព្រំ/ *ន.* ចុល្លព្រឹក្សមួយពួក មានរោមច្រើន ដុះក្នុងព្រៃស្រោង ឬ តាមមាត់ផ្លូវមានថ្ម លើទួល។ ស្លឹកជាថ្នាំប្រើដោយពេទ្យសត្វសម្រាប់ព្យាបាលរបួសនៃបសុសត្វនានានិងសត្វដែលចិញ្ចឹមក្នុងផ្ទះ។

បូព្រឹក /បូ-ព្រឹក/ *ន.* ឈើមានកម្ពស់ពី៧ទៅ១៥ម៉ែត្រ ដុះក្នុងព្រៃជ្រុះស្លឹកនៃអាស៊ីក្ដៅ គេនិយមដាំដើមនេះជាលម្អ។ មានពូជរងមួយប្រភេទទៀតដុះឯងៗក្នុងព្រៃត្រដាក់ជើងភ្នំបូកគោ។ គេនិយមដាំពូជរងនេះក្នុងក្រុងធំៗជាលម្អ ដោយដើមនេះមានផ្កាក្រហមល្អមើល។ តាមវេជ្ជសាស្ត្របុរាណ ផ្លែវា គេទទួលទានប្រើជាថ្នាំបញ្ចុះ។ គ្រាប់វា គេអាចជំនួសស្លាបាន។ គេស្ងោរឈើឱ្យស្ត្រីទើបសម្រាលកូនផឹកជាថ្នាំលើកកម្លាំង។

បើស /បើស/ *ន.* គុម្ពដុះក្នុងព្រៃឈ្មោះនៃទ្វីបអាស៊ីក្ដៅ, គេដាំជាលម្អក្នុងសួន។ ដើមដែលមានឈ្មោះថា «ដើមធ្នុកដប» សម្រាប់ធ្វើកំសួលសន្ទូច ឬ ធ្វើក្រដាសធុនអន់ឬមួយសង់ទូកតូចៗ។ តាមវេជ្ជសាស្ត្របុរាណ គេស្ងោរស្លឹកលាងដំបៅ។ ស្លឹកអាចធ្វើថ្នាំបញ្ចុះបាន។

បើសសមុទ្រ /បើស-សៈ-ម៉ុត/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះ តាមមាត់សមុទ្រលើ ដីមានថ្មនៃប្រទេសក្ដៅ។ គេនិយមដាំដើមនេះជាលម្អ ដោយសារវាជារុក្ខជាតិមានស្លឹកច្រើននិងផ្កាលឿងធំៗ ហើយ ជាដើមឱ្យម្លប់។

# ប

បេឡើយ /បេ-ឡើយ/ *ន.* ឈ្មោះឈើមួយប្រភេទ មានកម្ពស់១៥ពី៣០ម៉ែត្រ ដុះក្នុងព្រៃធំនៃប្រទេសកម្ពុជានិងវៀតណាម។ ឈើមានពណ៌លឿងភាវគេទុកជាឈើលេខមួយសម្រាប់ សង់ផ្ទះ ឬ ធ្វើ តុ ទូ ជាដើម។

បេឡើយលឿង /បេ-ឡើយ-លឿង/ *ន.* ឈើមួយប្រភេទ មានកម្ពស់ពី២៥ទៅ៣០ម៉ែត្រ ដុះក្នុងព្រៃធំឬព្រៃល្បោះនៃប្រទេសកម្ពុជានិងប្រទេសវៀតណាមភាគខាងត្បូង។ ឈើមានពណ៌ដាំដែងភាវឬលឿងភាវ មានតម្លៃណាស់សម្រាប់ប្រើសង់ផ្ទះ។

បំពង់ប្រហុក /បំ-ពង់-ប្រ-ហុក/ ន. (ម.ព. *បេឡើយលឿង* ។)

បំពង់ស្រមោច /បំ-ពង់-ស្រ-ម៉ោច/ *ន.* គុម្ពព្រឹក្សមួយប្រភេទវារលើដើមឈើលើដីទំនាបមានខ្សាច់ក្នុងព្រៃល្បោះ ច្រើនដុះក្នុងខេត្តកំពង់ធំនៃប្រទេសកម្ពុជានិងប្រទេសវៀតណាមភាគខាងត្បូង។ បំពង់មានពីរយ៉ាង, បំពង់ខ្ចីមានសណ្ឋានប្រហែលស្ពៃរ បំពង់ចាស់មានរាងទ្រវែង។

បំពង់ស្រមោចកំពត /បំ-ពង់-ស្រ-ម៉ោច-កំពត/ *ន.* បំពង់ស្រមោចមួយប្រភេទមានកម្ពស់ប្រហែលមួយម៉ែត្រដុះលើដីសើមៗតាមមាត់ព្រៃធំលើដីទំនាបឬលើភ្នំ។ បំពង់រាងខ្លី តែ ធំជាងបំពង់នៅខេត្តកំពង់ធំ, គម្របមានធ្នូតៗខាងក្នុង។

បំពង់ស្រមោចពោធិ៍សាត់ /បំ-ពង់-ស្រ-ម៉ោច-ពោ-សាត់/ *ន.* បំពង់ស្រមោចមួយប្រភេទគ្មានរោម វារតោងឈើជិតខាង ដុះក្នុងវាលភក់ល្បាប់កណ្តាលព្រៃនៃខេត្តពោធិ៍សាត់ និង នៅប្រទេសវៀតណាមខាងត្បូង។ ស្លឹកគ្មានរោមមានទងសំប៉ាតរាងដូចស្លាប។ បំពង់មានពីរប្រភេទ បំពង់ខាងលើរាងដូចកូនដប, បំពង់ខាងក្រោមរាងជាបំពង់តូចៗ។ ភាគដែលលយចេញរាងដូចជរមានព្រុយៗ។

បំពាក់សក់ /បំ-ពាក់-សក់/ *ន.* ឈ្មោះចុល្លព្រឹក្សច្រើនក្លាយជាវល្លិ ដុះក្នុងព្រៃមាត់សមុទ្រនៃប្រទេសកម្ពុជានិងប្រទេសវៀតណាមភាគខាងត្បូង។ ផ្កាមានពណ៌លឿងភាវក្លិនក្រអូប, គេច្រើនប្រើដោតជាកម្រងឬសម្រាប់បំពាក់សក់នារីជាលម្អ។

# ប

ប្រែក /ប្រេក/ *ន.* ឈ្មោះឧបករណ៍ភ្លេងមួយប្រភេទតមានលក្ខណៈប្រហាក់ប្រហែលចាប៉ីដងវែង គឺ គេកេះដេញលើខ្សែតូចដើម្បីបញ្ចេញសូរបទនិងខ្សែធំមួយទៀតដើម្បីបញ្ចេញសូរកំដរ។ ពេលលេង គេផ្ទប់ប្រអប់សូរនឹងដើមទ្រូង។ ប្រអប់សូរធ្វើពីសំបកផ្លែឃ្លោកទុំស្ងួតដែលគេចងភ្ជាប់នឹងតួដងដោយខ្សែ។ នៅលើតួមានខ្ទង់ធ្វើពីឈើចំនួនប្រាបបិទនឹងក្រមួនសត្វម្រោម។ ដងខាងលើរាងត្រង់ធ្វើពីឫស្សីពកមានចោះរន្ធពីរធ្លាយពីម្ខាងទៅម្ខាងសម្រាប់ស៊កព្រលួតធ្វើពីឫស្សីចុះផ្នែកចុងខាងលើដង។ ដងក្រោមរាងអែនធ្វើពីឈើសម្រាប់ចងខ្សែ។ អ្នកលេងប្រែកច្រើនចេះច្រៀង គឺ គេកេះបណ្ដើរច្រៀងបណ្ដើរ។ វាជាឧបករណ៍តន្ត្រីកូតមួយប្រភេទពោលគឺ គេកូតដូចម៉ិម។ គេប្រើឆាកពីឫស្សី។ ជនជាតិគ្រឹងនិងទំពូន ខេត្តរតនគិរីហៅ *ប្រេក,* ជនជាតិព្រៅ ហៅ *ប្រ៊ែក*។

ប្រ៉ែក /ប្រ៉ាក់/ *ន.* ឈ្មោះគ្រឿងភ្លេងខ្សែមួយប្រភេទមានខ្សែតែមួយ។ ឆាកប្រ៉ែកធ្វើពីឫស្សីដូចម៉ិម តួស្រដៀងម៉ិម របៀបកូតក៏ដូចគ្នា តែ អំបោះចងផ្នែកខាងក្រោមបន្លាយមកមាត់ដោយចោះរន្ធស៊កអំបោះតាមសាច់ស្បែកក្របីដែលគេចិតរាងមូលដូចប្រាក់កាសនិងខាត់ឱ្យស្ដើងដូចក្រដាសសៀវភៅក្រាស់។ ជនជាតិភាគតិចចារាយ ខេត្តរតនគិរី ចាត់ទុកប្រ៉ែកជាមរតកមួយរបស់ខ្លួន។ គេស្ដាប់សូរតន្ត្រីនេះតាមបំពង់ពាសមុខមានចោះមុខស៊កកន្លាស់ឫស្សីតូចមួយចងអំបោះបន្លាយទៅភ្ជាប់តួរបស់ប្រ៉ែកក្រោមកន្លែងកូត។ សូរតន្ត្រីនេះរត់តាមខ្សែចូលទៅក្នុងបំពង់ស្ដាប់។ បំពង់ស្ដាប់នោះ គេយកឃ្លោកទុំមកធ្វើ។

ប្រក់ទឹក /ប្រក់-ទឹក/ *ន.* បណ្ណង្គជាតិមួយប្រភេទដុះក្នុងទីដីសើមមានភក់ល្បាប់នៃប្រទេសក្ដៅសកលលោក។ ស្លឹកខ្ចីៗ គេនិយមប្រើជាបន្លែបរិភោគជាមួយទឹកគ្រឿង។

ប្រង់ទឹក /ប្រង់-ទឹក/ *ន.* ឈ្មោះបណ្ណង្គជាតិមួយប្រភេទមានកម្ពស់ប្រហែល៥០សង់ទីម៉ែត្រដុះក្នុងទីដីសើមមានភក់ល្បាប់។ ស្លឹកខ្ចីៗ គេប្រើធ្វើជាបន្លែបរិភោគជាមួយទឹកគ្រឿង។

# ប

ប្រង់សមុទ្រ /ប្រង់-សៈ-ម៉ុត/ ន. ឈ្មោះរុក្ខជាតិមួយប្រភេទមានដើមរាងដូចដើមដូង មានកម្ពស់ប្រហែល១ម៉ែត្រ ដុះក្នុងព្រៃឈ្មោះមិនឆ្ងាយពីសមុទ្រ។ មើមមានជាតិម្យ៉ា, គេត្រូវស្ងោរយូរ ទើបបរិភោគបាន។ តាមវេជ្ជសាស្ត្របុរាណ គេប្រើមើមវាធ្វើថ្នាំរំងាប់រោគផ្សេងៗ ដូចជា ដំបៅរលួយ, រោគកូនកណ្ដុរ និង បូសទ្រនិច ជាដើម។

ប្រទាលជន្លាត់ដៃ /ប្រ-ទាល-ជន់-លាត់-ដៃ/ *ន.* ប្រទាលមួយប្រភេទមាន មែកបែកជាច្រើន មានបីជ្រុង មានបន្លា, គេដាំជារុក្ខជាតិលម្អ។ ជ័រវាមានជាតិពុលសម្រាប់ធ្វើថ្នាំបំបាត់សត្វល្អិតដោយលាយជាមួយថ្នាំដទៃ។ តាមវេជ្ជសាស្ត្របុរាណ ជ័រនេះសម្រាប់រំងាប់រោគឈឺធ្មេញនិងចុកពោះ។ បណ្ដូលដើមត្រាំក្នុងទឹកសម្រាប់ផឹកព្យាបាលគ្រុននិងរាកមួល។

ប្រទាលនាងស /ប្រ-ទាល-នាង-ស/ *ន.* ឈ្មោះស្មៅមួយប្រភេទងមានមើមដុះទទឹងដី។ ផ្លែមានរាងពងក្រពើមានប្រវែងប្រហែល២សង់ទីម៉ែត្រ ទទឹងពី១ទៅ១៥សង់ទីម៉ែត្រ មានបន្លាតូចៗដូចរោមវែងៗ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើគ្រាប់វាត្រាំស្រាសដើម្បីសម្រាប់ព្យាបាលជំងឺសន្លាក់ឆ្អឹង។ អ្នកខ្លះហៅដើមនេះថា *ដំឡូងគ្រឹង* ។

ប្រទាលបាយដំណើប /ប្រ-ទាល-បាយ-ដំ-ណើប/ *ន.* ឈ្មោះផ្កាអ័រគីដេមួយប្រភេទមានផ្កាជាចង្កោមវែងៗពណ៌ក្រហមក្រមៅមានតែមលឿង និង ភាគបកចេញក្រៅក្រហមភាវ។ នៅប្រទេសកម្ពុជា ប្រទាលនេះច្រើនធ្វើប្រាណលើគល់ត្នោតលើដីទំនាប។ គេនិយមយកដើមនេះមកដាំក្នុងផ្ទះជារុក្ខជាតិលម្អ។ តាមវេជ្ជសាស្ត្របុរាណ គេយកទឹកស្ងោរនៃប្រទាលនេះឱ្យក្មេងស្គមស្គាំងងូតឱ្យមានកម្លាំងឆាប់ធំធាត់។

ប្រទាលបូស /ប្រ-ទាល-បូស/ *ន.* គុម្ពព្រឹកស្ទើរវារដុះលើដីស្ងួតឬ នៅលើដីខ្សាច់មាត់ សមុទ្រ ឬ ក្នុងព្រៃគុម្ពោតបន្លានៃប្រទេសកម្ពុជា ប្រទេសថៃភាគខាងត្បូង

និង ប្រទេសវៀតណាមភាគខាងត្បូង។ តាមវេជ្ជសាស្ត្របុរាណ សំបកនិងឫស គេប្រើសម្រាប់ធ្វើថ្នាំបូស។ អ្នកខ្លះហៅប្រទាលនេះថា *ថ្នាប់*។

ប្រទាលផ្លិត /ប្រ-ទាល-ផ្លិត/ *ន.* រុក្ខជាតិជាស្មៅតូចមានដើមកំណើតក្នុងប្រទេសចិន ឬជប៉ុន, គេនាំយកមកដាំក្នុងអាស៊ីអាគ្នេយ៍សម្រាប់រុក្ខជាតិលម្អសួន។ តាមវេជ្ជសាស្ត្របុរាណខ្មែរ ឫសដើមនេះ គេយកធ្វើថ្នាំព្យាបាលរោគផ្សេងៗ ដូចជា បន្សាបពុលម្ហូបអាហារ, រំងាប់ជម្ងឺ បំពង់ក តឹងទ្រូង ឬ គ្រុន។ អ្នកខ្លះហៅប្រទាលនេះថា *ប្រទាលពានជញ្ជាំង*។

ប្រទាលពស់ថ្នាំ /ប្រ-ទាល-ពស់-ថ្នាំ/ *ន.* ដើមដំបងយក្សមួយប្រភេទវារលើរបងឬជញ្ជាំងមានមែករាងត្រីកោណដើមកំណើតពីប្រទេសអាម៉េរិក គេយកមកដាំក្នុងទ្វីបអាស៊ីជារុក្ខជាតិលម្អ។ ផ្កាស ក្លិនក្រអូប រីកពេលយប់។ ផ្លែ គេអាចបរិភោគបាន។ ពេលខ្លះ ផ្លែនេះមានលក់ក្នុងផ្សារ។

ប្រទាលពានជញ្ជាំង /ប្រ-ទាល-ពាន-ជញ់-ជាំង/ *ន.* (ម.ព. *ប្រទាលផ្លិត*។)

ប្រទាលរទេះជើងក្ដាម /ប្រ-ទាល-រ-ទេះ-ជើង-ក្ដាម/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទកម្ពស់២ទៅ៧ម៉ែត្រ ដុះក្នុងប្រទេសអាហ្វ្រិក, គេនាំមកដាំជារុក្ខជាតិលម្អក្នុងអាស៊ីអាគ្នេយ៍។ ជ័រមានជាតិពុលខ្លាំងអាចធ្វើឱ្យខ្វាក់ភ្នែក។ គេប្រើជ័រសម្រាប់សម្លាប់ កណ្ដុរ ឬ ក្ដាម ក្នុងស្រែ។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំខ្លះយកជ័រលាយជាមួយថ្នាំដទៃទៀតសម្រាប់រំងាប់រោគជាច្រើន ជាពិសេស រោគស្វាយ និង ជំងឺឈឺធ្មេញ។

ប្រទាលសេដ្ឋី /ប្រ-ទាល-សេត-ថី/ *ន.* តិណជាតិមួយប្រភេទដុះក្នុងប្រទេសម៉ាដាហ្គាស្កា, គេនាំមកដាំគ្រប់ប្រទេសក្នុងសកលលោកជារុក្ខជាតិលម្អ។ ប្រទាលនេះមានច្រើនប្រភេទ។ តាមជំនឿអរូបី ពេលដើមនេះផ្កា គេជឿថាម្ចាស់វាច្បាស់ជានឹងកើតទ្រព្យសម្បត្តិទៅជាសេដ្ឋី។

# ប

**ប្របួយ** /ប្រ-បួយ/ *ន.* ឈ្មោះចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៣ទៅ៤ម៉ែត្រ ស្ទើរវារ ឬ វារឡើងលើដើមឈើ ដុះក្នុងព្រៃនាមជុំវិញបឹងទន្លេសាប។ នៅប្រទេសដទៃក្នុងអាស៊ីអាគ្នេយ៍ ដើមនេះច្រើនដុះក្នុងព្រៃស្រោង។ ដើមគេសម្រាប់ធ្វើជន្លង់សណ្ដែកបណ្ដុះ។ តាមវេជ្ជសាស្ត្របុរាណ គេស្ងោរឫសផឹកដើម្បីឱ្យលាមកទន់។

**ប្រផុក** /ប្រ-ផុក/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទ កម្ពស់ ៨ទៅ១០ម ជ្រុះស្លឹកអស់ខែមករាទៅមេសា តែមានផ្កា ឬផ្លែពេញដើម។ ព្រឹក្សនេះដុះក្នុងកន្លែងណាដែលមានថ្ងៃក្នុងប្រទេសខ្មែរ និង ឡាវ។ ដើមទាំងមូលគេនិយមទុក ធ្វើទូកឱ្យក្មេងៗជិះលេង។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ប្រផោក* ។

**ប្រផ្ទី** /ប្រ-ផ្ទូ/ *ន.* គុម្ពព្រឹក្សស្ទើរវារ ពេលខ្លះដុះជាវល្លិធំប៉ុនម្រាមដៃលើទីវាល ឬ លើទួលដែលដីមានជាតិកំបោរឬជាតិថ្មដុសនៃអាស៊ីអាគ្នេយ៍។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំខ្មែរកាត់ដើមជាកង់ៗហើយស្ងោរធ្វើថ្នាំជំងឺគ្រុន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ម្រាមនាង* ។

**ប្រផោក** /ប្រ-ផោក/ *ន.* (ម.ព. *ប្រផុក* ។)

**ប្រមាត់ដីចិន** /ប្រ-ម៉ាត់-ដី-ចិន/ *ន.* ឈ្មោះតិណជាតិមួយប្រភេទ គល់រឹង ដុះលើដីសើមៗតាមមាត់ទឹក នៃប្រទេសកម្ពុជានិងវៀតណាមខាងត្បូង។ ស្លឹកមានរសល្វីងចត់។ ក្នុងការធ្វើម្ហូប ស្លឹកនេះ ជនជាតិខ្មែរនិយមបង់សម្លកកូរ។ ជនជាតិចិននៅប្រទេសកម្ពុជា ប្រើដើមនេះធ្វើថ្នាំព្យាបាលជំងឺទាក់ទងគ្រឿងរំលាយអាហារ។

**ប្រមាត់ថ្ម** /ប្រ-ម៉ាត់-ថ្ម/ *ន.* ស្មៅធ្មារមួយប្រភេទស្ទើរវារលើដី ដុះឫសតាមថ្នាំងដើម ដុះលើទីវាលត្រូវថ្ងៃនៃទ្វីបអាស៊ីផ្នែកក្ដៅ។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំខ្មែរប្រើដើមនេះធ្វើថ្នាំ គេកិនស្មៅនេះឱ្យម៉ត់ជាមួយទឹកហើយឱ្យអ្នកកើតរោគប្លើមផឹក។

**ប្រមាត់មនុស្ស (ដើម)** /ប្រ-ម៉ាត់-មៈ-នុស/ *ន.* (ម.ព. *រំលាយស្នួង* ។)

**ប្រមាត់មនុស្ស (ស្មៅ)** /ប្រ-ម៉ាត់-មៈ-នុស/ *ន.* (ម.ព. *ផ្ទុះ* ។)

# ប

ប្រមោញ /ប្រ-ម៉ោញ/ *ន.* សត្វមានរូបរាងដូចប្រមាតែមាឌតូចជាងប្រមា រោមមានប្រវែងខ្លីជាងប្រមា ផ្នែកខាងលើដងខ្លួនមានកាំរាងសំប៉ែត ផ្នែកក្រោមពោះមានរោមខ្លីពណ៌ត្នោតខ្ចី កន្ទុយតូច ហើយ នៅចុងកន្ទុយមានកញ្ចុំរោមដូចអំបោះ។

ប្រមោញស្វា /ប្រ-ម៉ោញ-ស្វា/ *ន.* ឈ្មោះបណ្ណង្គជាតិមួយប្រភេទច្រើនដុះក្នុងព្រៃភ្នំបូកគោ។ ពេលខ្លះ គេដាំប្រមោញស្វាជាដើមលម្អសួន។

ប្រលាស់ព្រះ /ប្រ-លាស់-ព្រះ/ *ន.* ឈ្មោះគុម្ពព្រឹក្សមួយប្រភេទដុះក្នុងព្រៃស្រោងនៃប្រទេសកម្ពុជា។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំយកឫសដើមនេះផ្សំធ្វើថ្នាំព្យាបាលដំណើរបាក់ឆ្អឹង។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ព្រាលខ្សាច់*។

ប្រសាក់ញី /ប្រ-សាក់-ញី/ *ន.* រុក្ខជាតិមួយប្រភេទមានកម្ពស់ពី១០ទៅ២៥ម៉ែត្រដុះក្នុងព្រៃកោងកាង ឬ ព្រៃមាត់ព្រែកមានទឹកប្រៃលើដីល្បាប់ សម្រាប់ឱ្យឫសចេញ ពីមែក(ទៅក្រៅដី)អាចដុះបាន។ ប្រសាក់ញីដុះមាត់សមុទ្រគ្រប់ប្រទេសក្នុងសកលលោក។ ឈើសាច់ម៉ត់ ពណ៌ក្រហម, គេនិយមប្រើធ្វើផ្ទះមាត់សមុទ្រឬធ្វើស្ពាន របង រោងនេសាទ។ល។ ពេលគេដុត ដើមនេះអាចទៅជាធ្យូងល្អណាស់។ សំបកសម្រាប់ជ្រលក់សំណាញ់នេសាទ ឬ សម្លាប់ស្បែកសត្វ។ តាមវេជ្ជសាស្ត្របុរាណ គេស្ងោរសំបកផឹកឱ្យបាត់រាក។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ប្រសាក់តូច* ឬ *ប្រសាក់ទឹក*។

ប្រសាក់តូច /ប្រ-សាក់-តូច/ *ន.* (ម.ព. *ប្រសាក់ញី*។)

ប្រសាក់ទឹក /ប្រ-សាក់-ទឹក/ *ន.* (ម.ព. *ប្រសាក់ញី*។)

ប្រសាក់ធំ /ប្រ-សាក់ធំ/ *ន.* (ម.ព. *ផ្លោង*។)

ប្រាក់កាក់ /ប្រាក់-កាក់/ *ន.* វល្លិប្រាក់កាក់ជាវល្លិឆ្មារធ្វើប្រាណលើដើមឈើក្នុងព្រៃល្បោះនៅអាស៊ីនិងអូស្ត្រាលីក្តៅ។ វល្លិនេះចាក់ឫសភ្ជាប់ដូចកៅស៊ូទៅលើដើមឈើ។ គេនិយមដាំវល្លិប្រាក់កាក់ជិតផ្ទះជាលម្អ។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំប្រើ

វល្លិប្រាក់កាក់ផ្សំជាមួយរុក្ខជាតិដទៃទៀតធ្វើឱសថសម្រាប់លើកកម្លាំងនិង ព្យាបាលជំងឺអុត។

**ប្រាក់ដំឡើង** /ប្រាក់-ដំ-ឡើង/ *ន.* ឈ្មោះព្រឹក្សមួយប្រភេទមានកម្ពស់ពី១០ពី១៥ ម៉ែត្រ, ទំហំជុំវិញអាចធំដល់៣ម៉ែត្រ, ដុះក្នុងព្រៃស្រោងឬក្រាស់មធ្យមនៅឧបទ្វីបឥណ្ឌូចិន។ ឈើប្រណីត គេសម្រាប់ ធ្វើសសរផ្ទះ និង ធ្វើ តុ ទូ ជាដើម។

**ប្រុញស្វា** /ប្រុញ-ស្វា/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៦ទៅ១០ម៉ែត្រ ច្រើនដុះក្នុងព្រៃក្រាស់តាមមាត់ទឹក លើដីរាប ឬ ទួលមិនខ្ពស់ហួសពី៦០០ម៉ែត្រ។ ស្លឹកខ្ចីអាចធ្វើអន្លក់ឬរបោយបាន, ផ្លែក៏អាចបរិភោគដែរ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *អង្កាញ់ស្វា* ។

**ប្រេងខ្យល់ស្លឹកតូច** /ប្រេង-ខ្យល់-ស្លឹក-តូច/ *ន.* រុក្ខជាតិមួយប្រភេទ ស្លឹកល្អិតពេលដើមចាស់ដុះរហ័ស មានដើមកំណើតមិនប្រាកដ ឬ ក្នុងប្រទេសអូស្ត្រាលី ឬ ប្រទេសណូវែលហ្គីណេ។ នៅប្រទេសកម្ពុជា គេច្រើនដាំក្នុងរមណីយដ្ឋាននិងតាមវិថី។ ដើម គេអាចប្រើសង់ផ្ទះ។

**ប្រេងខ្យល់ស្លឹកស** /ប្រេង-ខ្យល់-ស្លឹក-ស/ *ន.* ប្រេងខ្យល់មួយប្រភេទ មានដើមកំណើតក្នុងប្រទេសអូស្ត្រាលី, ក្នុងប្រទេសនេះ ប្រេងខ្យល់ស្លឹកសដុះជាព្រៃធំលិចទឹកមួយដង ឬ ច្រើនដងក្នុងមួយឆ្នាំ។ ព្រៃប្រេងខ្យល់ប្រភេទនេះដុះលើដីទំនាប ពុំអាចឡើងលើភ្នំខ្ពស់លើស៦០០ម៉ែត្រឡើយ។ នៅប្រទេសកម្ពុជា គេច្រើនដាំក្នុងរមណីយដ្ឋាននិងតាមវិថី។ ដើមនេះដុតឆេះឥតឬស្ទើរគ្មានសល់ផេះឡើយ។ ឈើ គេអាចប្រើសង់ផ្ទះ។

**ប្រាំតម្លឹង** /ប្រាំ-តំ-ឡឹង/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃស្រោងលើដីមានថ្ម។ ដើមវា គេប្រើធ្វើជាសសរផ្ទះ, សំបកវា គេអាចប្រើជាថ្នាំលាបសំណាញ់នេសាទឱ្យមានពណ៌ប្រផេះ។ អ្នកខ្លះហៅឈើនេះថា *ព័ន្ធលៃ* ។

# ផ

ផោម /ផោម/ *ន.* រុក្ខជាតិមួយប្រភេទជាវល្លិវារលើដើមឈើ។ ស្លឹកខ្ចីមានក្លិនស្អុយ អាចបរិភោគជាបន្លែបាន។ តាមវេជ្ជសាស្ត្របុរាណ មែកនិងស្លឹកចាស់ប្រើផ្សំជាថ្នាំទំលាក់ព្រូន, ស្លឹកបុកធ្វើឱសថបំពោកសម្រាប់ព្យាបាលជំងឺភ្លាត់ឆ្អឹងបាន។

ផ្កាក្រម្ងួន /ផ្កា-ក្រ-មួន/ *ន.* ចុល្លព្រឹក្សមួយប្រភេទ គេដាំដើម្បីលម្អ។ ជ័រនិងគ្រាប់មានជាតិពុល ប៉ុន្តែ នៅកោះជ្វា គេប្រើដើមនិងសំបកធ្វើជានុយត្រី ដើម្បីឱ្យត្រីស្រវឹង។ អ្នកខ្លះហៅ *យិតថោបារាំង* ។

ផ្កាច័នព្រៃ /ផ្កា-ចាន់-ព្រៃ/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះភាគច្រើននៅលើភ្នំបូកគោ។ ផ្លែមានសារជាតិពុល ហើយ ស្លឹកខ្ចីៗ និង សំបក, អ្នកស្រុករស់នៅតាមជើងភ្នំបូកគោមុនឆ្នាំ១៩៧០ ប្រើជាថ្នាំព្យាបាលដំបៅ។

ផ្កាចាន់ភ្នំ /ផ្កា-ចាន់-ភ្នំ/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃធំដុះលើភ្នំបូកគោក្នុងព្រៃតឿ។ ផ្កាវាមានពណ៌ក្រហមក្រមៅ ក្លិនដូចផ្កាចាន់ គេច្រើនដាក់លម្អក្នុងផ្ទះតែ ផ្លែវាមានជាតិពុល។

ផ្កាចិញ្ចៀន /ផ្កា-ចិន-ជៀន/ *ន.* គុម្ពព្រឹក្សមួយប្រភេទដុះស្ទើរវារ។ តាមតំបន់ខ្លះ វាដុះលឿនពេក ត្រូវបានគេបំផ្លាញចោលវិញ ប៉ុន្តែ តំបន់ខ្លះទៀត វាដុះយឺត ក៏ត្រូវបានគេដាំដើម្បីលម្អ។

ផ្កាឈាមអន្ទង់ /ផ្កា-ឈាម-អន់-ទង់/ *ន.* (ម.ព. *កាំរទេះ* ។)

ផ្កាដង្កូវ /ផ្កា-ដង់-កូវ/ *ន.* រុក្ខជាតិមួយប្រភេទជាវល្លិវារឡើងទ្រើងមានប្រភពមកពីអាម៉េរិកខាងត្បូង។ ផ្កាមានក្លិនក្រអូប, ពណ៌ស, ដុះជាចង្កោមរាងមូលៗក្រញុលៗដូចដង្កូវ។

ផ្កាតាំងយូ /ផ្កា-តាំង-យូ/ *ន.* (ម.ព. *កំពីងពួយគោក* ។)

ផ្កាត្រៃ /ផ្កា-ត្រៃ/ *ន.* រុក្ខជាតិមួយប្រភេទប្រភេទជាវល្លិវារអាស្រ័យរុក្ខជាតិដទៃ មានកំណើតនៅអាម៉េរិកខាងត្បូង។ ផ្កាវាមានពណ៌លឿងរាងដូចត្រៃ។ តាមវេជ្ជសាស្ត្រ

បុរាណ ស្លឹក គេប្រើជាថ្នាំបញ្ចុះ ហើយ ដំរក៏ប្រើជាថ្នាំបញ្ចុះដូចគ្នា តែ មានប្រសិទ្ធភាពខ្លាំងជាងស្លឹក។ អ្នកខ្លះហៅផ្កានេះថា *វល្លិយាយហុក* ។

ផ្កាត្រែតូច /ផ្កា-ត្រែ-តូច/ រុក្ខជាតិមួយប្រភេទដូចផ្កាត្រែដែរ តែ តូចជាង។ តាមវេជ្ជសាស្ត្របុរាណ គេថ្នាំយកស្លឹកវាទៅស្ងោរឱ្យអ្នកទល់លាមកបរិភោគ, ដំរវាក៏ជាថ្នាំបញ្ចុះដូចស្លឹកវាដែរ។

ផ្កាថ្មី /ផ្កា-ថ្ម/ *ន.* តិណជាតិមួយប្រភេទនៅដីសំបូរថ្មនិងដីស្ងួត។ ដើមវា គេប្រើធ្វើជាចំណីជ្រូក។ តាមវេជ្ជសាស្ត្របុរាណ គេថ្នាំបុរាណប្រើផ្កាថ្មជា ឱសថព្យាបាលបូសទ្រនិច។ អ្នកខ្លះហៅតិណជាតិនេះថា *ស្មៅស្លាបទា* ។

ផ្កាទុំហូ /ផ្កា-ទុំ-ហ៊ូ/ *ន.* តិណជាតិមួយប្រភេទសម្រាប់ដាំលម្អ។ ផ្កាវា មានរាងជាគោមនិងពណ៌ក្រហម ហើយ ស្រីៗចូលចិត្តយកមកសៀតត្រចៀកលេង។

ផ្កាពងត្រី /ផ្កា-ពង-ត្រី/ *ន.* វល្លិធំមួយប្រភេទមានផ្កាពណ៌លឿងធំៗមានប្រភពពីប្រទេសអូស្ត្រាលី។ វាជាប្រភេទរុក្ខជាតិដែលគេដាំដើម្បីលម្អផ្ទះ ឬ លើរបងផ្ទះជាដើម។

ផ្កាម៉ោងដប់ /ផ្កា-ម៉ោង-ដប់/ *ន.* តិណជាតិមួយប្រភេទមានប្រភពពីទ្វីបអាម៉េរិក។ គេនិយមដាំលម្អក្នុងសួន ព្រោះ វាមានពណ៌ស្រស់និងច្រើនពណ៌ដូចជា ក្រហម លឿង ផ្កាឈូក និង ពណ៌ស។ ផ្កាមានច្រើនស្រទាប់, ស្លឹកទោលក្រាស់វែងស្រួចចុង។ តាមវេជ្ជសាស្ត្របុរាណ គេបុកបិតលើ បូស, ពិស, ស្នាមមុត, កន្លែងរលាកភ្លើង ជាដើម។

ផ្កាម៉ោងបួន /ផ្កា-ម៉ោង-បួន/ *ន.* តិណជាតិមួយប្រភេទស្ទើរវារលើដីមានប្រភពមកពីប្រទេសម៉ិចស៊ីកូ។ គេនិយមដាំលម្អក្នុងសួន។ ប្រភេទផ្កាមាន ពណ៌ស្វាយ ពណ៌ស ពណ៌ផ្កាឈូក និង ពណ៌លឿង ជាដើម, ស្លឹកទោលជាងជាផ្លែលំពែង, ផ្លែទុំមានពណ៌ខ្មៅ។ តាមវេជ្ជសាស្ត្របុរាណ គេបុកស្លឹកវា ហើយបំពោកលើខ្នងអ្នកជំងឺគ្រុន មុនពេលគក់ប្រចាំ។

# ផ

**ផ្កាម្នុលប្រាក់** /ផ្កា-ម្នុល-ប្រាក់/ *ន.* គុម្ពព្រឹក្សមួយប្រភេទផ្កាម្នុលពេជ្រមានកម្ពស់១ទៅ៣ម៉ែត្រ ដុះលើដីវាលក្នុងភូមិនៅ ប្រទេសឡាវ, វៀតណាមភាគខាងត្បូង និងប្រទេសកម្ពុជា។ អ្នកខ្លះហៅផ្កានេះថា *បាយក្តាំងស*។

**ផ្កាម្នុលពេជ្រ** /ផ្កា-ម្នុល-ពិច/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពស់១ទៅ១០ម៉ែត្រដុះក្នុងព្រៃធំនៅអាស៊ីអាគ្នេយ៍។ ផ្កាពណ៌សមានរាងដូចម្នុល គេអាចដាំក្នុងផើងឬក្នុងសួនដើម្បីលម្អ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើស្លឹកជាឱសថ ព្យាបាលជំងឺរាគមួល និង ស្ងោរឱ្យស្ត្រីទើបសម្រាលរួចផឹកជាថ្នាំកម្លាំង។

**ផ្កាយព្រឹក** /ផ្កាយ-ព្រឹក/ *ន.* រុក្ខជាតិមួយកម្ពស់ខ្ពស់ប្រភេទដុះនៅតាមមាត់សមុទ្រនិងព្រៃស្នាច់។ ផ្លែវាមានលក្ខណៈជាគ្រាប់ដុះក្នុងស្រោមជាសំបកដូចសំបកនៃផ្លែប្រភេទឈើពួកកកោះ, គ្រាប់ខ្មៅរាងសំប៉ែត, ផ្កាមានពណ៌ស។ វាជាប្រភេទឈើប្រណីតមានតម្លៃដែលគេប្រើសម្រាប់ធ្វើជាគ្រឿងសង្ហារិមនិងសង់អគារមានធ្វើកម្រាលក្តារជាដើម ជាដើម។ ឈ្មោះផ្កានេះប្រហែលគេដាក់តាមទម្រង់ផ្កាពណ៌របស់វា។ ផ្កាពណ៌សនេះវិវត្តជាពណ៌រាងស្វាយ។

**ផ្កាស្មៅ** /ផ្កា-ស្មៅ/ *ន.* (ម.ព. *ផ្កាអាចម៍កុក*។)

**ផ្កាស្លឹកក្រហម** /ផ្កា-ស្លឹក-ក្រហម/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានប្រភពមកពីប្រទេសម៉ិចស៊ីកូ។ វាជាផ្កាដាំក្នុងផើងសម្រាប់លម្អ, ផ្កាមានពណ៌ក្រហមនិងពណ៌លឿងស្អាត។

**ផ្កាហួយ** /ផ្កា-ហួយ/ *ន.* (ម.ព. *ក្របក*។)

**ផ្កាអណ្តាតនាគ** /ផ្កា-អន់-ដាត-នាក/ *ន.* (ម.ព. *ក្រដាសតូច*។)

**ផ្គរផ្តាំក្តាមខ្យង** /ផ្គ-ផ្តាំ-ក្តាម-ខ្យង/ *ន.* ផ្គរចុងខែអស្សុជឬដើមខែកត្តិកនាពេលអធ្រាត្រមានសូរស្រាលបង្អួសយ៉ាងវែង ឮពីទិសនិរតីឬទក្សិណ។ មុនដំបូងឮជិត ប៉ុន្តែ សំឡេងឮកាន់តែតិចទៅៗរហូតបាត់សំឡេងតែម្តង។

# ផ

**ផ្ទឹកភ្នំ** /ផ្ទឹក-ភ្នំ/ *ន.* (ម.ព. *កំឡៀង។*)

**ផ្កាអាចម៍កុក** /ផ្កា-អាច់-កុក/ *ន.* ឈ្មោះស្មៅរឹងមួយប្រភេទមានប្រភពក្នុងទ្វីបអាម៉េរិកក្តៅ។ តិណជាតិនេះច្រើនដុះតាមមាត់ផ្លូវនិងក្បែរផ្ទះអ្នកស្រុក។ តាមវេជ្ជសាស្ត្របុរាណ គេត្រាំគ្រាប់ឱ្យក្លាយជាទឹកដមកកសម្រាប់បំពោកលើស្នាមរបួសផ្សេងៗនិងលើបូសទ្រនិចជាដើម។ អ្នកខ្លះហៅផ្កានេះថា *ផ្កាស្មៅ*។

**ផ្ទឹកឧត្តម** /ផ្ទឹក-អ៊ុត-ដំ/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃធំៗនិងព្រៃល្បោះ។ ដើមវាជាប្រភេទឈើល្អមធ្យម គេសម្រាប់ធ្វើសម្ភារៈប្រើប្រាស់ធម្មតានិងសង់ផ្ទះ។ ជ័រវាគេប្រើសម្រាប់បិទនៀវនាវា ហើយ ក៏អាចលាយជាមួយបាយជ្រូកដើម្បីឱ្យជ្រូកញីអារ។ អ្នកខ្លះហៅដើមនេះថា *ខ្ទូរ*។

**ផ្គៀកក្រហម** /ផ្គៀក-ក្រ-ហម/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃជ្រុះស្លឹកលើដីទំនាបឬភ្នំទាបៗ។ វាត្រូវបានគេនិយមដាំនៅលើដីសណ្ត តាមដងទន្លេមេគង្គនិងឧបទ្វីបម៉ាឡេ។ ដើមមានពណ៌ត្នោតឬត្នោតលឿង សាច់រឹងមធ្យម, គេប្រើសម្រាប់សង់ផ្ទះធន់បានពី៧ទៅ៨ឆ្នាំ ហើយ អាចសង់នាវាធន់បានរហូតដល់៣០ឆ្នាំ។ ឯជ័រវា គេប្រើជាថ្នាំលាបឱ្យរលោងមានតម្លៃថ្លៃ។ អ្នកខ្លះហៅឈើនេះថា *គគីរដែក*។

**ផ្ទក់ក្រហម** /ផ្ទក់-ក្រ-ហម/ *ន.* តិណជាតិមួយប្រភេទដុះលើដីវាលក្នុងព្រៃធំៗ។ ទងស្លឹកវាបែកមែកសង្ខាងដូចស្លាប។ គេមានឃើញមានដុះច្រើននៅស្រុកក្បែរអង្គរនិងឧត្តុង្គ។ អ្នកខ្លះគាស់យកទៅដាំដើម្បីលម្អផ្ទះ ដោយសារសម្រស់ផ្ការបស់វា។

**ផ្គៀកស-ក្រហម** /ផ្គៀក-ស-ក្រហម/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី២០ទៅ៣៥ម៉ែត្រ ដុះក្នុងព្រៃធំត្រជាក់លើដីរាបនៅតំបន់អាស៊ីអាគ្នេយ៍។ ជ័រវាមានក្លិនក្រអូបពណ៌ស គេប្រើសម្រាប់ធ្វើចន្លុះនិងលាបទូក, ឯដើម គេប្រើសម្រាប់សង់ផ្ទះនិងគ្រឿងសង្ហារិម។

# ផ

ផ្អក់ស /ផ្អក់-ស/ *ន.* តិណជាតិមួយយ៉ាងដុះតាមទីវាលកណ្ដាលព្រៃភ្នំ, ស្លឹកវាវែងៗល្អគ្មានទងនិងមានផ្កាពណ៌ស, គេច្រើនដាំវាជារុក្ខជាតិលម្អ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើវាជាថ្នាំព្យាបាលជំងឺគ្រុន និង សន្លាក់ឆ្អឹង។

ផ្អល់ /ផ្អល់/ *ន.* ឈើមួយប្រភេទមានកម្ពស់១៥ទៅ២០ម៉ែត្រ ដុះតាមព្រៃរបោះមាត់ទឹកនិងព្រៃនាមក្នុងប្រទេសកម្ពុជា, សំបូរដុះនៅខេត្តក្រចេះ។ គេច្រើនយក ដើមវាធ្វើជារបស់លេងនិងធ្វើសំណាក។ អ្នកខ្លះហៅដើមនេះថា *អាចម៍កណ្ដុរ* ។

ផ្អុះ (ស្មៅ) /ផ្អុះ/ *ន.* ស្មៅមួយប្រភេទដុះតាមជងផ្លូវនិងតាមទីវាលក្នុងប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍។ ឫសនិងដើមវាមានរសចត់។ តាមវេជ្ជសាស្ត្របុរាណ, គេប្រើសារជាតិនេះសម្រាប់បន្សាបការពុលអាហារដោយក្អួតឬបញ្ចុះចេញ។ ឫសស្ងួត គេអាចត្រាំស្រាសផឹកឱ្យបរិភោគបាយបាន។ អ្នកហៅដើមនេះថា *ស្មៅប្រមាត់មនុស្ស* ។

ផ្លង់ /ផ្លង់/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃស្រោងនៃឥណ្ឌូចិន ឥណ្ឌា ចិន និងហ្វីលីពីន។ ផ្លែបរិភោគបាន ឯមែក និង ឫស បុកលាយ ស្រាស ឱ្យក្រអូប។ ស្លឹកធុងផឹកសម្រាប់ស្ត្រី ទើបសម្រាលកូនរួចដើម្បីបរិភោគបាយបាន។ អ្នកហៅដើមនេះថា *ភ្លាំង* ។

ផ្លាង /ផ្លាង/ *ន.* ឈ្មោះឈើមួយប្រភេទព្រឹក្សដែលមានកម្ពស់ពី៤ទៅ២០ម៉ែត្រដុះក្នុងព្រៃជ្រៅនៅចុងបូព៌ាប្រទេស។ មែកជាងនិងស្លឹក គេប្រើសម្រាប់ស្ងោរ លាងដំបៅនិងរបួស, ឯដើមវា គេប្រើសម្រាប់សង់រោងផ្សេងៗ។ តាមវេជ្ជបុរាណ រុក្ខ-ជាតិនេះប្រយោជន៍ច្រើនក្នុងការព្យាបាលរោគជាច្រើនទៀត។

ផ្ដុង /ផ្ដុង/ *ន.* ចុល្លព្រឹក្សមួយប្រភេទកំពស់៦ទៅ១២ម៉ែត្រក្នុងព្រៃធំឬព្រៃល្បោះនៅប្រទេសឥណ្ឌា កម្ពុជា វៀតណាមខាងត្បូង និង កោះជ្វា។ សំបក គេវេញធ្វើខ្សែ ឯដើមគេធ្វើជាគ្រឿងសង់ផ្ទះរាយរង។

# ផ

ផ្លោង /ផ្លោង/ *ន.* ឈើមួយប្រភេទកម្ពស់ពី២០ទៅ៣០ម៉ែត្រឫសដុះជាចន្ទល់ជាជើងទោម និង ឫសដែលដុះចេញពីដីល្បាប់មានរាងដូចទំពាំងហើយមានតួនាទីជួយឱ្យដើមមានអុកស៊ីសែន។ វាច្រើនដុះក្នុងព្រៃកោងកាង តាមសមុទ្រនៅប្រទេសក្ដៅ។ សំបក គេប្រើសម្លាប់ស្បែកឬជ្រលក់សំពត់និងសំណាញ់នេសាទជាដើម។ អ្នកហៅឈើនេះថា *ប្រសាក់ធំ* ។

ផ្គុងក្រហម /ផ្គុង-ក្រ-ហម/ *ន.* (ម.ព. *ផ្គុងគោក* ។)

ផ្គុងគោក /ផ្គុង-គោក/ *ន.* ឈើមួយប្រភេទមានកម្ពស់ប្រហែលពី១០ទៅ៣០ម៉ែត្រដុះក្នុងព្រៃជ្រៅលើភ្នំ និង ទំនាប នៃប្រទេសកម្ពុជានិងវៀតណាម។ ដើមដុះត្រង់ល្អ, គេច្រើនដាំតាមដងផ្លូវឬសួនដើម្បីលម្អនិងជាម្លប់។ ដើមធន់ល្អ គេអាចប្រើធ្វើទូកកប៉ាល់ផ្សេងៗបាន។ អ្នកខ្លះហៅឈើនេះថា *ផ្គុងក្រហម* ។

ផ្គុងខ្ទឹង /ផ្គុង-ខ្ទឹង/ *ន.* ឈើមួយពួកមានកម្ពស់១៥ទៅ២៥ម៉ែត្រ ដុះក្នុងព្រៃក្រាស់លើខ្នងភ្នំ និង លើដីល្បាប់ដែលមានខ្សាច់នៅឥណ្ឌូចិន។ ដើមធន់ល្អសម្រាប់សង់ផ្ទះ នាវានិងធ្វើឈើមុខតំណជាដើម។

ផ្គុងដាំ /ផ្គុង-ដាំ/ *ន.* (ម.ព. *ផ្គុងដាំ* ។)

ផ្គុងតូច /ផ្គុង-តូច/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់២ទៅ៣ម៉ែត្រ ដុះនៅព្រៃក្រាស់លើដីល្បាប់ក្នុងតំបន់អាស៊ីអាគ្នេយ៍។ មែកធាង គេប្រើសម្រាប់ធ្វើអំបោស។ ដើមប្រើសម្រាប់សងរោងឬខ្ទមជាដើម។ អ្នកខ្លះហៅឈើនេះថា *ផ្គុងដាំ* ។

ផ្គុងធំ /ផ្គុង-ធំ/ *ន.* (ម.ព. *ផ្គុងព្រៃ* ។)

ផ្គុងព្រៃ /ផ្គុង-ព្រៃ/ *ន.* ឈើមួយប្រភេទមានកម្ពស់១៥ទៅ២០ម៉ែត្រ ដុះក្នុងព្រៃធំត្រជាក់នៅអាស៊ីក្ដៅ។ ដើមធន់មាំល្អ ជាប្រភេទឈើលេខបី។ គេប្រើវាសម្រាប់ធ្វើគ្រឿងសង្ហារិម។ អ្នកខ្លះហៅឈើនេះថា *ផ្គុងធំ* ។

# ផ

**ផ្ទុងភ្នំ** /ផ្ទុង-ភ្នំ/ *ន.* ឈើមួយប្រភេទកម្ពស់២០ទៅ៣០ម៉ែត្រ ដុះនៅទាំងតំបន់លិចទឹកនិងភ្នំនៃអាស៊ីក្តៅ។ សំបក គេអាចធ្វើជាផើងដាក់ ជ័រចន្លុះ, ជ័រលាប កញ្ជើ កញ្ច្រែង ល្អី ជាដើម។ ដើម គេអាចធ្វើត្រឹម រោង ខ្ទម បណ្តោះអាសន្ន។ អ្នកខ្លះហៅឈើនេះថា *ផ្ទុងស្លឹកធំ*។

**ផ្ទុងមមីស** /ផ្ទុងមះមីស/ *ន.* ឈើមួយប្រភេទជាព្រឹក្សកម្ពស់ប្រហែលពី១០ទៅ២០ម៉ែត្រដុះក្នុងព្រៃធំត្រជាក់លើដីទំនាបនិងភ្នំតាមបណ្តាប្រទេសក្តៅ។ សំបកវា គេមិនអាចប៉ះបានទេ ព្រោះ អាចធ្វើឱ្យរមាស់ខ្លាំង, ប្រហែល១០ម៉ោង ទើបបាត់។ ដើមអាចប្រើជាគ្រឿងសម្រាប់ធ្វើផ្ទះបាន តែ ត្រូវសកសំបកចេញសិន ឯជ័ររបស់មែក គេប្រើជាថ្នាំព្យាបាលអំបៅអំបែក។

**ផ្ទុងស្លឹកធំ** /ផ្ទុង-ស្លឹក-ធំ/ *ន.* (ម.ព. *ផ្ទុងភ្នំ*។ )

# ៣

ពង្រភ្នំ /ពង្រ-ភ្នំ/ ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃស្រោងឬព្រៃធំៗ ហើយ ភាគច្រើន ដុះលើភ្នំ។ ផ្លែវា គេអាចបរិភោគ តែ គ្រាប់មានជាតិពុល ហើយ ដើមវា គេអាច ប្រើធ្វើជាបង្គោលរបងបាន។ អ្នកខ្លះហៅឈើនេះថា *ថ្មចង្ក្រាន*។

ពន់ /ពន់/ *ន.* ឈ្មោះឈើមួយប្រភេទដុះក្នុងព្រៃក្រាស់ស្ងួត។ សាច់ឈើមានពណ៌ លឿង។ វាជាប្រភេទឈើមានតម្លៃ, គេប្រើសម្រាប់សង់ផ្ទះបាន។

ព័ន្ធលៃ /ពាន់-ទៈ-លៃ/ *ន.* (ម.ព. *ប្រាំតម្លឹង*។)

ពពកវិល /ព-ពក-វឹល/ *ន.* ស្មៅស្លឹកមួយប្រភេទធំៗដុះក្នុងប្រទេសត្រដាក់មធ្យម នៅទ្វីបអាម៉េរិកខាងជើង។ វាជារុក្ខជាតិលម្អ ដែលគេយកមកដាំនៅអាស៊ី។ តាម ជំនឿអរូបីខ្មែរ មនុស្សខ្លះជឿថា ដើមនេះអាចការពារផ្ទះពីចោរលួចប្លន់បាន ព្រោះ វានឹងធ្វើឱ្យចោរវិលមុខ។

ពពាលខែឈ្មោល /ព-ពាល-ខែ-ឈ្មោល/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃស្រោង។ ដើមវា គេប្រើសម្រាប់សង់ផ្ទះ។ សំបកវា, តាមវេជ្ជសាស្ត្របុរាណ, គេប្រើជាឱសថ សម្រាប់ស្ងោរឱ្យស្ត្រីទើបសម្រាលកូនផឹកដើម្បីឆាប់មានកម្លាំង និង ប្រើជាថ្នាំ រំងាប់រោគរាកមួល។

ពាល់ពៃង /ពាល់-ពៃង/ (ព.មេ.) *កិ.* ធ្វើឱ្យឈឺ។ ឧ. *ហេតុអ្វីបានជាអស់លោកមក ពាល់ពៃងកូនចាប?*

ពពូលថ្ម /ព-ពូល-ថ្ម/*ន.* រុក្ខជាតិមួយប្រភេទដុះក្នុងព្រៃស្រោង។ ដើមវាមានសភាព រឹង, គេច្រើនយកធ្វើជាដងកាំបិតពូថៅជាដើម។ តាមវេជ្ជសាស្ត្របុរាណ សំបក គេប្រើជាថ្នាំបុរាណ ស្ងោរផឹកជាឱសថជំនួយកម្លាំង, គ្រាប់ គេប្រើជាថ្នាំព្រូន, ស្លឹក គេប្រើលាយជាមួយសំបកស្ងោរផឹកដើម្បីឱ្យសក់ដុះលឿន។ អ្នកខ្លះហៅ ដើមនេះថា *ពពូលរមៀត*។

# ៣

ពភ្លាធំ /ព-ភ្លា-ធំ/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានប្រភពក្នុងព្រៃក្រាស់ស្ងួតនិងព្រៃស្រោង។ ផ្លែវា គេអាចបរិភោគបាន។ តាមវេជ្ជសាស្ត្របុរាណ ឫសប្រើជាឱសថស្ងោរផឹកព្យាបាលជំងឺក្អក, ស្លឹកវា គេលាយនឹងសំបកត្រាំទឹកសម្រាប់ព្យាបាលការបាក់ឆ្អឹង។ អ្នកខ្លះហៅដើមនេះថា *ពញាប្រើស* ។

ពភ្លាប្រើស /ព-ភ្លា-ប្រើស/ *ន.* (ម.ព. *ពភ្លាធំ* ។)

ពិកា (ដើម) /ពិ-កា/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី៥ទៅ១៣ម៉ែត្រ ដុះក្នុងព្រៃស្រោង និង តាមច្រកព្រៃធំៗ លើដីទំនាបឬភ្នំនៅតំបន់អាស៊ីក្ដៅ។ ស្លឹកខ្ចី ផ្កា និងផ្លែ គេអាចចម្អិនបរិភោគបាន ហើយ សំបកនិងឫសគេសម្រាប់ជ្រលក់សំពត់ឱ្យមានពណ៌លឿង។ អ្នកខ្លះហៅឈើនេះថា *ស្រោមដាវ* ។

ពិកា (ស្មៅ) /ពិ-កា/ *ន.* តិណជាតិរីងដុះក្នុងព្រៃល្បោះនៃ ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសវៀតណាម និង ប្រទេសថៃ។ ផ្លែជារបស់ដែលក្មេងចូលចិត្តលេង។

ពិធីជញ្ជាត់ព្រលឹង /ពិ-ធី-ជញ់-ជាត់-ព្រលឹង/ *ន.* ពិធីរៀបចំឡើង ដើម្បីរកព្រលឹងអ្នកឈឺឱ្យចូលខ្លួនវិញ។ គេរៀបចំពិធីនេះបន្ទាប់ពីពិធីលៀងអារក្ស។ ជាធម្មតាអ្នកជំងឺមានអាការៈល្ងិតល្ងៃដេកស្ដូកស្ដឹង មិនចង់និយាយស្ដី។ គេធ្វើពិធីនេះដោយជឿថា ព្រលឹងអ្នកជំងឺដើរចោលរូបឬមានខ្មោចយកព្រលឹងអ្នកជំងឺទៅ។ តាមជំនឿខ្មែរ ព្រលឹងរបស់មនុស្សមាន១៩, ពេលខ្លះ គេសន្មតថា ស្រូវមានព្រលឹង១៩ដូចមនុស្សដែរ។ ឧ. *អញស្រូបព្រលឹងអំពីគុហាមហាសមុទ្រ ហេតុមន្តអញធុត អញតាមស្រូបព្រលឹងនេះហោងទាំង១៩គ្រប់នៅនឹងរូបនេះ ហោង ...* (តម្រាហៅព្រលឹង)។

ពីងចាប /ពីង-ចាប/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះក្នុងព្រៃល្បោះ។ ដើមវាត្រង់ពណ៌ប្រផេះ, ផ្លែទុំមានពណ៌ក្រហម។ តាមវេជ្ជសាស្ត្របុរាណ ដើមវា គេធ្វើជាថ្នាំ, ឫសវា គេច្របាច់ជាមួយទឹកសម្រាប់ព្យាបាលជំងឺគ្រុននិងរាគ ហើយ អាចស្ងោរផឹកដើម្បីព្យាបាលជំងឺស្ងួត។

# ព

**ពុទ្ធក្ខេត្ត** /ពុត-ធាក់-ខែត/ *ន.* ខេត្តរបស់ព្រះពុទ្ធ។ តាមគម្ពីរវិសុទ្ធិមគ្គ ពុទ្ធក្ខេត្តជាដែនក្នុងលោកធាតុសម្រាប់ការប្រតិស្ឋានឡើងនៃព្រះពុទ្ធ។ ពុទ្ធក្ខេត្តមានបី គឺ *ជាតិក្ខេត្ត, អាណាខេត្ត* និង *វិសយក្ខេត្ត* ។ ជាតិក្ខេត្តមានលោកធាតុឬចក្រវាលចំនួនមួយម៉ឺនលោកធាតុ។ ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធចុះចាប់បដិសន្ធិនិងប្រសូតជាដើម ជាតិក្ខេត្តនេះកម្រើកញ្រាប់ញ័រហាក់ដូចគេចាប់អង្រួន ដោយអំណាចបុណ្យរបស់ព្រះអង្គ។ អាណាខេត្តមានលោកធាតុឬចក្រវាលចំនួនមួយសែនកោដិលោកធាតុ។ ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធសម្តែង រតនបរិត្ត, ខន្ធ-បរិត្ត, ធជគ្គបរិត្ត, អាដានាដិយបរិត្ត និង មោរបរិត្ត អាណាខេត្តនេះកម្រើកញ្រាប់ញ័រហាក់ដូចគេចាប់អង្រួន ដោយអំណាចព្រះបរិត្តដែលព្រះអង្គសម្តែង។ វិសយ-ក្ខេត្តមានលោកធាតុឬចក្រវាលជាអនន្ត។ ប្រាជ្ញាញាណរបស់ព្រះពុទ្ធជ្រៅឆ្ងាយទូលាយជាអនន្តផ្សាយទៅក្នុងឱកាសលោក។ ជាតិក្ខេត្តនិងអាណាខេត្តជាខេត្តរបស់ព្រះពុទ្ធមួយព្រះអង្គៗ។

**ពោធិព្រឹក្ស** /ពោ-ធិ-ព្រឹក/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះជាបញ្ញើក្អែកលើដើមឈើព្រៃភ្នំ។ ផ្លែវា គេអាចបរិភោគ។ គេច្រើនដាំវាដើម្បីលម្អ។

**ពុលឯក** /ពុល-អែក/ *ន.* វល្លិធ្នារមួយប្រភេទដុះវារតាមដងផ្លូវ។ ស្លឹកខ្ចីជាបន្លែ តែ ផ្លែមានជាតិពុលខ្លាំង។ តាមវេជ្ជសាស្ត្របុរាណ ដើមវា គេបុកលាយជាមួយទឹកធម្មតា និងទឹកប្រមាត់ពស់ថ្លាន់ផឹករំងាប់រោគអុតធំ។

**ពួច** /ពួច/ *ន.* ឈើតូចមួយប្រភេទមានកម្ពស់ពី១ទៅ២ម៉ែត្រ ដុះក្នុងព្រៃស្រោង។ ផ្លែមានសាច់ច្រើនពណ៌ក្រហមក្រមៅ គេអាចបរិភោគជាអាហារស្រស់។ សរសៃសំបក គេប្រើបិទនៀវទូកឬកប៉ាល់បាន។

**ពួចដូវ** /ពួច-ដូ/ *ន.* ចុល្លព្រឹក្សមួយពួកមានកម្ពស់ពី២ទៅ១០ម៉ែត្រ ដុះក្នុងព្រៃភ្នំនៅអាស៊ីអាគ្នេយ៍, នៅស្រុកខ្មែរ ច្រើនដុះលើភ្នំបូកគោ។ ផ្កាសដុះជាចង្កោមចេញពីគល់ស្លឹក, គេកាត់ដាក់ផើងលម្អផ្ទះ។

# ព

ពួចឈ្មោល /ពួច-ឈ្មោល/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី១០ទៅ២០ម៉ែត្រ ដុះក្នុងព្រៃរបោះក្នុងទ្វីបអាស៊ីក្ដៅ ដើមមានសារជាតិពុល។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក គេស្ងោរផឹកអាចធ្វើឱ្យរលូតកូនបាន។

ពួចអួល /ពួច-អួល/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់២ទៅ៤ម៉ែត្រ ដុះក្នុងព្រៃល្បោះនៅអាស៊ី និង អូស្ត្រាលីតំបន់ក្ដៅ។ ផ្លែបរិភោគបាន, ដើមធ្វើជាបង្គោលរបង។

ពោតបារាំង /ពោត-បា-រ៉ាំង/ *ន.* គុម្ពព្រឹក្សមួយយ៉ាងមានប្រភពមកពីប្រទេសអេហ្ស៊ីបហើយបាននាំយកទៅដាំនៅបណ្ដាប្រទេសក្ដៅ។ ស្លឹកនិងផ្លែខ្ចីសម្រាប់បរិភោគ។

ពោធិបេង /ពោ-បេង/ *ន.* ឈើមួយប្រភេទដើមធំកំពស់ប្រហែលពី៣០ទៅ៤៥ម៉ែត្រ ដុះក្នុងត្រជាក់និងព្រៃធំនៃឥណ្ឌូចិន ភូមា ចិនខាងត្បូង ឥណ្ឌា និងប្រទេសនៅជុំវិញភ្នំហិមាល័យដែលមានកំពស់១២០០ម៉ែត្រ។ ដើមវាគេប្រើសង់ផ្ទះ។

ពុំពែន /ពុំ-ពែន/ *ន.* រុក្ខជាតិមួយប្រភេទមានកម្ពស់ពី២ទៅ១០ម៉ែត្រ ដុះលើខ្សាច់មាត់ទឹកនៅ ទ្វីបអាស៊ី និង អូស្ត្រាលីក្ដៅ។ ផ្លែទុំពណ៌បៃតងមានជាតិប្រេងអាចប្រើដុតបំភ្លឺបាន បើចាក់ក្នុងទឹកពុលត្រី។ តាមវេជ្ជសាស្ត្របុរាណ សំបកស្ងោរលាយ ទឹកដូង ទឹកអង្ករ និង ទឹកខ្មេះ គេប្រើជាថ្នាំបញ្ចុះ។ ដើមវា គេប្រើសង់រោងឬខ្ទមបាន។ អ្នកខ្លះហៅឈើនេះថា *ដាវក្រពើ*។

ព្រហូតទឹក /ព្រ-ហ៊ូត-ទឹក/ *ន.* ចុល្លព្រឹក្សមួយយ៉ាងមានកម្ពស់ប្រហែលពី៦ទៅ១៥ម៉ែត្រ ដុះក្នុងព្រៃធំលើខ្សាច់ឬដីឥដ្ឋនៅអាស៊ី និង អូស្ត្រាលីក្ដៅ។ ដើមវា គេអាចប្រើសង់ផ្ទះនិងដុតកម្ដៅបាន។ អ្នកខ្លះហៅឈើ *តាត្រៅទឹក, ហង់ទឹក*។

ព្រហូតភ្នំ /ព្រ-ហ៊ូត-ភ្នំ/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី៨ទៅ១២ម៉ែត្រ ដុះតាមព្រៃភ្នំក្នុងឧបទ្វីបឥណ្ឌូចិន។ សំបកវា គេប្រើជ្រលក់ឱ្យសំពត់មានពណ៌បៃតង។ ដើមវាមិនសូវធន់ទេ តែ អាចធ្វើក្ដារសង់ផ្ទះបាន។

# ព

**ព្រហ្មសទ្ទ** /ព្រំ-មៈ-សាត់/ (បា.) *ន.* សំឡេងព្រហ្ម។ តាមគម្ពីរពុទ្ធសាសនា ព្រហ្មប្រកបដោយសំឡេងប្រាំបី គឺ *វិស្សដ្ឋោ* សំឡេងជ្រះស្រលះ, *វិញ្ញេយ្យោ* សំឡេងបញ្ជាក់, *មញ្ជុ* សំឡេងទន់ពីរោះ, *សវនិយោ* សំឡេងគួរឱ្យចង់ស្ដាប់, *ពិន្ទុ* សំឡេងណែន, *អវិសារី* សំឡេងមូល, *គម្ភីរោ* សំឡេងជ្រៅ, *និន្នាទី* សំឡេងរំពង។

**ព្រាលខ្សាច់** /ព្រាល-ខ្សាច់/ *ន.* (ម.ព. *ប្រលាស់ព្រះ*។)

**ព្រាលចៀម** /ព្រាល-ចៀម/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៥ទៅ៩ម៉ែត្រ ដុះក្នុងព្រៃក្រាស់និងក្រាស់មធ្យមនៃអាស៊ីអាគ្នេយ៍។ សំបកវា គេអាចយកមកវេញធ្វើជាខ្សែពួរ ឯដើម គេប្រើធ្វើគ្រឿងផ្ទះ។ អ្នកខ្លះហៅឈើនេះថា *ស្រោល*។

**ព្រាលជ្រូក** /ព្រាល-ជ្រូក/ *ន.* (ម.ព. *កន្ទុយកំប្រុក ១*។)

**ព្រាលឈ្មោល** /ព្រាល-ឈ្មោល/ *ន.* រុក្ខជាតិមួយប្រភេទមានកម្ពស់ប្រហែលពី៦ទៅ១៥ម៉ែត្រ ដុះតាមព្រៃរបោះក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្លឹកវា គេប្រើជ្រលក់ជ័រទឹកសម្រាប់ធ្វើចន្លុះ ។ សំបកវាមានសរសៃអាចប្រើសម្រាប់វេញខ្សែ។

**ព្រាលប្រើស** /ព្រាល-ប្រើស/ *ន.* (ម.ព. *ប៉ាងផែក*។)

**ព្រីងបាយ** /ព្រីង-បាយ/ *ន.* រុក្ខជាតិមួយប្រភេទដុះក្នុងទ្វីបអាស៊ីនិងអូស្ត្រាលីក្តៅ។ ផ្លែវា គេអាចបរិភោគបាន។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក សំបក និង ដើម គេយកទៅស្ងោរផឹកព្យាបាលជំងឺទឹកនោមផ្អែម។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ព្រីងដោះក្របី*។

**ព្រៃថ្នាំង** /ព្រៃ-ថ្នាំង/ *ន.* (ម.ព. *កម្រើកគុម្ព*។)

**ព្រំ** /ព្រំ/ *ន.* ឈើមួយប្រភេទមួយពួកកម្ពស់ពី៧ទៅ១៥ម៉ែត្រ ដុះក្នុងព្រៃ ស្រោងនៃតំបន់អាស៊ីផ្នែកក្តៅ។ ស្លឹកខ្ចី គេយកមកធ្វើជាចំណីសត្វគោក្របី។ ដើមវាមិនសូវធន់ល្អទេ គេអាចត្រឹមសម្រាប់សង់រោងឬធ្វើអុសដុតជាដើម។

# ៣

**ព្រុមបន្លា** /ព្រុំ-បន់-ឡា/ *ន.* ចុល្លព្រឹក្សមានកម្ពស់៤ទៅ៥ម៉ែត្រ ដុះក្នុងព្រៃល្បោះ នៃឥណ្ឌូចិន ហើយ គេច្រើនដាំវាធ្វើរបង ព្រោះវាមានបន្លាច្រើន។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេប្រើធ្វើជាថ្នាំព្យាបាលរោគក្រពះ។

**ព្រះខ្លួបដំរី** /ព្រះ-ខ្លួប-ដំរ៉ី/ *ន.* គុម្ពព្រឹក្សឆ្មារម្យ៉ាងដុះវារតាមដីវាលក្បែរព្រៃដងផ្លូវនិងព្រៃគុម្ពោត។ តាមវេជ្ជសាស្ត្របុរាណ ដើមវាមានបន្លា, ស្លឹកគេប្រើធុងផឹកដើម្បីព្យាបាលគ្រុនមានពិសលើស្បែក។

**ព្រះខ្លួបយក្ស** /ព្រះ-ខ្លួប-យាក់/ *ន.* (ម.ព. *បន្លាយក្ស*។)

**ព្រះធ្លក** /ព្រះ-ធ្លក/ ព្រឹក្សមួយប្រភេទមានកម្ពស់ពី៦ទៅ១០ម៉ែត្រ ដុះនៅព្រៃត្រជាក់លើទីរាបនិងខ្ពស់ប្រហែល៥០០ម៉ែត្រនៃឧបទ្វីបឥណ្ឌូចិន ថៃ និង ប្រទេសឥណ្ឌូណេស៊ីលើកោះស៊ូម៉ាត្រា។ ដើមពណ៌ស មិនសូវធន់ល្អទេ គេអាចប្រើជាគ្រឿងផ្ទះឬខ្ទមបាន។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេធុងសម្រាប់ស្ត្រីជិតសម្រាលកូនផឹកជាថ្នាំជំនួយឱ្យឆាប់សម្រាលនិងឃាត់ឈាម។

**ព្រះភ្នៅ** /ព្រះ-ភ្នៅ/ *ន.* រុក្ខជាតិខ្ពស់មួយប្រភេទដុះនៅខេត្តមួយចំនួននៅប្រទេសចិន, ប្រទេសនៅឥណ្ឌូចិន និង កោះថៃ។ វាជាពួកឈើមានសាច់រឹងមិនប្រេះ, គេច្រើនយកដើមវាច្នៃប្រើសម្រាប់ធ្វើគ្រឿងសង់ផ្ទះនិងទូក។ សំបកមានពណ៌សប្រផេះគេបរិភោគជំនួសស្លាបាន។ តាមវេជ្ជសាស្ត្របុរាណ គេអាចយកសំបកស្ងោរផឹកព្យាបាលរោគមួល។

**ព្រះល្បៀង** /ព្រះ-ល្បៀង/ *ន.* តិណជាតិមួយយ៉ាងវារលើដីដុះតាមទីវាលកណ្តាល ថ្ងៃលើដីខ្សាច់នៃឥណ្ឌូចិននិងប្រជុំកោះថៃ។ តាមវេជ្ជសាស្ត្របុរាណ គេស្ងោរផឹកព្យាបាលអុត ហើយ ប្រើជាគ្រឿងផ្សំធ្វើថ្នាំព្យាបាលរោគស្វាយ។ តិណជាតិនេះគេប្រើជាចំណីសត្វគោក្របីផងដែរ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ស្មៅអំបុក* ឬហៅថា *ស្មៅស្រមោច*។

# ៣

ព្រះអង្គម្ចាស់ /ព្រះ-អង់-ម្ចាស់/ *ន.* ព្រះរាជបុត្រព្រះរាជា, ព្រះរាជបុត្ររបស់ក្សត្រាក្សត្រីដែលមានរាជសក្តិជាទីព្រះអង្គម្ចាស់ស្មើគ្នា។

# ភ-ម-យ

ភូឈ្មួយក្រុង /ភូ-ឈ្មួយ-ក្រុង/ *ន.* ឈ្មោះតំណែងរដ្ឋបាលអ្នកគ្រប់គ្រងបន្ទាប់ពីអភិបាលក្រុង (ម.ព. *ចៅហ្វាយខេត្ត* បន្ថែម។)

ភ្លាំង /ភ្លាំង/ *ន.* (ម.ព. *ផ្លង់* ។)

ភ្លៀងលាងស្លែ /ភ្លៀង-លាង-ស្លែ/ *ន.* ភ្លៀងពេលអគ្រាត្រធ្លាក់ចុះមកជាមេធំៗ។

មកុដ /មៈ-កុត/ *ន.* ឈ្មោះឈើធំមួយប្រភេទមានកម្ពស់ពី២០ទៅ៣៥ម៉ែត្រ ដុះក្នុងព្រៃជ្រៅ។ ស្លឹកខ្ចីៗជាចំណីសត្វពាហនៈ, សាច់ឈើសម្បុរប្រផេះក្រមៅឬលឿងភាវ។ ឈើអាចខូច បើនៅហាលភ្លៀងខ្យល់។ គេច្រើនប្រើឈើនេះធ្វើជាគ្រឿងដំបូលផ្ទះនិងធ្វើតួស្គរ។ ផ្លែវា គេអាចបរិភោគជាចំណីបាន។

មណ្ឌា /មន់-ឌា/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីមួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម។ រឿងនេះមាននិទានក្នុងសង្ក្រានសូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃពុធ ឆ្នាំនោះជាឆ្នាំដែលព្រះនាង មណ្ឌា គ្រប់គ្រង។ ព្រះនាង មណ្ឌា សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះថ្លា(សប្បិ) អាវុធស្ពាំម្ពុល ឆ្វេងឈើច្រត់ ពាហនៈលា។

មន្ត្រី /មន់-ត្រី/ *ន.* ឈ្មោះឈើមួយប្រភេទមានកម្ពស់ពី៨ទៅ១៥ម៉ែត្រ។ គ្រាប់មានពណ៌ក្រហម។ តាមវេជ្ជសាស្ត្របុរាណ គេយកសំបកទៅស្ងោរផឹកដើម្បីរំងាប់រោគមួលនិងជំងឺឈាម។

មនតូច /មន-តូច/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៣ដល់៦ម៉ែត្រនាំពីប្រទេសចិនភាគកណ្តាល និង ខាងលិច, គេយកមកដាំគ្រប់ប្រទេសនៅអាស៊ីផ្នែកក្តៅជាយូរណាស់ហើយ។ នៅប្រទេសកម្ពុជា ដើមមនមានកម្ពស់ត្រឹម១ដល់២ម៉ែត្រប៉ុណ្ណោះ។ គេប្រើស្លឹកធ្វើជាចំណីដង្កូវនាង។ ផ្លែវាមានពណ៌ក្រហមឬក្រហមភាវ, ពេលទុំ វាមានពណ៌ក្រហមក្រមៅ, គេអាចបរិភោគបាន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *មនពោធិ* ។

# ភ-ម-យ

មនធំ /មន-ធំ/ *ន.* ចុល្លព្រឹក្សកម្ពស់មួយប្រភេទមានកម្ពស់ពី៣ទៅ៧ម៉ែត្រនាំពីស្រុកចិនកណ្ដាលនិងខាងលិច, គេយកមកដាំគ្រប់ប្រទេសនៃ អាស៊ីអាគ្នេយ៍, ទ្វីបអឺរ៉ុប និង អាម៉េរិកខាងជើង។ គេដាំដើម្បីយកស្លឹកប្រើជាចំណីដង្កូវនាងធ្វើសូត្រ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើស្លឹកមនធំផ្សំធ្វើថ្នាំព្យាបាលជំងឺភ្នែកក្រហមនិងសម្រាប់លាងដំបៅ។ សំបក គេប្រើជាថ្នាំកម្លាំងនិងទប់មិនឱ្យរាកជាដើម។

មនបារាំង /មន-បារ៉ាំង/ *ន.* ឈ្មោះរុក្ខជាតិមានកម្ពស់៦ទៅ២៥ម៉ែត្រមានដើមកំណើតក្នុងទ្វីបអាស៊ីខាងកើត, គេដាំស្រុកខ្មែរសម្រាប់លម្អសួន។ ដើមនេះ គេដាំធ្វើក្រដាសបាន។ តាមវេជ្ជសាស្ត្របុរាណ ស្លឹក ផ្លែ គ្រាប់ គេយកមកដាំផឹកឱ្យនោមច្រើន។

មនបារាំង(វល្លិ) /មន-បារ៉ាំង/ *ន.* ឈ្មោះគុម្ពព្រឹក្សជាវល្លិមួយប្រភេទមានកម្ពស់ពី ០.៥០ទៅ១ម៉ែត្រ។ គេនាំពីបរទេសមកដាំលើភ្នំបូកគោ ច្រើនដុះតាមមាត់ព្រៃក្រាស់ ឬ លើព្រៃគុម្ពោតមានថ្ម។ ផ្លែវាមានរសផ្អែមបរិភោគឆ្ងាញ់ពិសា។ ផ្កាក្លិនក្រអូបអាចបេះ តាំងផ្ទះបាន។ គេស្ងោរឫសផឹករម្ងាប់រោគឈឺពោះ។

មនពោធិ /មន-ពោ/ *ន.* (ម.ព. *មនតូច*។)

មនស្វា /មន-ស្វា/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី៧ទៅ១៦ម៉ែត្រដុះក្នុងព្រៃស្រោងនិងទីវាលលើដីក្រហម។ ឈើមនស្វាមិនសូវជាប់ទេ តែ អាចប្រើធ្វើគ្រឿងផ្ទះរាយរងបាន និង ធ្វើប្រអប់ផ្សេងៗ។

មមាញខ្មោច /ម-មាញ-ខ្មោច/ *ន.* ឈ្មោះស្មៅមួយប្រភេទដុះតាមមាត់ផ្លូវ នៃប្រទេសអាស៊ីក្ដៅ។ ស្លឹកស្អិតៗបរិភោគមិនបានទេ តែ ផ្លែខ្ចីៗមមាញខ្មោច គេអាចជ្រក់ជាអាហារ។ តាមវេជ្ជសាស្ត្របុរាណ ដើមវា គេប្រើសម្រាប់ធ្វើថ្នាំព្យាបាលផ្សេងៗដូចជា សន្លាក់, លើសឈាម, គ្រុនចាញ់, ខ្សោយប្រព័ន្ធប្រសាទ និង ដំបៅក្លាយ ជាដើម។

# ភ-ម-យ

មមាំង(ស្មៅ) /ម-មាំង/ *ន.* តិណជាតិមួយប្រភេទដុះត្រង់ឡើងលើមានកម្ពស់ពី ៥០ទៅ៨០សង់ទីម៉ែត្រលើដីទំនេរក្នុងទ្វីបអាស៊ីក្ដៅ។ ដើមវាមានក្លិនស្អុយ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើស្មៅនេះផ្សំធ្វើថ្នាំពស់ចឹក។ មែក ជាង ព្រមទាំង ឫស ជាគ្រឿងផ្សំថ្នាំព្យាបាលជំងឺប្រមេះស្ត្រី។

មហាមេឃ(វល្លិ) /មៈ-ហា-មេក/ *ន.* ឈ្មោះវល្លិធំមួយប្រភេទវារឡើងរុក្ខជាតិជិត ខាង មានប្រវែងរហូតដល់ ២៥ម៉ែត្រ តែ ដើមមានវិជ្ឍមាត្រមិនលើសពី២សង់ទី-ម៉ែត្រ ដុះក្នុងព្រៃល្បោះឬព្រៃស្រោង។ តាមវេជ្ជសាស្ត្របុរាណ គេធុងដើមសម្រាប់ ព្យាបាលជំងឺអុតធំនិងគ្រុនចាញ់។

មហាកណ្ឌាភណ្ឌ /មៈ-ហា-កន់-ឋា-ភាន់/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយយស* ផង។)

មហាសិរីវឌ្ឍន៍ /មៈ-ហា-សេ-រ៉ី-វ៉ាត់/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម. ព. *គ្រឿងឥស្សរិយយស* ផង។)

មហោទរា /មៈ-ហោ-ទៈ-រា/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រី មួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម, រឿងនេះមាននិទាន ក្នុងសង្រ្កានសូត្រ។ កាលបើឆ្នាំណាមានសង្រ្កាន្តជាថ្ងៃសៅរ៍ ឆ្នាំនោះជាឆ្នាំដែល ព្រះនាង មហោទរា គ្រប់គ្រង។ ព្រះនាង មហោទរា សៀតផ្កាត្រកៀត គ្រឿង ប្រដាប់នីលរ័តន៍ ភក្សាហារសាច់ទ្រាយ អាវុធស្ដាំចក្រ ឆ្វេងត្រីសូល៍ ពាហនៈក្ងោក។

ម៉ាក់ប្រោង /ម៉ាក់-ប្រោង/ *ន.* ឈ្មោះឈើមួយប្រភេទមានកម្ពស់ពី៨ទៅ២០ម៉ែត្រ ដុះក្នុងព្រៃក្រាស់មាត់សមុទ្រ។ ផ្លែទុំមានពណ៌លឿងភាវមានរសជាតិផ្អែម, គេ អាចបរិភោគជាបង្អែម។ គេប្រើជ័រមាក់ប្រោងលាប តុ ទូ ឱ្យរលោងល្អ។ ឈើវាគេ ប្រើសម្រាប់ធ្វើ តុ ទូ កៅអី។ មែកធំៗអាចកាត់ធ្វើជន្លង់ចម្ការម្រេចដោយសារវា ជាប់បានយូរ។ ឈើ គេប្រើធ្វើសសរផ្ទះបាន។

# ភ-ម-យ

ម៉ាក់ខេត /ម៉ាក់-ខេត/ *ន.* ឈើមានបន្លាមានកម្ពស់ពី៥ទៅ១០ម៉ែត្រ។ គេយកពីប្រទេសចិន (កោះហៃណាំ ហុងកុង) មកដាំក្នុងឥណ្ឌូចិន។ តាមវេជ្ជសាស្ត្របុរាណ គេយកសាច់ផ្លែធ្វើថ្នាំព្យាបាលជំងឺច្រមុះ។ ស្លឹកនិងសំបកគេយកប្រើធ្វើថ្នាំព្យាបាលជំងឺស្បែក។ គ្រាប់ជាថ្នាំធ្វើឱ្យក្អួត (ពេលពុលចំណី) និង បញ្ចុះដើម្បីបន្សាបពិស។

មាស(វល្លិ) /មាស/ *ន.* វល្លិល្អិតមួយប្រភេទរស់ដោយសារគេ, មែកតូចដូចខ្សែអំបោះវារពាត់ជុំវិញមែករុក្ខជាតិដែលអាចជា ចុល្លព្រឹក្ស គុម្ពព្រឹក្ស ឬ ព្រឹក្ស។ វល្លិនេះមាននៅ គ្រប់ប្រទេសអាស៊ី និង អាហ្វ្រិកក្តៅ។ គេអាចយកវល្លិនេះធ្វើថ្នាំជ្រលក់សំពត់អាវឱ្យពណ៌ក្រមៅ។ វាមានជ័រស្អិត ដែលគេតែងលាយជាមួយកំបោរសង់ផ្ទះ និង សម្រាប់ធ្វើជីលែងដើម្បីបិទប្រហោងទូក។ នៅប្រទេសកម្ពុជាគេយកវល្លិមាសធ្វើឱសថព្យាបាលជំងឺស្ងួត។

មិម /មឹម/ *ន.* ឈ្មោះគ្រឿងភ្លេងខ្សែមួយប្រភេទមានខ្សែតែមួយ។ អ្នកលេងកូតខ្សែដូចទ្រ, ខ្សែនេះជាខ្សែអំបោះដែលគេចងនៅខាងចុងខាងក្រោមជិតកន្លែងកូតបន្លាយមកដាក់ក្នុងមាត់ហើយយកស្រកាលពង្រួលកូត។ ស្រកាពង្រួល គេកោសឱ្យស្តើង រួច ចោះរន្ធស៊កខ្សែអំបោះដោយបង្ខាំងនឹងកន្លាស់ឫស្សីតូចមួយហើយ ដាក់ចន្លោះធ្មេញលើក្រោមប្រៀបដូចទារកបៅដោះឬម៉ិម។ ធាកវាធ្វើពីឫស្សី។ ខ្សែចងភ្ជាប់ពីចុងខាងក្រោមនៃតួបង្គួតទៅភ្ជាប់នឹងព្រលួតធ្វើពីឫស្សី, ដងធ្វើពីពីងពង់។ ផ្នែកខាងក្រោមដង គេស៊កឈើតូចមូលចូលក្នុងបំពង់ឫស្សី, ផ្នែកខាងចុងឈើខាងអ៊ែនបន្តិច, ខាងចុងផុត គេចិតឱ្យមានរាងមូលសំប៉ែតដូចប្រាក់កាស។ គេចិតឈើនោះឱ្យមានដុំតូចមួយទៀត ហើយ លើឈើមួយសំប៉ែតនោះ គេចោះរន្ធតូចមួយសម្រាប់ស៊កខ្សែដោយចងភ្ជាប់នឹងកន្លាស់ឫស្សីតូចមួយគឺកន្លែងនេះហើយដែលគេចងអំបោះបន្លាយ។ លើដងឫស្សី គេបិទខ្ទង់ដោយក្រមួនឃ្មុំឬម្រោម, ខ្ទង់មានចំនួនបួនធ្វើពីឫស្សី។

# ភ-ម-យ

**មេឃុំ** /មេ-ឃុំ/ *ន.* ឈ្មោះតំណែងរដ្ឋបាលអ្នកគ្រប់គ្រងជាន់ខ្ពស់នៅឃុំ។ (ម.ព. *ចៅហ្វាយខេត្ត* បន្ថែម។)

**ម្ទុល** /ម្ទុល/ *ន.* (ម.ព. *បង្គោលស៊ីផ្លែ* ។)

**ម្ទូរបារាំង** /ម្ទូ-បា-រ៉ាំង/ *ន.* (ម.ព. *ម្ទូរល្មមក្រហម* ។)

**ម្ទូរល្មមក្រហម** /ម្ទូ-ល្មម-ក្រ-ហម/ *ន.* តិណជាតិប្រចាំឆ្នាំមួយប្រភេទ មានដើមរឹង, ស្លឹកទោដុះឆ្លាស់ទង, សន្ទះស្លឹកចែករាងជាម្រាម, ផ្កាទោលពណ៌ក្រហមស្វាយដុះចេញ ពីប្រគាបស្លឹក, ទងខ្លី។ តាមវេជ្ជសាស្ត្របុរាណ រុក្ខជាតិទាំងមូលមានប្រយោជន៍ ច្រើន ដូចជា គេប្រើ ស្លឹកព្យាបាលជំងឺក្អក, ផ្កាព្យាបាលជំងឺ ចុកពោះលើសសម្ពាធឈាម, សរសៃប្រសាទ, ផ្លែបញ្ចុះខ្លាញ់ក្នុងឈាម, គ្រាប់បញ្ចុះ ទឹកនោម, ស្រទាប់ផ្លែព្យាបាលក្រួសក្នុងតម្រងនោម ជាដើម។ អ្នកខ្លះហៅ រុក្ខជាតិនេះថា *ម្ទូរល្មមក្រហម* ឬ *ជេងគ្រេងក្រហម* ។

**ម្រឹតត្យូវ** /ម្រឹត-ត្យូវ/ *ន.* ឈ្មោះជំងឺមួយប្រភេទដែលអ្នកជំងឺមានអាការៈ ភ័យខ្លាច មិនមាត់មិនក រសាប់រសល់ចេះតែចង់ដើរឱ្យបាត់ពីផ្ទះ។ តាមជំនឿអរូបីខ្មែរ នៅពេលស្ថានភាពធ្ងន់ធ្ងរ គេឃើញអ្នកជំងឺកំបុតក្បាល។ តាមជំនឿខ្មែរ គេថា ព្រលឹងទាំង ១៩របស់ជននោះមិននៅគ្រប់ក្នុងខ្លួនឬមានគេយកព្រលឹងទៅ។ ពាក្យនេះ អ្នកខ្លះនិយាយក្លាយជា *ប្រមាត់ត្រយូវ* ក៏មាន។

**ម្រាមនាង** /ម្រាម-នាង/ *ន.* (ម.ព. *ប្រផូ* ។)

**ឃិតថៅបារាំង** /ឃិត-ថៅ-បា-រ៉ាំង/ *ន.* (ម.ព. *ផ្កាក្រមួន* ។)

**ឃោគគុន** /ឃោក-គុន/ *ន.* ឈ្មោះមេអុតទីប្រាំបីកើតនៅបាតដៃផុត។

# រ

**រកាវារ** /រ-កា-វា/ *ន.* ឈើមួយពួកមានកម្ពស់ពី៧ទៅ១១ម៉ែត្រ ដុះក្នុងព្រៃល្បោះនៃតំបន់អាស៊ីអាគ្នេយ៍។ តាមវេជ្ជសាស្ត្របុរាណ ស្លឹកត្រាំទឹកអាច ព្យាបាលជំងឺកមរមាស់។

**រង្វាយភ្លើង** /រង់-វាយ-ភ្លើង/ *ន.* (ម.ព. *កុលាបភ្នំ។*)

**រតនះស្តោះខ្យល់** /រាត់-តៈ-ណាក់-ស្តោះ-ខ្យល់/ *ន.* ឈ្មោះមេអុតទីពីរកើតនៅចំប្របេរមាត់។

**រទេះលន** /រ-ទេះ-លន/ *ន.* រទេះសាឡី។

**រន្ទះបាញ់** /រន់-ទះ-បាញ់/ *ន.* គុម្ពព្រឹក្សមួយយ៉ាងមានផ្កាក្រហមឆ្អៅដូចរន្ទះ មានដើមកំណើតនៅអាស៊ីក្តៅ ហូរចូលមកឥណ្ឌូចិន។ នៅប្រទេសកម្ពុជា រុក្ខជាតិនេះដុះតាមដងផ្លូវ និងក្បែរផ្ទះនៅទីជនបទ ហើយ ពេលខ្លះវាត្រូវបានគេដាំលម្អ។

**រមៀត (វល្លិ)** /រ-មៀត/ *ន.* រុក្ខជាតិមួយប្រភេទជាស្មៅវារលើដី មានពោមដុះនៅទីវាល។ ឫសវាមានពណ៌លឿងដូចរមៀត។ គេអាចប្រើជាថ្នាំជ្រលក់សំពត់បានហើយ, តាមវេជ្ជសាស្ត្របុរាណ, គេយកប្រើរំងាប់មេរោគផ្សេងៗ។

**រមាំង ១** /រ-មាំង/ *ន.* ចុល្លព្រឹក្សមួយប្រភេទវារលើដើមឈើដទៃ។ មែករបស់វាអាចប្រើដុតបំភ្លឺជំនួសទៀន។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេស្ងោរផឹកជាថ្នាំកម្លាំង។

**រមាំង ២** /រមាំង/ *ន.* ឈើមួយប្រភេទ មានកម្ពស់ពី៨ទៅ១៥ម៉ែត្រ ដុះក្នុងព្រៃស្រោង និងព្រៃល្បោះ ក្នុងប្រទេសកម្ពុជា។ ផ្លែវា គេប្រើជាគ្រឿងធ្វើឱ្យត្រីស្លឹកមុននេសាទ ។ ដើមវា គេប្រើសង់ផ្ទះនិងរបស់ប្រើប្រាស់ផ្សេងៗ។

**រយោង ១** /រ-យោង/ *ន.* (ព.មេ.) ដូង។

**រយោង ២** /រ-យោង/ *ន.* ឈើមួយប្រភេទមានកម្ពស់ពី២០ទៅ៣៥ម៉ែត្រដុះតាមព្រៃត្រជាក់នៃ ឧបទ្វីបឥណ្ឌូចិន ជ្វា លើកោះសូម៉ាត្រា និង បណោអូ។ ស្លឹកខ្ចី គេប្រើ

ជាបន្លែ, ដើមមានទម្ងន់ស្រាល គេធ្វើជាហិបឬប្រអប់។ តាមវេជ្ជសាស្ត្របុរាណ សំបក គេប្រើជាថ្នាំត្រាំទឹកងូតព្យាបាលកមរមាស់។

**រលាយឈាម** /រំ-លាយ-ឈាម/ *ន.* ចុល្លព្រឹក្សមួយពួក មានផ្កាពណ៌ខៀវល្អ មានកម្ពស់ពី១ទៅ៤ម៉ែត្រ ដុះក្រោមរុក្ខជាតិធំៗ លើភ្នំកម្ពស់៣០០ម៉ែត្រឡើង ក្នុងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេប្រើជាថ្នាំរំលាយសម្រាប់ស្បែកជាំផងដែរ។

**រលួសបារាំង** /រ-លួស-បារ៉ាំង/ *ន.* ឈើមួយពួកមានកម្ពស់ពី៨ទៅ១៥ម៉ែត្រ ដុះនៅប្រទេសអាម៉េរិកក្ដៅ ហើយ ដាំលម្អនៅអាស៊ី។ ផ្លែទុំ គេអាចចោលបានឆ្ងាយ ហើយផ្ទុះយ៉ាងខ្លាំង។ ផ្លែស្ងួត គេធ្វើជាកង់រទេះក្មេងលេង។

**រាជដាស** /រាច-ចៈ-ដាស/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី១ទៅ៤ម៉ែត្រដុះតាមដីវាលនៃ ឧបទ្វីបឥណ្ឌូចិន ផ្ទា ចិនភាគខាងត្បូង និង ឥណ្ឌូណេស៊ី។ តាមវេជ្ជសាស្ត្របុរាណ ឫស គេចុងផឹកព្យាបាលអាការៈវិលមុខខ្យល់គរជាដើម ហើយអាចធ្វើជាគ្រឿងផ្សំព្យាបាលជំងឺខាន់លឿង។ អ្នកហៅឈើនេះថា *ញិញ* ។

**រាក្សសា** /រា-ក្សាក់-សា/ *ន.* នាមទេពធីតាជាបុត្រីមហាព្រហ្ម។ ព្រះនាងជាបុត្រីមួយអង្គក្នុងចំណោមបុត្រីទាំងប្រាំពីររបស់កបិលមហាព្រហ្ម។ រឿងនេះមាននិទានក្នុងសង្ក្រានសូត្រ។ កាលបើឆ្នាំណាមានសង្ក្រាន្តជាថ្ងៃអង្គារ ឆ្នាំនោះជាឆ្នាំដែលព្រះនាង *រាក្សសា* គ្រប់គ្រង។ ព្រះនាង *រាក្សសា* សៀតផ្កាឈូក គ្រឿងប្រដាប់មោរ៉ា ភក្សាហាររលោហិត អាវុធស្ដាំត្រីសូល៍ ឆ្វេងធ្នូ ពាហនៈអស្សតរ។

**រូបស្នៀត** /រូប-ស្នៀត/ *ន.* មនុស្សដែលមិនចំជាតួអារក្សប្រចាំត្រកូល។ រូបស្នៀតចេញ នៅពេលដែលអ្នកភូមិមិនគិតគួរលៀងមេមត់ហើយគិតតែរកគ្រូខ្មែរឬគ្រូពេទ្យព្យាបាល។

**រូបសំណឹង** /រូប-សំណឹង/ *ន.* មនុស្សដែលសម្រាប់ឱ្យអ្នកតាឬខ្មោចអារក្សចូលសណ្ឋិត។

# រ

**រូបអារក្ស** *ន.* មនុស្សសាមញ្ញ តែ ជាតំណាងព្រលឹងដូនតា នៅពេលដែលអារក្សចូល (ចូលរូប)។

**រ៉ាក់លែត** /រ៉ាក់-លែត/ *ន.* ឧបករណ៍តន្ត្រីផ្លុំមួយបែបរបស់ជនជាតិព្នង។ ឧបករណ៍នេះកើតឡើងពីការផ្គុំផ្លែឃ្លោកទុំស្ងួតដែលចោះរន្ធបីទៅនឹងឫស្សីមួយកង់ប៉ុនកដៃ។ បំពង់ឫស្សីនេះជាជំនួយធ្វើឱ្យឮខ្លាំងហើយឆ្ងាយ។ ផ្នែកទទឹងនៃផ្លែឃ្លោកគេចោះរន្ធឱ្យធ្លាយពីម្ខាងទៅម្ខាងសម្រាប់ស៊កឫស្សីពកដែលចោះរន្ធបីដែរ។ ផ្នែកខាងទងនៃផ្លែឃ្លោក គេកាត់ចោល ហើយស៊កឫស្សីពកត្រង់ភាគនៃទងដែលកាត់ចោលនោះ។ ឫស្សីដែលស៊កនេះមានប្រវែងខ្លីវែងឫស្សីពកដែលស៊កទទឹងឃ្លោក។ គេផ្លុំតាមឫស្សីពកខ្លីនេះ។ គេភ្ជាប់ផ្នែកនៃតួទាំងមូលរ៉ាក់លែតដោយជ័រម្រោម។ នៅពេលផ្លុំ ប្រសិនគេចង់បានសំឡេងមូលល្អ គេចាក់ទឹកចូលក្នុងបំពង់ឫស្សីដែលភ្ជាប់នោះ។ គេផ្លុំរ៉ាក់លែតដើម្បីអន្ទងហៅព្រលឹង តែ គេក៏អាចផ្លុំប្រគំជាមួយនឹងគងបានដែរក្នុងពិធីផឹកស្រាពាំងរែក បន្ទាប់ពីសែនព្រេន។

**រែយោង** /រែ-យោង/ *ន.* (ម.ព. *វល្លិយោង*។)

**រោគស** /រោក-ស/ *ន.* វល្លិមួយពួកមានសភាពរឹងវារឡើងរុក្ខជាតិផ្សេងៗ ដុះក្នុងព្រៃស្រោងទ្វីបអាស៊ី និង អូស្ត្រាលីតំបន់ក្តៅ។ តាមវេជ្ជសាស្ត្របុរាណ គេប្រើផ្សំវាជាឱសថព្យាបាលរោគធ្លាក់ស។

**រំបែកភ្នំ** /រំ-បេក-ភ្នំ/ *ន.* ចុល្លព្រឹក្សមួយប្រភេទបែកមែកសាខាច្រើនដុះតាមតំបន់ភ្នំខ្ពស់ប្រហែល១០០០ម៉ែត្រក្នុងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ តាមវេជ្ជ-សាស្ត្របុរាណ ស្លឹកវា គេស្ងោរផឹកបង្ការជំងឺគ្រុនចាញ់។

**រំដួលស៊ីផ្លែ** /រំ-ដួល-ស៊ី-ផ្លែ/ *ន.* ចុល្លព្រឹក្សមានកម្ពស់ពី២ទី៥ម៉ែត្រ មែកធ្លាក់ មកក្រោម ដុះតាមព្រៃស្រោងនៅប្រទេសកម្ពុជានិងប្រទេសឡាវ។ ផ្លែវាមានទំហំប៉ុនទំពាំងបាយជូរ មានរសផ្អែម ហើយ អាចជួយឱ្យការរំលាយអាហារបានលឿន។

# រ

**រំលៀង** /រំលៀង/ *ន.* ព្រឹក្សមួយពួកកម្ពស់ប្រហែល៦ទៅ១៥ម៉ែត្រ ដុះតាមព្រៃជិតមាត់សមុទ្រ និង លើភ្នំខ្ពស់ប្រហែល១០០០ម៉ែត្រ នៅអាស៊ីអាគ្នេយ៍។ សំបកគេយកធ្វើជាចន្លុះ ឯដើម គេធ្វើជាគ្រឿងផ្ទះផ្សេងៗ។

**រំលាយធំ** /រំ-លាយ-ធំ/ ឈើមួយពួកមានកម្ពស់ពី៧ទៅ៣០ម៉ែត្រ ដុះក្នុងព្រៃធំ ឬព្រៃល្បោះនៅអាស៊ីអាគ្នេយ៍។ ដើមពណ៌សប្រផេះ មិនមាំល្អទេ គេអាចប្រើត្រឹមជាគ្រឿងផ្ទះធម្មតា, មែកនិងធាង គេធ្វើជាអុសដុត។

**រំយោលភ្នំ** /រំ-យោល-ភ្នំ/ *ន.* ចុល្លព្រឹក្សមួយពួក ពេលខ្លះ ដុះជាគុម្ព កម្ពស់ប្រហែល១ទៅ៥ម៉ែត្រ មានប្រភពមកពីទ្វីបអាហ្វ្រិកខាងកើត ហើយ គេយកទៅដាំលម្អនៅប្រទេសក្តៅនិងត្រជាក់មធ្យម។ ពូជបង្កាត់ឯងៗ មានត្របកផែកៗ។

**រំយោលផែក** /រំ-យោល-ផែក/ *ន.* រំយោលមួយប្រភេទដែលមានត្របកផែកៗ។ ចុល្លព្រឹក្សនេះមានកម្ពស់១ទៅ៥ម៉ែត្រ, មានប្រភពមកពីទ្វីបអាហ្វ្រិកខាងកើត។ គេដាំលម្អនៅប្រទេសក្តៅនិងត្រជាក់មធ្យម។ វាជាប្រភេទរុក្ខជាតិដែលពូជបង្កាត់ឯងៗ។

**រំលាយស្មង** /រំ-លាយ-ស្មង/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ប្រហែលពី១ទៅ៣ម៉ែត្រ ដុះក្នុងព្រៃក្រាស់ជ្រុះស្លឹកនៅអាស៊ីក្តៅ។ តាមវេជ្ជសាស្ត្របុរាណ ដើមវាគេធ្វើថ្នាំរម្ងាប់រោគ, ឯផ្លែល្វីង គេប្រើជាថ្នាំរាកមួល, គ្រាប់ និង សំបក ក៏គេប្រើជាឱសថដែរ។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ដើមប្រមាត់មនុស្ស*។

**រាំងភ្នំ** /រាំង-ភ្នំ/ *ន.* (ម.ព. *ថ្នឹកភ្នំ*។)

# ល-វ-ស-ហ-ឡ-អ

លៀងលើផ្ទះ /លៀង-លើ-ផ្ទះ/ *ន.* ការលៀងអារក្សឱ្យខ្មោចដូរជំប្ដូរទាំងខាងឪពុកទាំងខាងម្ដាយ។

លៀងឯជី /លៀង-អែ-ជី/ *ន.* ការលៀងគ្រូសម្ដោះ។ ក្នុងពិធីនេះ គេរៀបចំឱ្យមានត្រួន៣ជាន់ និង បើកឆត្របាំង។ គេនិយាយថា *លៀងឱ្យចំណី* ក៏មាន។

លម៉ើព្រៃ /លះ-ម៉ើ-ព្រៃ/ *ន.* តាលព្រឹក្សតឿមួយប្រភេទ ដុះតាមវាលស្មៅ នៅឧបទ្វីបឥណ្ឌូចិន និង ប្រទេសចិនខាងត្បូង។ គុម្ពមានរសឆ្ងាញ់ធ្វើជាបន្លែ ឯផ្លែរសផ្អែមដូចលម៉ើធម្មតា។ អ្នកខ្លះហៅរុក្ខជាតិនេះថា *កំពេញ* ឬ *ដើមប្រើស* ។

លួតតូច /លួត-តូច/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៦ទៅ១៥ម៉ែត្រដុះក្នុងព្រៃស្រោងនិងតាមច្រកភ្នំ នៅឧបទ្វីបឥណ្ឌូចិន, ប្រទេសចិនភាគខាងត្បូង និងប្រទេសឥណ្ឌា។ ដើមវា គេប្រើសម្រាប់សង់រោងឬខ្ទម។ មែកជាងតូចៗ គេប្រើធ្វើអុសដុត។

លំពស់ដែក /លំ-ពស់-ដែក/ *ន.* (ម.ព. *វល្លិដែក* ។)

លំពាន់ /លំ-ពាន់/ *ន.* (ម.ព. *កំប្រុញ។*)

ល្បៀងទឹក /ល្បៀង-ទឹក/ *ន.* ចុល្លព្រឹក្សមួយប្រភេទ មានកម្ពស់ពី១ទៅ៥ម៉ែត្រ ដុះតាមវាលខ្សាច់ព្រៃស្រោងព្រៃគុម្ពោតជិតផ្ទះក្នុងភូមិ ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្លឹកមានរសជូរ, គេប្រើជាបន្លែអន្លក់និងស្លជាមួយត្រីបាន។ មែកជាង គេប្រើធ្វើអុសដុតបាន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ល្បៀងស្បាត* ។

ល្បៀងស្បាត /ល្បៀង-ស្បាត/ *ន.* (ម.ព. *ល្បៀងទឹក* ។)

ល្បប់ /ល្បប់/ *ន.* ឈ្មោះទ្រមួយប្រភេទរបស់ជនជាតិចាមនៅស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង។ ប្រអប់សូរធ្វើពីលលាដ៍ដូងហើយពាសឈើស្រាលដូចទ្រអ៊ូ, ផ្នែកខាងក្រោម គេចិតផ្ទៃឱ្យរាបស្មើ ហើយ ពាសឈើដើម្បីទប់ដងទ្រនិងសម្រាប់ចងខ្សែពីក្រោម។

# ល-វ-ស-ហ-ឡ-អ

ល្វាជី /ល្វា-ជី/ *ន.* (ម.ព. *កុមារពេជ្រ* ២ ។)

វត្ថុសក្តិសិទ្ធិ /វ៉ាត់-ថុ-សាក-សិត/ *ន.* វត្ថុដែលគេមានជំនឿថាមានឫទ្ធិមានអំណាច អាថ៌កំបាំង។ ឧ. *មនុស្សមួយចំនួនជឿវត្ថុសក្តិសិទ្ធិ ដូចជា មន្ត, អាគម, គាថា និង យ័ន្ត* ជាដើម។

វរសេនា /វៈ-រាក់-សេ-ណា/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយយស* ផង។)

វល្លិឆ្អឹងពស់ /វ៉ាល់-ឆ្អឹង-ពស់/ *ន.* គុម្ពព្រឹក្សមួយប្រភេទមានផ្កាពណ៌សតូចៗវារឡើងរុក្ខជាតិដុះក្បែរ ដុះក្នុងព្រៃល្បោះនៅឥណ្ឌូចិននិងប្រទេសឥណ្ឌា។ ដើមវាគេប្រើជាចំណងសម្រាប់ចងវត្ថុផ្សេងៗ។

វល្លិដែក /វ៉ាល់-ដែក/ *ន.* ចុល្លព្រឹក្សមួយប្រភេទមាន ពេលខ្លះ ដុះជាវល្លិវារឡើងរុក្ខ-ជាតិដទៃ ដុះក្នុងព្រៃស្រោង នៅតំបន់ទំនាប និង តំបន់ភ្នំ ដែលទាបជាង១០០០ ម៉ែត្រ នៅអាស៊ីក្តៅ។ ស្លឹកខ្ចី គេបរិភោគជាបន្លែ ឯមែក គេប្រើធ្វើជាខ្សែនិងគ្រោងលប។ តាមវេជ្ជសាស្ត្របុរាណ ឫស គេប្រើជាថ្នាំព្យាបាលជំងឺ ហើមកណ្តុរ។ អ្នកខ្លះហៅវល្លិនេះថា *វល្លិពងក្តស្វា* ឬ *លំពស់ដែក* ។

វល្លិពងក្តស្វា /វ៉ាល់-ពង-ក្ត-ស្វា/ *ន.* (ម.ព. *វល្លិដែក* ។)

វល្លិយាយហុក /វ៉ាល់-យាយ-ហុក/ *ន.* (ម.ព. *ផ្កាត្រែ* ។)

វល្លិយោង /វ៉ាល់យោង/ *ន.* រុក្ខជាតិមួយប្រភេទកម្ពស់ប្រហែលពី៨ទៅ២០ម៉ែត្រ ដុះក្នុងព្រៃក្រាស់នៃ ឥណ្ឌូចិន ឥណ្ឌា និង កោះជ្វា។ ខ្លឹមក្នុងដើម គឺល្អស្អាត មានពណ៌ក្រហមឆ្អូត, គេប្រើធ្វើ តុ ទូ និង សង់ផ្ទះ។ អ្នកខ្លះវល្លិនេះថា *វែយោង* ។

វិវដ្តកប្ប /វិ-វ៉ាត់-កាប់/ *ន.* កប្បចម្រើន។

# ល-វ-ស-ហ-ឡ-អ

វីក (វល្លិ) /វីក/ *ន.* ចុល្លព្រឹក្សមួយពួកដើមតឿហើយត្រង់ឡើងលើ ដុះតាមវាលស្មៅ ឬក្នុងស្រែដែលគេបោះបង់។ វាជាចំណីមួយប្រភេទសម្រាប់គោក្របី។ តាមវេជ្ជសាស្ត្របុរាណ គ្រូថ្នាំខ្មែរប្រើវាជាថ្នាំបុរាណព្យាបាលជំងឺផ្សេងៗ។ អ្នកខ្លះហៅវល្លិនេះថា *ស្រកានាគ* ឬ *ស្រឡប់ពពក*។

សក់សេះ /សក់-សេះ/ *ន.* (ម.ព. *អណ្ដូងប្រាំង។*)

សង្កើច(ស្មៅ) /សង់-កើច/ *ន.* ស្មៅប្រចាំឆ្នាំមួយប្រភេទមានកម្ពស់ពី៣០ដល់៥០សង់ទីម៉ែត្រដុះក្រោមឈើធំៗក្នុងព្រៃត្រជាក់លើភ្នំ ច្រើនមានក្នុងវាលស្មៅលើភ្នំបូកគោ។ គេប្រើដើមសម្រាប់សម្លាប់សត្វល្អិតជាពិសេសសត្វសង្កើច។

សង្កែភ្លើង /សង់-កែ-ភ្លើង/ *ន.* ឈ្មោះសង្កែមួយប្រភេទមានកម្ពស់ពី៤ទៅ១០ម៉ែត្រដុះក្នុងព្រៃស្រោង។ វាជាឈើមិនសូវជាប់ល្អទេ តែ គេអាចប្រើជាគ្រឿងផ្ទះរាយរងបាន។ តាមវេជ្ជសាស្ត្របុរាណ គេប្រើសំបកស្ងោរធ្វើថ្នាំគ្រុន។

សង្កែភ្លើង (តូច) /សង់-កែ-ភ្លើង/ *ន.* ឈ្មោះសង្កែមួយប្រភេទមានកម្ពស់ពី១ទៅ៤ម៉ែត្រ ដុះក្នុងព្រៃល្បោះ។ ស្លឹកសម្រាប់ធុងផឹកដូចតែ។ ដើមវា គេយកធ្វើអុសដុតឆេះល្អ។

សង្កែព្រៃ /សង់-កែ-ព្រៃ/ *ន.* ឈ្មោះសង្កែមួយប្រភេទមានកម្ពស់ពី១ទៅ២ម៉ែត្រដុះក្នុងព្រៃក្រាស់។ គេយកស្លឹកមូរបារីជក់បានដូចស្លឹកសង្កែធម្មតាដែរ។

សណ្ដាក្រហម (ដើម) /សន់-ដា-ក្រ-ហម/ *ន.* ឈ្មោះឈើមួយប្រភេទមានកម្ពស់ពី៧ទៅ១២ម៉ែត្រដុះក្នុងព្រៃក្រាស់លើដីទំនាបឬលើភ្នំទាបៗ។ នៅប្រទេសកម្ពុជាឈើនេះដុះច្រើននៅខេត្តកំពត លើភ្នំកំចាយ និង ខេត្តកំពង់ស្ពឺ។ ឈើពណ៌ក្រហមភាវគេប្រើសម្រាប់ធ្វើជាក្ដារសង់ផ្ទះ។

សណ្ដាន់ទេស /សន់-ដាន់-ទេស/ *ន.* ស្មៅរឹងមួយប្រភេទមានកម្ពស់ពី១ទៅ៣ម៉ែត្រដុះឡើងលើត្រង់ពណ៌ក្រហម មានដើមកំណើតប្រហែលពីទ្វីបអាហ្វ្រិក។

ដើមវាមានសរសៃល្អ គេអាចយកទៅត្បាញបាន។ គ្របកផ្កាមានសាច់ច្រើនមាន ពណ៌ក្រហមឆើតព្រមទាំងស្លឹក គេប្រើធ្វើគ្រឿងទេសជូរ អាចជំនួសក្រូចឆ្មារនិង អម្ពិលបាន។

សណ្ដែកកំប៉ើញ /សន់-ដែក-កំ-ប៉ើញ/ *ន.* វល្លិធំមានមែករឹងដុះក្នុងព្រៃស្រោង។ ស្លឹកខ្ចីធ្វើបន្លែឬរបោយបាន។ ផ្លែ គេយកប្រើសម្រាប់លាងសក់។ សំបកវាគេអាច ស្ងោរជ្រលក់សំណាញ់។ តាមវេជ្ជសាស្ត្របុរាណ ផ្លែគេប្រើជាថ្នាំច្រើនមុខ ដូចជា បូស ស្រែង ឃ្លង់ ជាដើម។ គេផឹកទឹកដែលត្រាំផ្លែដើម្បីធ្វើឱ្យទន់លាមក, ផ្លែក៏ជា គ្រឿងផ្សំថ្នាំសម្រាប់ព្យាបាលជំងឺតម្រងនោមនិងប្លោកនោម។ សាច់នៃគ្រាប់, ពេលប្រឡេះគ្រាប់ចោល, ជាឱសថធ្វើឱ្យ នោមច្រើន និង ធ្វើឱ្យក្អួត។ គ្រាប់ជាថ្នាំ គេប្រើសម្រាប់សម្រួលការសម្រាលកូន។

សណ្ដែកក្លិង្គ /សន់-ដែក-ក្លឹង/ *ន.* សណ្ដែកមួយប្រភេទ មានកម្ពស់ពី១ទៅ៣ម៉ែត្រ ដុះក្នុងព្រៃស្រោងព្រៃល្បោះ តាមមាត់ទឹកឬលើដីទួល។ គេនិយមដាំសណ្ដែកក្លិង្គជុំ វិញផ្ទះជារបង។ គ្រាប់អាចបរិភោគដូចសណ្ដែកបាយ។ ស្លឹកខ្ចី គេអាចយកធ្វើជា ចំណីគោក្របី។ តាមវេជ្ជសាស្ត្របុរាណ អ្នកដែលមានជំងឺរាកនោមតែងព្យាបាល ដោយបរិភោគផ្លែឆៅរាល់ថ្ងៃឱ្យធាប់ជា។ ស្លឹកស្ងួត គេកិនឱ្យម៉ត់ដូចម្សៅ គេផឹក ដើម្បីព្យាបាលជំងឺប្រមេះគ្រាប់។ អ្នកខ្លះហៅសណ្ដែកនេះថា *សណ្ដែកគ្រាប់* ។

សណ្ដែកកំប៉ើយ /សន់-ដែក-កំ-ប៉ើយ/ *ន.* (ម.ព. *បាយដំណើប* ។)

សណ្ដែកខ្មោច /សន់-ដែក-ខ្មោច/ *ន.* សណ្ដែកមួយប្រភេទមានដើមកំណើតក្នុង ប្រទេសអាម៉េរិកខាងត្បូង។ ដើមសណ្ដែកខ្មោចដុះឯងៗតាមមាត់ផ្លូវ និង ក្នុងដី វាល។ ផ្កាលឿងជាចង្កោម គេអាចបរិភោគជាបន្លែរបោយបាន។ គេស្ងោរស្លឹកនិង ផ្លែយកទឹកផឹកជាថ្នាំលើកកម្លាំង។ គេស្ងោរគ្រាប់ដែលលីងហើយយកទឹកផឹក សម្រាប់ព្យាបាលជំងឺគ្រុនចាញ់ ឬ សម្រាប់ធ្វើថ្នាំបញ្ចុះ ឬ ថ្នាំព្យាបាលគ្រុន។

# ល-វ-ស-ហ-ឡ-អ

សម៉ស្បាត /សះ-ម៉-ស្បាត/ *ន.* (ម.ព. *ព្រះធ្លក*។)

សារ៉ាណាយ /សា-រ៉ា-ណាយ/ *ន.* ឧបករណ៍ភ្លេងមួយប្រភេទ ក្នុងពួកស្រឡៃ របស់ជនជាតិចាមដែលរស់នៅប្រទេសកម្ពុជា។ សារ៉ាណាយមិនមានសូរតឹងណែនដូចស្រឡៃពិណពាទ្យទេ។

សេនា /សេ-ណា/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយ-យស* ផង។)

សំវដ្តកប្ប /សាំង-វាត់-ដះ-កាប់/ *ន.* កប្បវិនាស។

សំប៉ុយ /សំ-ប៉ុយ/ *ន.* (ម.ព. *បន្លាស្អិត*។)

ស្លែចិនស្លឹកផែក /ស្លែ-ចិន-ស្លឹក-ផែក/ *ន.* (ម.ព. *ប៉ិឆាយ*។)

ស្នាច់អន្លង់ /ស្នាច់-អន់-លង់/ *ន.* (ម.ព. *អន្ទង់ទាត់*។)

ស្មៅស្លាបទា /ស្មៅ-ស្លាប-ទា/ *ន.* (ម.ព. *ផ្កាថ្ម*។)

ស្មៅស្រមោច /ស្មៅ-ស្រ-ម៉ោច/ *ន.* (ម.ព. *ព្រះល្មៀង*។)

ស្មៅអំបុក /ស្មៅ-អំ-បុក/ *ន.* (ម.ព. *ព្រះល្មៀង*។)

ស្រកានាគ /ស្រ-កា-នាក/ *ន.* (ម.ព. *វ៉ឹក*។)

ស្រមោច (ស្មៅ) /ស្រ-ម៉ោច/ *ន.* (ម.ព. *ព្រះល្មៀង*។)

ស្រឡប់ពពក /ស្រ-ឡប់-ព-ពក/ *ន.* (ម.ព. *វ៉ឹក*។)

ស្រុន /ស្រុន/ *ន.* (ម.ព. *អង្រុត*។)

ស្រោមដាវ /ស្រោម-ដាវ/ *ន.* (ម.ព. *ពិកា*។)

ស្រោល /ស្រោល/ *ន.* (ម.ព. *ព្រាលចៀម*។)

ហង់ទឹក /ហង់-ទឹក/ *ន.* (ម.ព. *ព្រហូតទឹក*។)

# ឈ-ឆ-ស-ហ-ឡ-អ

ហ៊ិត /ហ៊ិត/ *ន.* ឧបករណ៍ភ្លេងមួយប្រភេទមានសណ្ឋានហេតហូត តែ គេផ្គុំជាបាច់រាងមូល។ ពេលផ្លុំ គេកាន់បង្វិល។

ហាត់ដោ /ហាត់-ដោ/ *ន.* កំណាត់ឫស្សីពីងពង់ប្រវែងប្រមាណ៥ម៉ែត្រសម្រាប់វាយកាត់ទទឹងផ្លូវប្រណាំងកំណត់ការចាញ់ឈ្នះរបស់រទេះមុខនិងរទេះក្រោយ។

ហិតសម្អុយ /ហិត-សំ-អុយ/ *ន.* ឈ្មោះមេអុតទីបីកើតនៅចុងច្រមុះ។

ហេតហូត /ហេត-ហូត/ *ន.* ឧបករណ៍តន្ត្រីផ្លុំមួយប្រភេទធ្វើពីឫស្សីពកដែលគេកាត់ជាកង់ៗដោយមិនទុកថ្នាំង។ គេរើសបំពង់ពីតូចទៅធំពីប៉ុនម្រាមដៃដល់ប៉ុនមេដៃ។ គេផ្គុំតម្រៀបគ្នាជាបណ្ដុំជាជួរផ្ដេក តាមលំដាប់ឫស្សីដោយរៀងកម្ពស់ពីខ្លីទៅវែង។ពេលផ្លុំ គេប្រើមេដៃសិករន្ធកេះចេញសូរប៉ឹកៗជាការបន្ទរសាច់បទ។ ហេតហូតមានពីរប្រភេទ គឺ ហេតហូតបៀរតាល់ និង ហេតហូតពេងតាល់។ ហេតហូតបៀរតាល់ជាហេតហូតដែលគេផ្គុំជាពីរជាន់ ហើយ ច្រើនតែជនជាតិទំពួនប្រើឧបករណ៍នេះ ចំណែកហេតហូតពេងតាល់ វាជាហេតហូតដែលគេផ្គុំគ្នាបីជាន់។ ការផ្គុំពីរឬបីជាន់នេះគឺដើម្បីធ្វើឱ្យមានសូរខ្លាំង។

ហ្គងប /ហ្គង-ប/ *ន.* គងឫស្សី, ឈ្មោះឧបករណ៍តន្ត្រីមួយបែបរបស់ជនជាតិដើមភាគតិចខ្មែរ។

ហ្គងណាក /ហ្គង-ណាក/ *ន.* រនាតបំពង់ឫស្សី, ឈ្មោះឧបករណ៍តន្ត្រីមួយបែបរបស់ជនជាតិដើមភាគតិចខ្មែរ។

ហ្គងរីង /ហ្គង-រីង/ *ន.* ឈ្មោះឧបករណ៍តន្ត្រីមួយប្រភេទរបស់ជនជាតិដើមភាគតិចខ្មែរ។ គេឃើញនៅមានប្រើដោយជនជាតិក្នុងនៅខេត្តមណ្ឌលគិរី។ គេកាត់យកឫស្សីតែមួយសាច់ដែលជាបំពង់ធំ ដោយទុកថ្នាំងទាំងពីរខាង។ បន្ទាប់មក គេពុះជ្រៀកជាពីរ តែ មិនឱ្យដាច់ដល់ថ្នាំងម្ខាងទៀត ដើម្បីរកសូររងំបន្ទរពីក្នុងបំពង់ឫស្សីមក។ ចំពោះខ្សែ គេយកកាំបិតចុងស្រួចឆ្កឹះយកខ្នងផ្នែកម្ខាងនៃបំពង់ឫស្សី

នោះឱ្យមានរាងធ្នាវៗហូតទល់ដល់ថ្នាំងទាំងពីរ បន្ទាប់មក គេកល់កម្ទេចឈើនៅជិតថ្នាំងទាំងពីរខាងដើម្បីឱ្យខ្សែនោះឡើង។ កម្ទេចឈើដែលកល់មានប្រយោជន៍ក្នុងការរឹតរកសូរខ្ពស់ទាបផង, ខ្សែដែលត្រូវចិតសម្រាប់កេះមានចំនួនប្រាំពីរឬប្រាំបី។ គេលេងហ្គងរឹងដោយលេងម្នាក់ឯងឬលេងជាក្រុម។ ឧបករណ៍នេះសរសេរជា *គងរឹង* ក៏បាន។

ឡាំព្រះធរណី /ឡាំ-ព្រះ-ធ-រៈ-នី/ *ន.* ឈ្មោះមេអុតទីដប់កើតនៅខ្នងជើង។

អង្កង់ខ្មៅស្លឹកធំ /អង់-កង់-ខ្មៅ-ស្លឹក-ធំ/ *ន.* ចុល្លព្រឹក្សមួយប្រភេទដុះតាមព្រៃក្រាស់និងស្ទើរក្រាស់ក្នុង ឧបទ្វីបឥណ្ឌូចិន ថៃ ប្រទេសឥណ្ឌូណេស៊ី និង កោះម៉ាលុកស៍។ ដើមវា គេប្រើសង់រោងឬខ្ទម, មែកនិងជាងតូចៗ គេធ្វើអុសដុត។ តាមវេជ្ជសាស្ត្របុរាណ មែកនិងជាងតូចដែលកាត់តូចៗ គេស្ងោរផឹកជាថ្នាំបំបាត់ការឈឺចាប់ ហើយ ឫស គេប្រើជាគ្រឿងផ្សំធ្វើថ្នាំកម្លាំង។

អង្កាញ់ព្រៃ /អង់-កាញ់-ព្រៃ/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៦ទៅ១៥ម៉ែត្រដុះតាមព្រៃជ្រុះស្លឹកលើដីមានជាតិកំបោរនៅអាស៊ីអាគ្នេយ៍ និង ប្រទេសអូស្ត្រាលីផ្នែកខាងជើង។ ដើមវាជាប្រភេទឈើជាប់ធន់ល្អ មិនពុកផុយ គេអាចប្រើសង់ផ្ទះនិងធ្វើប្រដាប់ប្រដាផ្សេងៗបាន។ ស្លឹកខ្ចីៗ គេអាចបរិភោគ ឯផ្លែបរិភោគដើម្បីទម្លាក់ព្រូន។ អ្នកខ្លះហៅឈើនេះថា *ក្តួចទេសព្រៃ។*

អង្កាញ់ស្វា /អង់-កាញ់-ស្វា/ *ន.* (ម.ព. *ប្រុញស្វា។* )

អង្កោលបន្លា /អង់-កោល-បន់-ឡា/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៦ទៅ១២ម៉ែត្រដុះលើវាល។ ដើមវាមានបន្លាច្រើន តែ ជ្រុះបន្តិចម្តងៗវិញ នៅពេលចាស់ ។ ផ្លែអាចបរិភោគ ឯដើម ប្រើធ្វើរបស់ក្មេងលេង។ ជ័រប្រើជាថ្នាំព្យាបាលជំងឺគ្រុន ហើយ ខ្លឹមដើម ជនជាតិខ្មែរលើមានជំនឿថា ជាវត្ថុសក្តិសិទ្ធិបណ្តេញទេពារក្សអាក្រក់។

# ល-វ-ស-ហ-ឡ-អ

អង្រ្កុត /អង់-ក្រុត/ *ន.* ចុល្លព្រឹក្សមួយពួក មានកម្ពស់ប្រហែលពី៥ទៅ៩ម៉ែត្រ ដុះក្នុងព្រៃក្រាស់ ព្រៃស្រោង តាមបណ្ដាប្រទេសនៅ ជុំវិញភ្នំហិមាល័យ, ឥណ្ឌូចិន, លើកោះជ្វា និង លើកោះស៊ូម៉ាត្រា។ វាជារុក្ខជាតិមិនជ្រុះស្លឹក ហើយ ដើមវា គេប្រើធ្វើជា នាវា ទូក និង ធ្វើអង្រ្កុតចាប់ត្រី។

អញ្ចកធំ (ស្មៅ) /អាញ់-ជក-ធំ/ *ន.* តិណជាតិមួយប្រភេទមានប្រភពមកពីកោះជ្វា ហើយហូរចូលទៅប្រទេសក្ដៅ។ នៅប្រទេសខ្មែរ គេប្រើដើមវាជាថ្នាំបុរាណព្យាបាលអាការៈទាស់របស់ស្ត្រីកូនខ្ចី។

អណ្ដាតគោ (ដើម) /អន់-ដាត-គោ/ *ន.* គុម្ពព្រឹក្សមួយពួក មានកម្ពស់ពី១ទៅ២ម៉ែត្រ ដុះតាមទីវាល។ តាមវេជ្ជសាស្ត្របុរាណ ឫស គេយកធ្វើថ្នាំព្យាបាលសន្លាក់ឆ្អឹង និង កែរដូវស្ត្រីមកឱ្យទៀង។

អណ្ដូងប្រាំង /អន់-ដូង-ប្រាំង/ *ន.* ចុល្លព្រឹក្សមួយពួក ជាវល្លិតោងដើមឈើធំៗ មានប្រភពមកពីឥណ្ឌា ផ្កាក្រហមល្អស្អាត គេយកទៅដាំក្នុងប្រទេសក្ដៅ។ ត្រួយខ្ចី គេបរិភោគជាបន្លែ។ តាមវេជ្ជសាស្ត្របុរាណ គ្រាប់វា គេប្រើជាថ្នាំទម្លាក់ព្រូន។ អ្នកខ្លះហៅរុក្ខជាតិនេះថា *សក់សេះ* ។

អណ្ដូងព្រះ /អន់-ដូង-ព្រះ/ *ន.* គុម្ពព្រឹក្សមួយប្រភេទ មានកម្ពស់១ទៅ២ម៉ែត្រ ស្ទើរវារឬវារ ដុះតាមព្រៃធំៗ លើដីទំនាបនៅ ឥណ្ឌូចិន, កោះជ្វា និង លើកោះស៊ូម៉ាត្រា។ តាមវេជ្ជសាស្ត្របុរាណ ស្លឹកនិងគ្រាប់ គេស្ងោរផឹកដើម្បីទម្លាក់ព្រូន។

អន្ទង់ទាត់ /អន់-ទង់-ទាត់/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី១ទៅ៤ម៉ែត្រ ដុះតាមព្រៃក្រាស់នៅមាត់សមុទ្រក្នុងប្រទេសកម្ពុជានិងប្រទេសវៀតណាម។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេស្ងោរឱ្យស្ត្រីជិតសម្រាលកូនផឹកដើម្បីសម្រាលបានលឿន (តាមទម្លាប់អ្នកខេត្តកោះកុងខ្លះប្រកាន់)។ អ្នកខ្លះហៅរុក្ខជាតិនេះថា *ស្ទាប់អន្លង់* ។

# ឈ-ច-ស-ហ-ឡ-អ

**អន្ទង់ពោយ** /អន់-ទង់-ពោយ/ *ន.* ចុល្លព្រឹក្សមួយប្រភេទ មានកម្ពស់ពី៦ទៅ៨ម៉ែត្រ ដុះតាមព្រៃក្រាស់ជ្រលងភ្នំនិងព្រៃស្រស់ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ជួនកាល គេដាំវាជារុក្ខជាតិលម្អ ហើយ ដើមវា គេប្រើសម្រាប់សង់ខ្ទមឬរោងផ្សេងៗ។

**អន្ទង់ស** /អន់-ទង់-ស/ ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី២ទៅ៥ម៉ែត្រ ដុះតាមក្រោមរុក្ខជាតិធំៗ ក្នុងព្រៃជ្រៅនៃ ឥណ្ឌូចិន, កោះជ្វា និង ប្រទេសឥណ្ឌា។ តាមវេជ្ជសាស្ត្របុរាណ សំបកវា គេប្រើជាថ្នាំរំងាប់រោគក្នុងប្រដាប់រំលាយអាហារ, ផ្លែវាជាថ្នាំរាគមួល ឯឫសវិញ វាជាឱសថសម្រាប់បន្សាបពិស និង ធ្វើឱ្យស្វាងស្រា។

**អន្ទោក** /អន់-ទោក/ *ន.* ឧបករណ៍តន្ត្រីមួយបែបធ្វើពីឫស្សី។ គេយកមួយសាច់ដោយទុកថ្នាំងសងខាងហើយទុកសាច់បន្តបន្តិចសម្រាប់កាន់។ ខ្សែដែលដាក់ភ្ជាប់នឹងឫស្សីមានពីបីដល់ប្រាំពីរ ដោយមានកល់កំណល់ទាំងពីរខាង។ អ្នកខ្លះ ចោះរន្ធមួយខាងក្រោមឧបករណ៍ ហើយ គេចងភ្ជាប់សំបកឃ្លោកទុំមួយ ដើម្បីធ្វើឱ្យមានបន្លឺខ្លាំង។ អន្លូង(ឈើ)សម្រាប់វាយធ្វើពីឫស្សីទាំងដងទាំងផ្លែ។ ពេលលេង គេកាន់វានឹងដៃម្ខាង កាន់អន្លូងដៃម្ខាងទៀត។ អ្នកខ្លះយកប្រអប់សូរដាក់ក្នុងផ្ចិលខាត់ ដើម្បីធ្វើឱ្យមានសូររងំ។ របៀបលេងមួយបែបទៀត គឺ គេកាន់និងកល់លើស្មាដូចវីយ៉ូឡុង តែ គេត្រូវបង្វិលដើម្បីវាយទៅតាមចង្វាក់បទ។ ឧបករណ៍ភ្លេងនេះ អ្នកខ្លះហៅថា *អន្ទូត។*

**អន្ទូត** /អន់-ធូត/ *ន.* (ម.ព. *អន្ទោក*។)

**អន្លក់ព្រះ** /អន់-លក់-ព្រះ/ *ន.* តិណជាតិមួយប្រភេទមានស្លឹកក្រាស់ សាច់ច្រើន ដុះតាមមាត់សមុទ្រនៅអាម៉េរិកក្តៅ។ គេច្រើនបរិភោគជាអន្លក់ជាមួយទឹកគ្រឿងជាដើម។

# ឈ-ឆ-ស-ហ-ឡ-អ

**អន្លុងស** /អន់-លុង-ស/ *ន.* ចុល្លព្រឹក្សមួយប្រភេទ មានកម្ពស់ពី១ទៅ៨ម៉ែត្រ ដុះក្នុងព្រៃធំៗនៅអាស៊ីអាគ្នេយ៍។ តាមវេជ្ជសាស្ត្របុរាណ ឫសវា គេឆុងផឹកជា ថ្នាំគ្រុនចាញ់ ឯស្លឹក គេប្រើជាថ្នាំរោគ ប្រមុះ ត្រចៀក និង ធ្មេញ។

**អម្ពិលខ្មែរ** /អំ-ពឹល-ខ្មែរ/ *ន.* វល្លិមួយពួក ដុះតាមព្រៃក្រាស់និងព្រៃគុម្ពោតលើតំបន់ទំនាបនៅ ឥណ្ឌូចិន, កោះជ្វា, កោះខ្លះនៃប្រទេសឥណ្ឌា, កោះស៊ូម៉ាត្រា និង បណេអូ។ ដើមវា គេប្រើធ្វើជាចំណង ធន់ល្អ។ សំបកវា គេត្រាំស្រាផឹកជាថ្នាំប៉ូវកម្លាំង។

**អង្កាសីលទេស** /អង់-គា-សិល-ទេស/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានប្រហែល ៤ ទៅ៦ម៉ែត្រមានផ្កាពណ៌លឿងដុះក្នុងព្រៃល្បោះនិងគុម្ពោត។ គេតែងដាក់លម្អក្នុងថ្ងៃចូលឆ្នាំចិន។ ស្លឹករបស់វាខុសពីអង្កាសីលធម្មតា ពីព្រោះ វាមានសណ្ឋានធ្មេញរណា ដូចបន្លានៅជុំវិញ និង មានត្របកពណ៌ក្រហមភាវលើផ្លែ។ មែកផ្កាតែងមានដាក់លក់ក្នុងផ្សារ ពីខែមករាដល់ខែមេសា។ ផ្កាពណ៌លឿង តែងរីកឆាប់រហ័ស ពេលគេដាក់មែកផ្កាក្នុងទឹកក្តៅឧណ្ហៗ។ មនុស្សខ្លះជឿថាផ្កានេះជាវត្ថុធ្វើឱ្យចម្រុងចម្រើន។ តាមវេជ្ជសាស្ត្របុរាណ ឫសអង្កាសីលជាថ្នាំជួយរំលាយអាហារ។

**អម្ពិលវល្លិ** /អំ-ពឹល-វាល់/ *ន.* វល្លិធំមួយពួក ជួនកាល ដុះជាចុល្លព្រឹក្ស តាមព្រៃ មាត់សមុទ្រនិងព្រៃស្រោងក្នុងតំបន់អាស៊ីអាគ្នេយ៍។ សំបកវា គេបរិភោគជំនួសស្លា, ស្លឹក គេបុកជ្រលក់សំពត់ជំនួសមក្លឿបាន, ដើម គេប្រើជាចំណងផ្សេងៗ។

**អរិយមេតេយ្យ** /អាក់-រ៉ិ-យាក់-មេត-តៃ/ (បា., សំ. *អារ្យ + មៃត្រេយ*) *ន.* ព្រះនាមព្រះសម្មាសម្ពុទ្ធទីប្រាំក្នុងចំណោមព្រះសម្មាសម្ពុទ្ធប្រាំព្រះអង្គដែលនឹងត្រាស់ដឹងក្នុងភទ្ទកប្បនេះ។

**អស្សឫទ្ធិ** /អាស់-សៈ-រឹត/ *ន.* គ្រឿងឥស្សរិយាភរណៈមួយប្រភេទ។ (ម.ព. *គ្រឿងឥស្សរិយយស* ផង។)

# ល-វ-ស-ហ-ឡ-អ

អាចម៍កណ្ដុរ /អាច់-កន់-ដុល/ *ន.* (ម.ព. *ផ្ទល់*។)

អាមែកន្ទួល /អា-មែ-កន់-ទួល/ *ន.* (ម.ព. *គ្រប់មមីស*។)

ឥន្ទជា /អិន-នៈ-ជា/ *ន.* ចុល្លព្រឹក្សមួយប្រភេទមានកម្ពស់ពី៥ទៅ១៥ម៉ែត្រ ដុះតាមវាលកណ្ដាលព្រៃក្រាស់នៅឥណ្ឌូចិននិងចុងបូព៌ាប្រទេស។ ផ្លែវា គេចំរាញ់យកម្សៅទៅជ្រលក់សំពត់បានជាពណ៌លឿង ហើយ គេអាចប្រើជាឱសថទម្លាក់ព្រូន។ នៅប្រទេសឥណ្ឌា គេប្រើសំបកនិងស្លឹកជាថ្នាំបំពោកលើរោគស្បែក។

អ៊ុងអំប៊ូង /អ៊ុង-អំ-ប៊ូង/ *ន.* ឧបករណ៍តន្ត្រីមួយប្រភេទធ្វើពីឫស្សី។ វាជាឧបករណ៍តន្ត្រីរបស់ជនជាតិព្រៅនៅខេត្តរតនគិរី។ ឧបករណ៍នេះធ្វើពីថ្ងៃពីរសាច់, គេទុកថ្នាំងនៅចុងសងខាងនិងទុកថ្នាំងកណ្ដាល។ គេចិតខ្នងឫស្សីនោះគាស់មកក្រៅបន្តិចនិងដាក់កល់ឱ្យងើបឡើយដោយជន្ទល់មួយលើថ្នាំងកណ្ដាល។ គេវាយខ្សែនេះនឹងអន្លូងពីរ, អន្លូងធ្វើពីឫស្សី។ ជនជាតិព្រៅលេងឧបករណ៍ភ្លេងនេះនៅពេលប្រមូលផលដំណាំ មានដំឡូងជាដើម។

អូយណូយ /អូយ-ណូយ/ *ន.* ឈើមួយប្រភេទ មានកម្ពស់ពី៨ទៅ១០ម៉ែត្រ ដុះតាមព្រៃធំៗក្នុងប្រទេសកម្ពុជានិងវៀតណាម។ ដើមវា គេធ្វើជាក្ដារក្រាលផ្ទះ។

អូយម៉ូយ /អូយ-ម៉ូយ/ *ន.* ព្រឹក្សមួយពួកមានប្រភពមកពីអាម៉េរិកក្ដៅ ហើយត្រូវបាននាំយកទៅដាំនៅបណ្ដាប្រទេសក្ដៅដើម្បីលម្អ។ ស្លឹកជ្រុះនៅរដូវប្រាំង ហើយ នៅតំបន់អាស៊ី វាដុះតាមជាយព្រៃ។ តាមវេជ្ជសាស្ត្របុរាណផ្លែជាថ្នាំធ្វើឱ្យបរិភោគបាយបាន និង សម្រួលដល់ការបន្ទោបង់, ស្លឹក គេបុកបំពោកលើស្រែងឱ្យឆាប់ជា, សំបក គេប្រើជាថ្នាំជំនួសសំបករាជព្រឹក្ស។

អំបុក (ស្នៅ) /អំ-បុក/ *ន.* (ម.ព. *ព្រះល្វៀង*។)

អំវ៉ែត /អំ-វ៉ាត់/ *ន.* ឧបករណ៍តន្ត្រីផ្លុំមួយប្រភេទមានសូរសំឡេងនិងសណ្ឋានក្នុងពពួកភ្លយដែរ។ គេសង្កេតឃើញមាននៅប្រើតែអ្នកខេត្តមណ្ឌលគិរីនិងរតនគិរី។ អំវ៉ែត

# ល-ឝ-ស-ហ-ឡ-អ

មានបំពង់សូរប្រាំដែលគ្រាន់តែស៊កឱ្យទល់ផ្ទៃខាងក្នុងនៃឃ្លោកប៉ុណ្ណោះ។ បំពង់ឫស្សីពក គេតម្រៀប ខាងមុខបីដើម ខាងក្រោយបីដើម។

**អ្នកតាចាស់ស្រុក** /នាក់-តា-ចាស់-ស្រុក/ *ន.* ទេពតារក្សាខេត្តស្រុក។

**អ្នកតាព្រះស្រុក** /នាក់-តា-ព្រះ-ស្រុក/ *ន.* ទេពតារក្សាព្រះនគរ។

**អ្នកអង្គ** /នាក់-អង់/ *ន.* ព្រះរាជបុត្រដែលមានព្រះបិតាជាទីអ្នកអង្គម្ចាស់, រាជបុត្រ-ក្សត្រាក្សត្រីជាជាយាស្វាមីដែលមានរាជសក្តិជាទីអ្នកអង្គម្ចាស់ស្មើគ្នា។

**អ្នកអង្គម្ចាស់** /នាក់-អង់-ម្ចាស់/ *ន.* ព្រះរាជបុត្រដែលមានព្រះបិតាជាទីព្រះអង្គម្ចាស់, រាជបុត្រក្សត្រាក្សត្រីដែលមានរាជាសក្តិជាទីអ្នកអង្គម្ចាស់ស្មើគ្នា។

# ឧបសម្ព័ន្ធ ១

*សម្រង់សេចក្តីទាក់ទងនឹងឈ្មោះរុក្ខជាតិ*
*តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរមួយចំនួន*

## ១- *ព្រះវេស្សន្តរជាតក*

«ឯចំណែកភូមិឋាននោះសោត ក៏រាបស្មើប្រពៃក្រៃពេកដ៏ប្រកបនូវស្រះបោក្ខរណីផង ក៏មានឆ្នេរនោះត្រង់ មានកំពង់នោះរាបស្មើអធឹកពន្លឺ ដ៏មានទឹកនោះជ្រៅជ្រះត្រចះថ្លា ដ៏មានផ្កាកុមុទ, ឧត្បល, លំចង់, ស្បង្គ័ជ, សឹងដ៏រំលេចនូវឈូកសឈូកប្រាលណាស់ណាន់តាន់តាប់ ដ៏ប្រដាប់នូវដើមឈើផងទាំងឡាយ ជាដើមគឺ ស្វាយ, ខ្វិត, ក្រសាំង, ខ្នុរណាំង, ខ្នុរបាយស្រា, ញ្ញើ, បង្គោ, ពង្រ, ដកពណ៌, កណ្ណិការ, ពពូល, សត្បារ, ថ្មរ, ញរ, ធ្នង់, ក្លែង-គង់, បាយម៉ាត, ប៉ាង-ចចាត, ត្នាតទ្រាន, ស្តៅ, ស្តាន់, ទ្រា, ទហឹង, កំភ្លឹង, កន្ទួត, ក្រកោះ, លំពោះ, លំពាន់, ក្រវាន់, ត្រៀលស្វា, ចារ, ស្លែង, ភ្នំភ្នែង, ប្រកែងទួយ, ជ្រួយ, ខុះ, ប្រមុះ, ស្តុកស្តុរ, បុសនាគ, សំយាកសំយុងដ៏ទ្រង់នីទៅនូវផ្លែផ្កាសន្លឹកអធឹកនូវមែកនោះសាខាលូតលាស់ខៀវខ្ចី ។ (ទំ.២២)

«រីចុងអាស្រមសោត ដ៏ប្រដាប់នីទៅនូវឈើផងទាំងឡាយ ដ៏វិចិត្រនូវផ្លែផ្កានោះផ្សេងៗ ដ៏ប្រកបនីទៅនូវចេកស្នែង ចេកជងខ្នែង ចេកកាបូរ ចេកឥតត្រយូង ចេកអំបូង ចេកស្នែងពពៃ ចេករាជសីហ៍ ចេកមហាថ្លៃ ចេកម្រាមដៃនាង ចេកផែះ ចេកនួន ចេកពងមាន់ ដ៏មាននូវអំពៅតំឡាន់អំពៅក្តាម អំពៅត្រែង ដ៏ប្រកបនីទៅ នូវដំឡូងទៀន ដំឡូងទឹក ដំឡូងពងលលក ដំឡូងពងព្រវឹក ដំឡូងបាស ដំឡូងក្រាមរមាស ដំឡូងដៃខ្លាដំឡូងខ្យា ដំឡូងស្រំផ្សំនូវដំឡូងស្រូវ ដំឡូងឈាមមាន់ រាជព័ន្ធនូវដំឡូងពស់ ដំឡូងដ្វា ស្រេចសព្វគ្រប់ព្រមទាំងគ្រឿងបរិក្ខារអ្នកបួសនោះហោង។» (ទំ.១៦៦)

«តាជីអើយ យើងនឹងរាប់ឲ្យអស់សេចក្តី **អម្ពា** រីស្វាយព្រៃ ស្វាយស្រុក សឹងដ៏ដុះប្រកិត ទាំងក្រសាំងនូវខ្វិត ផ្លែដូចរំយោល រំដួល ពុទ្រា **វិភេឌកា**

សម៉ ត្រៀលស្វា កន្ទួតព្រៃ កន្ទួតស្រុក ផ្លែដូចគេចាក់គេគរ ឧទុម្ពរ ពិ្នល ញ្ញោ បង្កា បង្គោ ម័កបែន គូលែន សិរមាន់ ច័ន្ទន៍ ម័កបាត លាំងសាត ទុរេន មៀន ប្រដាក ម័កប្រេង ម័កប្រាង ម័កសាង ម័កដោក ឪឡោក ខ្ទឹងខ្ទាស់ ដូងព្រះ ស្រឡៅ តាត្រៅ ត្រៀក ត្រាច ផ្តុក ផ្ទៀក អង្កាញ់ អង្កោល កណ្ដោល កណ្ដាក់ ចម្បក់ រាំងភ្នំ ស្រគំ ពង្រ ញ ព្រីង ព្រូស ជន្លូស ក្រកោះ លំពោះ ក្រវាន់ ច័ន្ទន៍ ក្រស្នា គេកា ការកេស ចេកទេស ត្រយង់ សឹងដ៏ដុះរហង់ ដោយមាគ៌ា ។ **ចារុតិម្ពរុក្ខា** មង្ឃុត ល្មុត សេដា ពុទ្រា ផ្ចា ធ្នុង ដងអង្កាល់ អម្ព្រិល ទ្រមូង គ្រញូង ក្រឡាញ់។» ( ទំ.២២០ )

---------------------

«ហៃចៅព្រាហ្មណ៍អើយ បើព្រះស្ដែងឃ្លានអាហារ ក៏អញ្ជើញព្រះស្ដែងជ្រើសរើសរកផ្លែឈើឯណាទុំខ្ទីក្ដី ក៏មាន ទន្លាប់ ញ្ញោ បង្គោ សិរមាន់ សង្ស័រ ខ្វិត គុយ ស្រគំ ទុំល្អៗ សឹងប្រពៃ ឧត្តមប្រឡាក់នូវទឹកឃ្មុំផ្អិត អញ្ជើញព្រះស្ដែងបរិភោគចុះ ។» ( ទំ.២២៩ )

---------------------

«ព្រាហ្មណ៍អើយ រីអញ្ចាំនស អញ្ចាំនខ្មៅ អញ្ចាំនលឿង ដ៏មានផ្ការីករុងរឿងនីទៅនូវម្លិះរួត ម្លិះលា យុថ្កា ពុកធ្មា ម្រះព្រៅ លីងល័ខ ស្លឹកគ្រៃផងច្រើន ។»
( ទំ.២៤១ )

## ២- *ស័ង្ខសិល្បជ័យ*

«ក្រូចព្រៃដកម៉ៃលាយលេច រំចេករំដេច លំអងកេសររុះរោយ ។
មៀមមុំធុំក្លិនជិតដោយ ហិចហើរតាមក្រោម ត្រាច់ត្រឹបជញ្ជក់ក្លែបក្លិន ។
មានរសជាតិជាក់នូវអញ្ចាំន ក្រវាញក្រាន់ អនេកអនន្តគណនា ។»
( ទំ.១៦៨ )

## ៤. ពុទ្ធិសែន នាងកង្រី

«សរសើរដំណើរព្រៃព្រឹក្ស    លូតលាស់សន្លឹក   ត្រសាយសាខា ។
ខ្ទឹងក្ទម្ពឱជុំរកា    ពោនពួចត្រៀលស្វា បង្កៅសេរមាន់ ។
គូលែនម៉ាក់ប៉ែនណាស់ណាន់ ព្រីងព្រួសក្រវាន់  ពញាគ្រទា ។
ជ្រៃជ្រៃពួពៃពីកា    រលួសរាំងត្រ    យឹងលាយលេច ។
ក្ទូក្លងអង្គ្រងស្នែស្នាច    ត្រៀកត្រាចព្រៃព្រេច ដាស់ដុះប្រទ្បំ ។

## ៥. ហង្សយន្ត

«លំចង់ទ្រង់ផ្កាឥតផ្គង    ត្រកួនបោះទង    កំពីងពួយព័ន្ធ ។
សារាយស្បូងសាយណែនណាន់ កញ្ជែតវារវ័ណ្ឌ  ពែនព័ន្ធជ្រែកជ្រៀត ។
ត្រាវធំប្រទ្បំត្រកៀត    ដុះដាសសែមសៀត    លាស់លេចលើត្រឹប ។
ព្រឹក្សាខ្លះផ្កាខ្លះក្ដឹប    ស្រទបស្រទាប់    រុះរោយដាសដាល ។
ស្រះស្រីនាទីជ្រៅជ្រាល    សម្ដេចភូបាល   ចុះលេងគង្គា ។
ស្ដែងស្ដេចត្រេកត្រាច់លីលា    ប្រពាតព្រឹក្សា   ក្រសាលហឫទ័យ ។
កែវកោដ្ឋលៀមលោតលាំងជ័យ  ព្រីងព្រូសពោនពៃ ពួចពពាលខែ ។
ស្នែស្នាច់ព្រាលព្រេចព្រៃជ្រៃ  ទន្សាទន្សែ    ក្រួចក្រាយក្រវាន់ ។
ពញាសណ្ដាសណ្ដាន់    វល្លិ៍វើកវារវ័ណ្ឌ    សោមសន្ទៃធំ ។
ពពូលស្រល់ស្រូលសុក្រំ    រោគរាក់រាំងភ្នំ ចារចន្ទន៍ក្រស្នា ។
គ្រើលគ្រង់ខ្លែងគង់ឆាំឆា   ទន្លាប់ទន្លា ដង្កៀបក្ដាមក្ដុល ។
ត្រសេកត្រមែងត្រមល់ ស្ដីស្ដៅស្ដុកស្ដុរ ភ្ញាសស្នោងស្នួលស្នាយ ។
ពង្រូដកពដកពាយ  រលួសរលោយ    រលួសផ្ដុងផ្កាវ ។
ពពេលស្នាយដែលខ្ទឹងខ្ទារ    បង្កៅបង្ការ   សម្បុរល្វែងល្វា ។

ចេកទេសកាកែសកណិការ    ដង្កោក្ដាំងងា     ដុះដូចគេចារ ។ ( ទំ. ៣៦ )

## *៦. មរណមាតា*

«ព្រះបទុមវង្ស    យល់បិតាទ្រង់
ក្រសាលព្រឹក្សា    អ្នកយាងចូលជិត
នៃបនិត្យបិតា    រៀបរាប់ព្រឹក្សា
ថ្វាយក្សត្រពណ្ណរាយ ។

ធូរេន[1]មង្ឃុត    ក្រូចក្រាយស្វាយល្មុត
ដកពដកពាយ    ដើមដុះទាបស្រាប់
លូកចាប់បេះងាយ    ផ្លែទុំជ្រុះរាយ
ដោយដីត្រៀបត្រា ។

ពួកពលទាំងឡាយ    បេះស៊ីរែកស្ពាយ
ពាសពេញព្រឹក្សា    មាក់ប៉ែនចេកចាន់
សិរមាន់សេដា    មៀនទៀបត្រៀលស្វា
សន្ដាន់សន្ទៃ ។

ផ្លែប្រាលទែងទុំ    ផ្អែមដូចទឹកឃ្មុំ
ដុះដាសពាសព្រៃ    មើលយល់សឹងយប់
ជាម្លប់ត្រឈៃ    ផ្លែទាបលូកដៃ
បេះបានភោក្តា ។

មាក់ប្រេងមាក់ប្រាង    មាក់ដោកមាក់សាង
ក្រូចក្រាយនានា    ទ្រមូងក្រវាន់
តាប់តាន់ត្រៀបត្រា    ទម្លាប់[2]ទន្លា
ទ្រមែងព្រីងព្រូស ។

[1] តាមវចនានុក្រមខ្មែរ គឺ **ទុរេន** ។

[2] តាមវចនានុក្រមខ្មែរ គឺ **ទន្លាប់** ។

ពង្រពង្រៀង ដើមល្វរវៀង
ឪជ្រឹងជន្លួស បង្គាបង្គៅ
សារម៉ាវខ្ទឹងក្នុម្ព ខ្ទិតខ្ទាវស្រគំ
រាំងរោគព្ធិលញ្ចៅ ។
ក្រខុបក្រឡាញ់ អង្កោលអង្កាញ់
អំពិលអំពៅ ឪឡឹកឪឡោក
មាក់ដោកដុះនៅ ម្រុមម្រោមម្រះម្រៅ
ត្រឡកត្រឡាត់ ។
ផ្លែទុំពាសវាល ខ្លះទុំស្រគាល
ខ្លះក្តិបច្រើនក្តាត់ ខ្លះទុំដោកដាំ
សត្វពាំខ្ចាយខ្ចាត់ ជ្រុះដែលមាត់សត្វ
ដោយដីពេញពាស ។
ស្វាយស្វាយក្បាល- ដំរីទុំប្រាល
ស្វាយមីងស្វាយមាស ស្វាយឥន្ទលាំ
ជ្រុះខ្ចាំពេញពាស ស្វាយក្រាមរមាស
ក្បាលសេះពងអង្រ្កង ។» (ទំ.២១៩-២២០)

## *៧. ស្រទបចេក*

«ខ្លះបេះប្រឡេះផ្លែស្វាយ ដណ្តើមប្រញាយ ទ្រហឹងអឹងកង ។
ខ្លះបេះប្រឡេះដំបង បានស្រេចហើយហោង ហៅគ្នាជួយយក ។
ខ្លះចេះឡើងបេះពង្រ ខ្លះរើសដាក់គរ ទុកចាំចែកគ្នា ។
ខ្លះបេះប្រឡេះពុទ្រា ខ្លះបេះផ្លែល្វា ទាំងខ្ចីទាំងទុំ ។
ខ្វះវេះចូលព្រៃស៊ុមទ្រុម ប្រទះឃើញឃ្មុំ ត្រតោកយោកស្វា ។
អំពាវស្រែកហៅគ្នីគ្នា ថារ៉ឺយអាជា មករ៉ឺយយកឃ្មុំ។
ខ្លះព្យហើយដើរចូលចំ ឃើញដាក់សម្ងំ នាំគ្នាយកបាន ។
នាំខ្មីថ្វាត់ថ្វាយក្សត្រក្សាន្ត ស្រេចទ្រង់ប្រោសប្រាណឲ្យ មានយសសក្តិ។

ខ្លះដើរលលើតាមស្ទ័គ្រ    ឃើញផ្លែប្រដាក់    បោចបេះមកដក់ ។
ខ្លះចេះរើសឯចម្បក់    ដាក់ពេញទាំងថ្នក់    សុទ្ធសឹងតែគ្រាប់ ។
ខ្លះថ្កានបេះបានទន្លាប់    យកមករើសរាប់    បានជាងមួយពាន់ ។
នាំថ្វាត់ថ្វាយក្សត្រសោភ័ណ ស្ដេចឲ្យរង្វាន់    ប្រាក់មួយជញ្ជីង ។
ខ្លះបេះប្រឡេះផ្លែព្រីង    ទុំខ្មៅរលីង    រលោងស្រិលស្រស់ ។
ខ្លះដែកបែកមែកចេញស្មោះ ដើរដោយចន្លោះ    ចម្លងហួសខ្នាត ។
បៀតបែរឃើញផ្លែលាំងសាត ខិតខំសង្វាត    បេះបានក្រែលគ្រាន់ ។
ខ្លះដើរលលើរួសរាន់    ឃើញផ្លែសិរមាន់    សាវម៉ាវមង្ឃុត ។
បេះចេកគ្នារែកប្រយុត    ខ្លះឃើញផ្លែល្មុត    បោចបេះបានរែក ។
ខ្លះបេះប្រឡេះត្របែក    ខ្លះស្ទុះជ្រៀតជ្រែក    បេះបានផ្លែភ្លៀវ[3] ។
ស្រែកស័ព្ទអឺងកងខ្វារខ្សៀវ កញ្ច្រោកកញ្ច្រៀវ    រំពងព្រៃភ្នំ ។
ខ្លះបេះប្រឡេះស្រគំ    រើសបានទុំៗ    ទុកថ្វាយក្សត្រា ។

(ទំ.៣៦៤-៣៦៥)

## *៨. ទុំទាវ*

«មើលមានជ្រៃជ្រែសង្កែថ្វាន់    ត្រៀលត្រស់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ទម្ព    ទ្រនំអាអូដ្ឋចង្ហូរត្នោត ។
ដង្កោទ្រយឹងខ្ទឹងក្រសាំង    អំពិលក្លូងភ្លាំងទាំងភ្លូបាត
គូលែនទុរេនមៀនលាំងសាត    មាក់បាតបង្គោញៀចាន់ចារ ។
ត្របែកត្រសេកអំបែងថ្ងៃ    អង្គ្រងស្នាច់ស្នែរោគរកាក្រូច
ក្រាយស្វាតស្វាយត្រាចត្រៀលស្វា សេដាសណ្ដាន់ថ្វាន់ជ្រៃជ្រែ ។
មានទាមងដកពាយវាយដកព    សង្ស័រពង្ររាក់រាំងស្មី
ភ្នំភ្នែងផ្ចៃស្រែងលោតលាំងដៃ    សន្ទែក្រខុបងប់ក្រឡាញ់ ។

---
[3] តាមវចនានុក្រមថ្មី គឺ **ផ្លៀវ** ។

ប្រមាសបុស្បនាគត្រកែងទូយ ប្រផេញគោមួយឈើទាលត្រាញ់
រាជធ្លីសផ្មេញត្រីវែរអញ្ចាញ អង្កាញ់អង្កោលកណ្តោលបាត ។
ត្រាចត្រៀកចង្រៀកប្រេសខ្ទឹមក្តម្ព គគីរាំងភ្នំបេងបាយម៉ាត
ស្តុកស្តុរស្តីស្តៅត្រាវក្តួចក្តាត លាំងសាតសត្បារកាស្រល់ ។»

( ទំ. ៦១ )

.....................................

«ប្រាប់ស្នងបាឡាត់ចាត់មេស្រុក រកជ្រូកព្រៃកុកគោមាន់ទា
ផែប៉ូវខ្ទឹមម្រេចជំឡូងផ្គា គ្រឿងភ្លាផ្អីផ្អីជីរបារាំង ។
គ្រឿងទេសគ្រឿងតែងបន្លែគ្រប់ ទុកមនុស្សប្រសព្វទិញស្រាខ្លាំង
សាច់ក្រកសាបក្រៀមសាច់ចៀមអាំង បបែលទំពាំងក្រសាំងខ្យង ។
គ្រប់ម្ទេសស្លឹកគ្រៃខ្ទីរំដេង ក្រអៅរលីងឈូកសម្រង
ស្លែក្តោបស្លែលាភ្លាអង្រ្កង បង្កងស្នងគោនួវខ្ទុរល្មុង ។»

( ទំ. ៩៧ )

# ឧបសម្ព័ន្ធ ២

*សម្រង់ឈ្មោះរុក្ខជាតិ*

*ពីវចនានុក្រមខ្មែរ គ.ស.១៩៦៧-៦៨*

ក

| | |
|---|---|
| កក់ ២ | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| កកោះ | ឈ្មោះឈើមួយប្រភេទ។ |
| កញ្ជើបាយដាច | ឈ្មោះឈើមួយប្រភេទ |
| កញ្ច្រៀប | ឈ្មោះត្រសក់ផ្អែរយ៉ាងតូច។ |
| កណិការ | ឈ្មោះឈើផ្កាមួយប្រភេទ។ |
| កណ្ដក់ ៣ | ឈ្មោះឈើមួយប្រភេទ។ |
| កណ្ដាប់ចង្កេរ | ឈ្មោះឈើវល្លិមួយប្រភេទ។ |
| កណ្ដឹងគោ ឬ កណ្ដឹងដំរី | ឈ្មោះលតាជាតិមួយប្រភេទ។ |
| កណ្ដៀរខ្វេត | ឈ្មោះវល្លិមួយប្រភេទ។ |
| កណ្ដៀង | ឈ្មោះវារិតិណជាតិ។ |
| កណ្ដាល | ឈ្មោះឈើមួយប្រភេទ។ |
| កណ្ដាលបាត | ឈ្មោះឈើមួយប្រភេទ។ |
| កន្ទុលឱ | ឈ្មោះវល្លិព្រៃមួយប្រភេទ។ |
| កន្ទូទ្បេត | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| កន្ទ្រើយ | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| កន្ទី | ឈ្មោះឈើតូចមួយប្រភេទ។ |
| កន្ទុយប្រពើ | ឈ្មោះប្រទាលមួយប្រភេទ។ |
| កន្ទុយចចក | ឈ្មោះស្មៅរណ្ដាសមួយប្រភេទ។ |
| កន្ទុយឆ្កែ | ឈ្មោះស្មៅមួយប្រភេទ។ |
| កន្ទុយដំរី ១ | ឈ្មោះស្មៅមួយប្រភេទ។ |
| កន្ទួត ១ | ឈ្មោះឈើមានផ្លែមានរសជូរ។ |
| កន្ទួតប្រោង | ឈ្មោះឈើតូចមួយប្រភេទ។ |

| | |
|---|---|
| កន្ទួតព្រៃ | ឈ្មោះឈើព្រៃ។ |
| កន្ទេចអាល ២ | ឈ្មោះតិណជាតិមួយប្រភេទ។ |
| កន្ទែក | ឈ្មោះត្រកួនមួយប្រភេទ។ |
| កន្ទាំងហែ | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| កន្ទ្រង់ | ឈ្មោះឈើតូចមួយប្រភេទ។ |
| កន្ទ្រោក | ឈ្មោះឈើមួយប្រភេទ។ |
| កន្ទ្រោកង៉ើរ | ឈ្មោះឈើមួយប្រភេទ។ |
| កន្លងភ្នំ | ឈ្មោះវល្លិមួយប្រភេទ។ |
| កន្លើតចក | ឈ្មោះវល្លិមួយប្រភេទ។ |
| កប្បព្រឹក្ស ( សំ. *កល្បវ្រក្ស* ) | ឈ្មោះឈើវិសេសមួយប្រភេទ។ |
| កប្បាស ( បា. ) | ឈ្មោះឈើតូចមួយប្រភេទ។ |
| កុលាប | ឈ្មោះដើមផ្កាមួយប្រភេទ។ |
| កូវកែ | ដូងមួយប្រភេទ។ |
| កែស ១ | ឈ្មោះឈើមួយប្រភេទ។ |
| កោដ្ឋ | ឈ្មោះឈើមួយប្រភេទប្រើជាថ្នាំ។ |
| កំញាន | ឈ្មោះឈើមួយប្រភេទ។ |
| កំប៉ែត ១ | ឈ្មោះឈើមួយប្រភេទ។ |
| កំប្លោក | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| កំពីងពួយ | ស្មៅវារដុះអណ្តែតលើទឹក។ |
| កំភ្លឹង | ឈ្មោះប្រទាលមួយប្រភេទ។ |
| ក្បោក ២ | ឈ្មោះឈើមួយប្រភេទ។ |
| ក្តាត | ឈ្មោះដំណាំជាបន្លែមួយយ៉ាង។ |
| ក្តុល | ឈ្មោះឈើមួយប្រភេទ។ |

| | |
|---|---|
| ក្តួច | ឈ្មោះវល្លិមើមមួយប្រភេទ។ |
| ក្តោប ២ | ឈ្មោះស្លែមួយយ៉ាង។ |
| ក្តាំងងា | ឈ្មោះឈើមួយប្រភេទ។ |
| ក្នុម្ត | ឈ្មោះឈើមួយប្រភេទ។ |
| ក្នុម្តទេស | ឈ្មោះឈើមួយប្រភេទ។ |
| ក្រកី | ឈ្មោះប្រទាលមួយប្រភេទ។ |
| ក្រកោ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ក្រខុប | ឈ្មោះឈើមានផ្លែបរិភោគបាន។ |
| ក្រចកអណ្តើក | ឈ្មោះចេកនួនមួយប្រភេទ។ |
| ក្រចកអណ្តើក | ឈ្មោះឈើភ្នំមួយប្រភេទ។ |
| ក្រចកចាប | ឈ្មោះស្រូវខ្សាយមួយប្រភេទ។ |
| ក្រចាប់ | ឈ្មោះសេវាលជាតិមួយប្រភេទ។ |
| ក្រចេះ ១ | ឈ្មោះម្សៅក្រអូប។ |
| ក្រថៅ ២ | ឈ្មោះតិណជាតិ។ |
| ក្របៅ ១ | ឈ្មោះឈើមួយប្រភេទ។ |
| ក្រពាត់ជ្រូក | ឈ្មោះតិណជាតិមួយប្រភេទ។ |
| ក្រពេន | ឈ្មោះឈើមួយប្រភេទ។ |
| ក្រមម ២ | ឈ្មោះវល្លិមួយប្រភេទ។ |
| ក្រវាញ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ក្រវាញជ្រូក | ឈ្មោះស្មៅមួយប្រភេទ។ |
| ក្រវាន់ | ឈ្មោះឈើមួយប្រភេទ។ |
| ក្រសាំង | ឈ្មោះឈើមួយប្រភេទ។ |
| ក្រសាំងទាប | ឈ្មោះអន្លក់មួយប្រភេត។ |

| | |
|---|---|
| ក្រសាំងទំហំ | ឈ្មោះដង់ណាំមួយប្រភេទ។ |
| ក្រស្នា | ឈ្មោះរុក្ខជាតិមួយយ៉ាង។ |
| ក្រាមរមាស | ឈ្មោះគ្រប់មួយប្រភេទ។ |
| ក្រាមរមាស | ឈ្មោះឈើមួយប្រភេទ។ |
| ក្រឹម | ឈើជ្រៃមួយប្រភេទ។ |
| ក្រែក | ឈ្មោះផ្កៅមួយប្រភេទ។ |
| ក្រោះរមាស | ឈ្មោះឈើមួយប្រភេទ។ |
| ក្លាំពាក់ | ឈ្មោះខ្លឹមឈើធ្វើប្រាណ។ |
| ក្អែក | ឈ្មោះតាសក់ពុលមួយប្រភេទ។ |

## ខ

| | |
|---|---|
| ខណ្ឌស្ករ | ឈ្មោះស្វាយមួយប្រភេទ។ |
| ខាបខា | ឈ្មោះប្រទាលមួយប្រភេទ។ |
| ខារ ៣ | ឈ្មោះត្រប់មួយប្រភេទ។ |
| ខោស | រុក្ខជាតិមួយប្រភេទ។ |
| ខ្វាស់ | ឈ្មោះឈើមួយប្រភេទ។ |
| ខ្ទូវ | រុក្ខជាតិមួយប្រភេទ។ |
| ខ្នាយ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ខ្ញី ១ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ខ្វែក | ឈ្មោះវល្លិមួយប្រភេទ។ |
| ខ្វែរ | ឈ្មោះវល្លិមួយប្រភេទ។ |
| ខ្វែរ | ឈ្មោះល្ហុងមួយប្រភេទ។ |
| ខ្ទឹង | ឈ្មោះឈើមួយប្រភេទ។ |
| ខ្ទឹម | ឈ្មោះប្រទាលមួយប្រភេទ។ |
| ខ្នុរ | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| ខ្នុរសម្ល | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| ខ្នាញ់ ២ | ឈ្មោះស្មៅមួយប្រភេទ។ |
| ខ្វង | ឈ្មោះល្ហុងមួយប្រភេទ។ |
| ខ្វាវ | ឈ្មោះឈើភ្នំមួយប្រភេទ។ |
| ខ្វាវ | ឈ្មោះឈើតូចមួយប្រភេទ។ |
| ខ្វិត ១ ( បា. *កបិដ្ឋ* ) | ឈ្មោះឈើមានផ្លែបរិភោគបាន។ |
| ខ្វែត | ឈ្មោះឈើមួយប្រភេទ។ |
| ខ្សួស | ឈ្មោះឈើតូចមួយប្រភេទ។ |
| ខ្សេវ ១ | ឈ្មោះឈើមួយប្រភេទ។ |

## គ

| | |
|---|---|
| គគីរ | ឈ្មោះឈើធំមួយប្រភេទ។ |
| គគីត | ឈ្មោះឈើមួយប្រភេទ។ |
| គុយ | ឈ្មោះឈើតូច។ |
| គូឆាយ | ឈ្មោះបន្លែមួយប្រភេទ។ |
| គូលែន ១ | ឈ្មោះឈើមួយប្រភេទ។ |
| គៃលលក | ឈ្មោះស្មៅមួយប្រភេទ។ |
| គ្រង់ | ឈ្មោះឈើមួយប្រភេទ។ |
| គ្រញូង | ឈ្មោះឈើមួយប្រភេទ។ |
| គ្រលែងវែក | ឈ្មោះឈើមួយយ៉ាងដើមតូច។ |
| គ្រែប ១ | ឈ្មោះឈើតូចមួយប្រភេទ។ |

# ឃ

| | |
|---|---|
| **ឃិនឆាយ ឬ ឃុយឆាយ** | ឈ្មោះបន្លែចិនមួយយ៉ាង។ |
| **ឃ្មង់** | ឈ្មោះឈើមួយប្រភេទ។ |
| **ឃ្មត់** | ឈ្មោះវល្លិមួយប្រភេទ។ |
| **ឃ្លាយបាត** | ឈ្មោះវល្លិតូចមួយប្រភេទ។ |
| **ឃ្លេ** | ឈ្មោះឈើនោមមួយប្រភេទ។ |
| **ឃ្លៃ ១** | ឈ្មោះឫស្សីមួយពួក។ |
| **ឃ្លោក** | ឈ្មោះវល្លិឡើងទ្រើង។ |

## ឧបសម្ព័ន្ធ ២

**ងប់ ២** ឈ្មោះឈើតូចមួយប្រភេទ។

## ច

| | |
|---|---|
| ចក ១ | សេវាលជាតិពួកមួយ។ |
| ចង្កុលណី | ឈ្មោះវារិជជាតិមួយប្រភេទ។ |
| ចង្កូមស្កា | រុក្ខជាតិមួយប្រភេទដើមតូច។ |
| ចង្គ្រង់ស្វា | តិណជាតិមួយប្រភេទដើមតូចៗ។ |
| ចង្អូរត្នោត | ឈ្មោះឈើមួយប្រភេទ។ |
| ចចូត | ឈ្មោះស្មៅមួយប្រភេទ។ |
| ច័ន ឬ ចាន់ | ឈ្មោះឈើមានផ្លែ។ |
| ចន្ទន៍ | ឈ្មោះឈើ។ |
| ចន្ទី | ឈ្មោះស្វាយមួយប្រភេទ។ |
| ច័ន្ទូ | ឈ្មោះតិណជាតិ។ |
| ចាក ១ | ឈ្មោះឈើតចសារជាតិមួយប្រភេទ។ |
| ចាក់ក្រឡេក | ឈ្មោះឈើតូចមួយប្រភេទ។ |
| ចាក់ក្រឡេក | ឈ្មោះស្មៅមួយប្រភេទ។ |
| ចាព្លូ | ឈ្មោះតិណជាតិមួយប្រភេទ។ |
| ចារ ២ | ឈ្មោះឈើមានផ្កាសម្បុរក្រហម។ |
| ចិត្រមូលភ្លើង | ឈ្មោះតិណជាតិដើមតូចៗ។ |
| ចុងអង្គរ | ឈ្មោះលតាជាតិមួយប្រភេទ។ |
| ចេក | ឈ្មោះដំណាំមានស្លឹកប្រើការ មានផ្លែជាអាហារ។ |
| ចេកទេស | ឈ្មោះប្រទានមួយប្រភេទ។ |
| ចេកទុំ | ឈ្មោះឈើសន្តានវល្លិឡើងទ្រើង។ |
| ចែង ១ | ឈ្មោះឈើមួយប្រភេទ។ |

| | |
|---|---|
| **ចំបក់** | ឈ្មោះឈើធំមួយប្រភេទ។ |
| **ចំប៉ី** | ឈ្មោះឈើមានជ័រស។ |
| **ចំប៉ីទេស** | ចំប៉ីដែលមានផ្កាតូចៗ។ |
| **ចំពុះទា** | ឈ្មោះតិណជាតិមួយប្រភេទ។ |
| **ច្បា** (សំ. បា. *ជបា*) | ឈ្មោះឈើផ្កាមួយប្រភេទ ផ្កាឥតក្លិន។ |
| **ប្រាច់** | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| **ប្រេស** | ឈ្មោះឈើមួយប្រភេទ។ |

## ឆ

| | |
|---|---|
| **ឆត្ររួត** | ឈ្មោះហរិតជាតិមួយប្រភេទ។ |
| **ឆៃថាវ** | ដំណាំមួយប្រភេទពួកស្ពៃ។ |
| **ឆាំឆា** | ឈ្មោះឈើមួយប្រភេទ។ |
| **ឆ្កែស្រែង** | ឈ្មោះឈើមួយប្រភេទសំបកក្រាស់។ |
| **ឆ្អាល់មាន់** | ឈ្មោះឈើនាមមួយប្រភេទ។ |
| **ឆ្វេះ ១** | ឈ្មោះដំរមានពិស។ |

## ជ

| | |
|---|---|
| ជណ្ដើរស្វា | វល្លិមួយប្រភេទ។ |
| ជន្លង់ | ឈ្មោះវល្លិឡើងទ្រើងមួយពួក។ |
| ជន្លាត់ដៃ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ជន្លូស | ឈ្មោះឈើមួយប្រភេទ។ |
| ជន្លួញបរ | ឈ្មោះឈើមួយប្រភេទ។ |
| ជម្ពូ ១ (សំ. បា.) | ព្រីង។ |
| ជម្ពូ ២ | ឈ្មោះឈើពួកមួយ ផ្លែប្រើជាអាហារ។ |
| ជម្ពូ ២ | ឈ្មោះឈើតូចមួយប្រភេទផ្សេងទៀត។ |
| ជើងចាប | ឈ្មោះឈើធំមួយប្រភេទ។ |
| ជើងចាប | ឈ្មោះឈើតូចមួយប្រភេទផ្សេងទៀត។ |
| ជើងមាន់ | ឈ្មោះដើមផ្កាមួយពួក។ |
| ជើងមាន់ | ឈ្មោះសារាយមួយប្រភេទ។ |
| ជ្រៃ ១ | ឈ្មោះឈើជាតចសារជាតិមួយប្រភេទ។ |

## ឈ

| | |
|---|---|
| ឈើកែវ | ឈ្មោះឈើមួយប្រភេទ។ |
| ឈើខ្មៅ | ឈ្មោះឈើមួយប្រភេទ។ |
| ឈើទាល | ឈ្មោះឈើមួយប្រភេទ។ |
| ឈើទាលត្រាញ់ | ឈើធំមួយប្រភេទ។ |
| ឈើទាលត្រាញ់ | ឈ្មោះឈើមួយប្រភេទទៀត។ |
| ឈើភ្លើង | ឈ្មោះឈើមួយប្រភេទ។ |
| ឈើអែម | ឈ្មោះឈើឬវល្លិដើមធំ។ |
| ឈៃ្ម | ឈ្មោះត្រសក់ល្វីងមួយប្រភេទ។ |
| ឈ្លីក | ឈ្មោះដើមឈើ។ |
| ឈ្វាំង | ឈ្មោះផ្តៅមួយប្រភេទ។ |

# ញ

ញ ១ ឈ្មោះឈើមានផ្លែ។

## ដ

| | |
|---|---|
| ដកខិម | ឈ្មោះឈើតូចមានផ្កា។ |
| ដកគាំ | ឈ្មោះផ្កាពណ៌ក្រហមស្រគាំ។ |
| ដកព | ឈ្មោះឈើមួយប្រភេទ។ |
| ដកពាយ | ឈ្មោះវល្លិធំមួយប្រភេទ។ |
| ដកម៉ែ | ឈ្មោះឈើពួកជម្ពូ។ |
| ដងដឹង | ឈ្មោះឈើមួយ ។ |
| ដងដឹង | ឈ្មោះប្រទាលមួយប្រភេទ។ |
| ដង្កោ | ឈ្មោះឈើមួយប្រភេទ។ |
| ដង្កោខ្មោច | ឈើមួយប្រភេទ។ |
| ដង្ខិត | ឈ្មោះឈើតូច។ |
| ដាង ២ | ឈើដំណាំស្រុកមួយប្រភេទ។ |
| ដឺប្លី | ឈ្មោះវល្លិឡើងជន្លង់មួយប្រភេទ។ |
| ដឺស | ឈ្មោះវល្លិមួយប្រភេទ។ |
| ដូង | ឈើស្រុកមានផ្លែជាអាហារ។ |
| ដូងចែម | ឈ្មោះឈើមួយប្រភេទ។ |
| ដូងព្រះ | វល្លិមានផ្កាតូចៗ។ |
| ដៀប | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| ដៃខ្លា | ឈ្មោះឈើមួយប្រភេទ។ |
| ដៃរហាត់ | ឈ្មោះឈើមួយប្រភេទ។ |
| ដោះគន់ | ឈ្មោះវល្លិមួយប្រភេទ។ |
| ដំបង | ឈ្មោះផ្តៅធំមួយប្រភេទ។ |
| ដំបងគ្រញូង | ឈ្មោះកុកមួយប្រភេទ។ |

| | |
|---|---|
| **ដំបងយក្ស ឬ ដំបងយក្ខ** | ឈ្មោះប្រទាលមួយប្រភេទ។ |
| **ដំរែក** | ឈ្មោះក្រូចមួយប្រភេទ។ |
| **ដំឡាន់ ២** | ឈ្មោះអំពៅមួយប្រភេទដើមធំៗ។ |
| **ដំឡូង** | វល្លិមានមើមប្រើជាអាហារ។ |

## ឱ

**ឱឱិម** ឬ **ឱលិម** (សំ.) ទទឹម, ផ្លែទទឹម។

## ត

| | |
|---|---|
| **តង្កៀបក្ដាម** | ឈ្មោះឈើមួយប្រភេទ។ |
| **តម្ពុល** ( បា. ) | ស្លា, ផ្លែស្លា។ |
| **តាត្រៅ** | ឈ្មោះឈើធំមួយប្រភេទ។ |
| **តែ ២** ( ចិ. *តេ* ) | ឈ្មោះឈើពួកមួយ។ |
| **តោតម៉ា** | ឈ្មោះឈើតូចមួយប្រភេទ។ |
| **តាំងឱ** ( ចិ. *តាំងអ៊ូ* ) | ឈ្មោះដំរមួយប្រភេទ ពូជមកពីប្រទេសចិន។ |
| **ត្នោត** | ឈ្មោះដំណាំតចសារជាតិមួយប្រភេទ។ |
| **ត្បាល់កិន** | ឈ្មោះឈើតូចមួយប្រភេទ។ |
| **ត្បាល់ដែក** | ឈ្មោះឈើតូចមួយប្រភេទ ជាគូគ្នានឹងដើមអង្រែដែក។ |
| **ត្រកួន** | ឈ្មោះវល្លិវារិជាតិមួយពួក។ |
| **ត្រកៀត** | ឈ្មោះស្មៅទឹកពួកត្រាវ។ |
| **ត្រកៀតប៉ោង** | ឈ្មោះស្មៅទឹកពួកត្រកៀត។ |
| **ត្រចៀកកណ្ដុរ** | ឈ្មោះផ្សិតដុះនឹងដើមឈើ។ |
| **ត្រចៀកដំរី** | ឈ្មោះដំរមួយប្រភេទ។ |
| **ត្រដិត** | ឈ្មោះវល្លិរំអិលមួយប្រភេទ។ |
| **ត្រថុក ឬ តាថុក** | ឈ្មោះប្រទាលមួយប្រភេទ។ |
| **ត្របឿង ឬ តាបឿង ១** | ឈ្មោះស្មៅពួកផ្អែ, ពួកក្រចៅ។ |
| **ត្របឿង ឬ តាបឿង ២** | ឈ្មោះប្រទាល។ |
| **ត្រប់** | ឈ្មោះដំណាំមានផ្លែបរិភោគជាបន្លែ។ |
| **ត្រប់ទុំ** | ឈ្មោះឈើធំមួយប្រភេទ។ |
| **ត្របែក** | ឈ្មោះឈើពួកមួយ។ |
| **ត្របែកជូរ** | ឈ្មោះឈើព្រៃនាមមួយប្រភេទ។ |

| | |
|---|---|
| ត្របែកព្រៃ | ឈ្មោះឈើមួយប្រភេទ។ |
| ត្រលាត់ ឬ ត្រឡាត់ | ឈ្មោះឈើធំមួយប្រភេទ។ |
| ត្រស់ | ឈ្មោះឈើនោមមួយប្រភេទ។ |
| ត្រឡក | ឈ្មោះឈើធំមួយប្រភេទ ពួកត្រឡាត់។ |
| ត្រឡាច ១ | ឈ្មោះវល្លិស្រុកមួយប្រភេទ។ |
| ត្រាង | ឈ្មោះជ្រៃមានស្លឹកធំៗទ្រវែងស្រួច។ |
| ត្រាច | ឈ្មោះឈើធំពួកឈើទាល។ |
| ត្រាច់ ២ | ឈ្មោះឫស្សីភ្នំមួយប្រភេទ។ |
| ត្រោកសាញ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ត្រុំ ១ | ឈ្មោះដំណាំដើមតូច។ |

## ថ

**ថ្ងូ** ឈ្មោះឈើមួយប្រភេទ។

**ថ្នឹង** ឈ្មោះវល្លិមួយប្រភេទ។

**ថ្លាញ់** ឈ្មោះឈើមួយប្រភេទ។

**ថ្លើមអណ្តើក** ឈ្មោះឈើនោមមួយប្រភេទ។

**ថ្វាង** ឈ្មោះត្រែងស្លឹកធំ។

## ទ

| | |
|---|---|
| ទទឹម (សំ.) | ឈ្មោះឈើមួយប្រភេទ។ |
| ទន់ដី | ឈ្មោះឈើតូចមួយប្រភេទ។ |
| ទន្រ្ទានខេត្ត, ខែត្រ | រុក្ខជាតិមួយប្រភេទ។ |
| ទន្លា | ឈ្មោះឈើមួយប្រភេទ ពួកថ្ងាន់។ |
| ទន្លាប់ | ឈ្មោះឈើធំមួយប្រភេទ។ |
| ទន្លឹង | ឈ្មោះវល្លិធំមួយប្រភេទ។ |
| ទន្សា ២ | ឈ្មោះឈើតូចមួយប្រភេទ។ |
| ទន្សែ | ឈ្មោះឈើមួយប្រភេទ។ |
| ទន្លាយរត | ឈ្មោះប្រទាលផ្ញើប្រាណ។ |
| ទម្លាយស្នង | ឈ្មោះឈើតូចមួយប្រភេទ។ |
| ទាស ២ | ឈ្មោះវល្លិព្រៃមួយប្រភេទ។ |
| ទិល ឬ ទឹល | ឈ្មោះស្មៅមួយប្រភេទ។ |
| ទុរេន | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| ទុរេន | ឈ្មោះស្វាយមួយប្រភេទ។ |
| ទៀប ១ | ឈ្មោះឈើដំណាំពួកមាក់បាត។ |
| ទំពូង | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ទំពាំងជូរ ឬ ទំពាំងបាយជូរ | ឈ្មោះវល្លិមានផ្លែជាចង្កោម។ |
| ទ្រមូង | ឈ្មោះឈើមានផ្លែប្រើជាម្ជូរស្ល។ |
| ទ្រមូងសេក | ឈ្មោះឈើមួយប្រភេទ។ |
| ទ្រមែង | ឈ្មោះឈើមួយប្រភេទ។ |
| ទ្រមាំង | ឈ្មោះដើរមួយប្រភេទ។ |
| ទ្រយឹង | ឈ្មោះឈើមួយប្រភេទ។ |

| | |
|---|---|
| **ទ្រលឹងទឹង** | ឈ្មោះឈើមួយប្រភេទ។ |
| **ទ្រាស** | ឈ្មោះឈើមួយប្រភេទ។ |
| **ទ្រៀល** | ឈ្មោះឈើតូចនិងវល្លិដើមរឹង។ |
| **ទ្រាំង ២** | ឈ្មោះតចសារព្រឹក្សមួយប្រភេទ។ |

## ឆ

**ឆ្នង់**　　ឈ្មោះឈើមួយប្រភេទមានខ្លឹម។

**ឆ្មេញត្រី**　　ឈ្មោះឈើតូចមួយប្រភេទ។

**ឆ្មៅ ឬ ខ្វូរ**　　ឈ្មោះប្រទាលមួយប្រភេទពួកទាល់។

**ឆ្លូក**　　ឈ្មោះឈើមួយប្រភេទពួកចំបក់។

## ន

| | |
|---|---|
| **នគរជុំ** | ឈ្មោះប្រទាលមួយប្រភេទ។ |
| **ននោង** | ឈ្មោះវល្លិដំណាំឡើងទ្រើង មានផ្លែជាអាហារ។ |
| **ននោងព្រៃ** | ឈ្មោះវល្លិដូចននោងដែរ។ |
| **នាងប្រាល** | ឈ្មោះធំមួយប្រភេទ។ |
| **នាងដែង** | ឈ្មោះឈើធំមួយប្រភេទ។ |
| **នាងនក់** | ឈ្មោះដំឡូងព្រៃមួយប្រភេទ។ |
| **នាងនួន** | ឈ្មោះឈើសាច់រឹងមានខ្លឹមធំ ពួកគ្រញូង។ |
| **នាងផ្អែក** | ឈ្មោះឈើធំ ពួកគគីរ។ |
| **នាងវង** | ឈ្មោះជីរ ១ ប្រភេទ។ |
| **នាងស្វាយ** | ឈ្មោះប្រទាលមួយប្រភេទ។ |
| **នារីផល** | ឈ្មោះឈើមានផ្លែរូបដូចជាស្រីក្រមុំ។ |
| **នី** | រុក្ខជាតិមួយប្រភេទ។ |

## *ប*

| | |
|---|---|
| បង្គៅ | ឈ្មោះឈើមួយប្រភេទ មានផ្លែបរិភោគបាន។ |
| បបុស ឬ ប្របុស | ឈ្មោះស្មៅខ្ពស់ៗ។ |
| បាយក្តាំង ១ ឬ ក្តាំងបាយ | ឈ្មោះឈើតូចពួកមួយ។ |
| បាយដំណើប | ឈ្មោះស្មៅដើមរឹង។ |
| បាយដំណើប | ឈ្មោះឈើតូចមួយប្រភេទមានបន្លាសណ្ឋានប្រដៀងនឹងតម្កក់។ |
| បំពង់ករឿង ឬ បំពង់រឿង | ឈ្មោះឈើមួយប្រភេទ ផ្លែតូចៗ។ |
| ប៉ប្រក | ឈ្មោះប្រទាលផ្ទើប្រាណមួយ។ |
| ប៉ប្រឹស ១ ឬ ប៉ប្រើស | ឈ្មោះវល្លិមួយប្រភេទ។ |
| ប៉េងប៉ោះ | ឈ្មោះវល្លិដើមទាបពួកមួយ។ |
| ប៉ិក្ខះ (ចិ.) | មើលក្នុងពាក្យ *រលួស* ត្រង់ពាក្យ *ដំឡូងរលួស*។ |
| ប្រក់ផ្លែ | ឈ្មោះស្មៅមួយប្រភេទ មានផ្លែតាមស្លឹកស្អះដូចគេប្រក់។ |
| ប្រផេញ | ឈ្មោះឈើតូច។ |
| ប្រមោយដំរី | ឈ្មោះស្មៅមួយប្រភេទ។ |
| ប្រោះស្វា | ឈ្មោះប្រោះព្រៃ។ |

# ផ

ផ្កាចេក ឈ្មោះបន្លែក្រៀមមួយប្រភេទ។

ផ្កាស រុក្ខជាតិមួយប្រភេទដើមតូចៗ។

ផ្ទឹក ឈ្មោះឈើខ្លឹមមានសាច់រឹង។

ផ្ទៀក ឈ្មោះឈើធំមួយប្រភេទ។

ផ្ដៅ ឈ្មោះវល្លិដើមរឹងមួយប្រភេទ។

ផ្ទី ឈ្មោះស្មៅពួកមួយ មានបន្លាខ្លះឥតបន្លាខ្លះ។

ផ្ទី ឈ្មោះប្រទាលព្រៃមួយប្រភេទ ពួករំដេង។

ផ្ទោល ឈ្មោះឈើនោមមួយប្រភេទ ច្រើនប្រើធ្វើឧស។

ផ្នក់ទឹក ឈ្មោះស្មៅទឹកមួយប្រភេទ។

ផ្សិត ភូតគ្រាមពួកមួយ។

ផ្គាវ ឈ្មោះឈើពួកតចសារជាតិមួយប្រភេទ។

ផ្អុង ឈ្មោះឈើមួយប្រភេទជាអសារព្រឹក្ស។

| | |
|---|---|
| **ពងមាន់** (ព. ប្រ.) | ឈ្មោះចេកមួយប្រភេទ |
| **ពងលលក** (ព. ប្រ.) | ឈ្មោះដំឡូងព្រៃមួយប្រភេទ |
| **ពងលលក** (ព. ប្រ.) | ឈ្មោះផ្សិតមួយប្រភេទ |
| **ពង្រ** | ឈ្មោះឈើធំមួយប្រភេទ |
| **ពន្លៃ ១** | ឈ្មោះប្រទាលដើមរឹង |
| **ពពារនាគរាជ** | ឈ្មោះផ្សិតពុលមួយប្រភេទ |
| **ពពាលខែ** | ឈ្មោះឈើធំមួយប្រភេទ |
| **ពពូលថ្ម** | ឈ្មោះឈើមួយប្រភេទ |
| **ពពូលទឹក** | ឈ្មោះឈើមួយប្រភេទ |
| **ពពេចចង្វា** | ឈ្មោះឈើតូចមួយប្រភេទ |
| **ពពេល** | ឈ្មោះឈើមួយប្រភេទ |
| **ពភ្លា** | ឈ្មោះឈើធំមួយប្រភេទ |
| **ពាន់តា** | ឈ្មោះឈើមួយប្រភេទ |
| **ពីងពង់** | ឈ្មោះឫស្សីមួយប្រភេទ |
| **ពុកឆ្មា** | ឈ្មោះឈើតូចមួយប្រភេទ |
| **ពុកបង្កង** | ឈ្មោះស្មៅមួយប្រភេទ |
| **ពុតឆ្លេ** | ឈ្មោះប្រទាលមួយប្រភេទ។ |
| **ពុតឆ្លេ** | ឈ្មោះឈើមួយប្រភេទ ... ហៅ *ពោធិ៍ឆ្លេ* ក៏មាន។ |
| **ពុទ្ធជាត** | ឈ្មោះឈើមួយប្រភេទ។ |
| **ពោធិ៍ធំ** | ពោធិ៍ស្លឹកធំៗ។ |
| **ពោធិ៍បាយ** | អស្សត្ថព្រឹក្ស, ពោធិ៍មួយប្រភេទស្លឹកតូចៗ។ |
| **ពោល្យំ ឬ ពោរយំ** | ឈ្មោះឈើដំណាំដើមតូចៗ។ |

| | |
|---|---|
| ពោះអំបែង | ឈ្មោះវល្លិមួយប្រភេទ។ |
| ពុំសែន | ឈ្មោះឈើតូចមួយប្រភេទស្ទើរជាស្មៅ។ |
| ព្នឹល | ឈ្មោះឈើពួកមួយសន្តានញ្ញៅ។ |
| ញ្ញៅ | ឈ្មោះឈើពួកមួយ។ |
| ព្រងាល់ | ឈ្មោះឈើមួយប្រភេទ។ |
| ព្រហូត | ឈ្មោះឈើមួយប្រភេទ។ |
| ព្រាល | ឈ្មោះឈើតូចមួយប្រភេទ |
| ព្រិច ២ | ឈ្មោះរុក្ខជាតិព្រៃមួយប្រភេទ។ |
| ព្រីង | ឈ្មោះឈើមួយប្រភេទ។ |
| ព្រួស ២ | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ព្រះកម្ទាត់ | ឈ្មោះឈើមួយប្រភេទ។ |
| ព្រះកម្ទាយ | ឈ្មោះឈើមួយប្រភេទ។ |
| ព្រះក្រាប | ឈ្មោះស្មៅមួយប្រភេទ។ |
| ព្រះខ្លប | ឈ្មោះស្មៅមួយប្រភេទ។ |
| ព្រះថ្កោល | ឈ្មោះប្រទាលមួយប្រភេទ។ |
| ព្រះទ្រហឹង | ឈ្មោះស្មៅធំមួយប្រភេទ។ |
| ព្រះរំងាច | ឈ្មោះស្មៅមួយប្រភេទ ពួកផ្ទីថ្ម ។ |
| ព្រះអង្កោល | ឈ្មោះប្រទាលមួយប្រភេទ។ |
| ព្រះអន្លក់ | ឈ្មោះតិណជាតិមួយប្រភេទ។ |

## ភ

| | |
|---|---|
| ភង្គី | ឈ្មោះឈើតូចមួយប្រភេទ។ |
| ភ្លូ | រុក្ខជាតិព្រៃមួយប្រភេទ។ |
| ភ្នែកព្រាប | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ភ្លៅកង្កែប | ឈ្មោះស្មៅអណ្ដែតទឹកមួយប្រភេទ។ |
| ភ្លូង | ឈ្មោះព្រៃមួយប្រភេទ។ |
| ភ្លូ | រុក្ខជាតិព្រៃមួយប្រភេទ។ |
| ភ្លៅកង្កែប | ឈ្មោះស្មៅអណ្ដែតទឹកមួយប្រភេទ។ |
| ភ្លៅក្រោក | ឈ្មោះស្មៅមួយប្រភេទ។ |
| ភ្លៅនាង | ឈ្មោះឈើមួយប្រភេទ។ |
| ភ្លាំង ១ | ឈើឈើតូចមួយប្រភេទ។ |
| ភ្លាំង ២ | ឈ្មោះស្បូវមួយប្រភេទ។ |
| ភ្វាស | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ភ្នំភ្នែង | ឈ្មោះឈើនោមមួយប្រភេទ។ |
| ភ្លុក ១ | ឈ្មោះម្រះមួយប្រភេទផ្លែវែងៗ។ |
| ភ្លូ | ឈ្មោះព្រៃមួយប្រភេទ |

# ម

| | |
|---|---|
| មកា (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| មភ្លឿ (ស.) | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| មង្ឃុត | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| មន | ឈ្មោះឈើដំណាំមួយប្រភេទ |
| មន្ទារ (សំ. *មន្ទារ*) | ឈើតូចមួយប្រភេទ ពួកឃើហ៊ុប។ |
| មមាញ | ឈ្មោះស្មៅពួកមួយសន្តានផ្ទី។ |
| មហាត្រសាល | ឈ្មោះចេកមួយប្រភេទ។ |
| មហារម្លាយ | ឈ្មោះឈើមួយប្រភេទ។ |
| មាក់បាត | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| មាក់ប៉ែន | ឈ្មោះច័នមួយប្រភេទ។ |
| មាក់ប្រាង (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| មាក់ប្រេង (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| មាក់សាង (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| មាលតី (សំ. បា.) | ឈ្មោះឈើតូចមួយប្រភេទ។ |
| មឹង ២ | ឈ្មោះស្វាយមានរសជូរ។ |
| មុង្គ្រៃ | ឈ្មោះឈើតូចមួយប្រភេទ។ |
| មុខឈ្នាង | ឈ្មោះស្មៅមួយប្រភេទ។ |
| មៀន ២ | ឈ្មោះឈើមួយប្រភេទ។ |
| ម៉ៃស័ក ឬ ម៉ៃសាក់ | ឈ្មោះឈើធំមួយប្រភេទ។ |
| មោក | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ម្កាក់ | ឈ្មោះឈើមួយប្រភេទ។ |
| ម្នាស់ | ឈ្មោះដំណាំមួយពួក។ |

| | |
|---|---|
| **ម្រុម** ( ឥណ្ឌា *មរុម* ) | ឈ្មោះឈើមួយប្រភេទ។ |
| **ម្រេច** | ឈ្មោះដំណាំឡើងជន្លង់មួយប្រភេទ។ |
| **ម្រេចកង្កែប** | ឈ្មោះស្មៅមួយប្រភេទ។ |
| **ម្រះ** | ឈ្មោះវល្លិដំណាំឡើងទ្រើងមួយប្រភេទ។ |
| **ម្រះព្រៅ** | ឈ្មោះឈើតូចមួយប្រភេទពួកជីរ។ |
| **ម្រះព្រៅ** | ឈ្មោះឈើធំមួយប្រភេទ។ |
| **ម្លូ** | វល្លិឡើងជន្លង់ពួកមួយ។ |
| **ម្លូទេស** | ឈ្មោះតិណជាតិមួយប្រភេទ។ |
| **ម្អម** | តិណជាតិពួកមួយ។ |
| **ម្អមក្អាម** | ឈ្មោះតិណជាតិមួយប្រភេទ។ |

## យ

| | |
|---|---|
| **យាប្លង** | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| **យាវ** | ឈ្មោះវល្លិមួយប្រភេទ។ |
| **យីថៅ ឬ យិតថៅ** | ឈ្មោះឈើផ្កាកមានស្លឹកតូចជមវែងៗស្រួច។ |
| **យីស៊ុន** | ឈ្មោះឈើផ្កាមួយប្រភេទ។ |

## រ

| | |
|---|---|
| រកាដែក | ឈ្មោះឈើរកាមានបន្លាសុទ្ធតែដែក |
| រញា | ឈ្មោះឈើរនាមមួយប្រភេទ ផ្កាមានក្លិនក្រអូប។ |
| រណ្តាស | ឈ្មោះស្មៅពួកស្បូវមួយប្រភេទ។ |
| រម្យា (សំ.) | ផ្កាចម្ប៉ា។ |
| រលួស | ឈើមួយប្រភេទ ពួកអសារព្រឹក្ស។ |
| រលួស | ដំឡូងមួយប្រភេទ ដើមជាវល្លិ ... (ចិនហៅ ប៉ិក្កះ)។ |
| រលួសផ្អុង | អសារព្រឹក្សមួយប្រភេទ ពួករលួស។ |
| រលៀក | ឈ្មោះឫស្សីព្រៃមួយប្រភេទ ។ |
| រាក់ ២ | ឈ្មោះឈើតូច។ |
| រាជព្រឹក្ស | ឈើមួយប្រភេទ។ |
| រាត្រី ២ | ឈើតូចមួយប្រភេទ។ |
| រុករ | ឈ្មោះវល្លិរីងមួយប្រភេទ។ |
| រុន | កក់មួយប្រភេទ។ |
| រៃទឹក | ឈើតូចមួយប្រភេទ។ |
| រោល ២ | ឈ្មោះឈើមួយប្រភេទ។ |
| រំចាក | ឈ្មោះប្រទាលធំឬរុក្ខជាតិមួយប្រភេទ។ |
| រំចេក | ឈ្មោះប្រទាលធំឬរុក្ខជាតិមួយប្រភេទ។ |
| រំដែក | ឈ្មោះវល្លិមួយប្រភេទ ប្រើជាថ្នាំ។ |
| រំដួល | ឈ្មោះឈើមួយប្រភេទ។ |
| រំដេង | ឈ្មោះប្រទាលពួកប្រកោ។ |
| រំដេញ | ឈ្មោះឈើរនាម។ |
| រំដេញមាស | ឈ្មោះឈើមួយប្រភេទ។ |

| | |
|---|---|
| **រាំង ៣** | ឈ្មោះឈើ។ |
| **រាំងសាប** | ឈ្មោះឈើមួយប្រភេទ។ |
| **ឫសីផ្សំស្រេច ឬ ឥសី-ឫស្សី** | ឈ្មោះឈើមួយប្រភេទ។ |
| | តចសារជាតិមួយប្រភេទ។ |

# *ល*

| | |
|---|---|
| លម៉ើ | ឈ្មោះឈើមួយប្រភេទ។ |
| លាជផ្ទុះ | ឈ្មោះឈើតូចមួយប្រភេទ។ |
| លាយល័ក្ខ ឬ លាយល័ខ | ឈ្មោះឈើធំមួយប្រភេទ។ |
| លីងល័ក្ខ ឬ លីងល័ខ | ឈ្មោះដីរមួយប្រភេទ។ |
| លោទ (បា. *លោទ្ធ;* សំ. *លោជ្រ*) | ឈ្មោះឈើមួយប្រភេទ។ |
| លំញង ២ | ឈ្មោះគ្រប់មួយប្រភេទ។ |
| លំពស់ | ឈ្មោះឈើតូចមួយប្រភេទ។ |
| លំពាន់ | ឈ្មោះប្រទាលមួយប្រភេទ។ |
| លាំង | ឈ្មោះឈើធំមួយប្រភេទ។ |
| លាំងជ័យ ឬ លាំងដៃ | ឈ្មោះឈើមួយប្រភេទ។ |
| លាំងសាត (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| ល្បៀង | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ល្បៀងជូតអាចម៍កូន | ឈ្មោះឈើព្រៃមួយប្រភេទ។ |
| ល្ពៅ | ឈ្មោះវល្លិដំណាំវារ។ |
| ល្មុត ១ (ស.) | ឈ្មោះឈើដំណាំ។ |
| ល្មុត ២ (ស.) | ឈ្មោះខ្នុរមួយប្រភេទ។ |
| ល្វា | ឈ្មោះវនស្បតិ។ |
| ល្បៀង | ឈើព្រៃមួយប្រភេទ។ |
| ល្ហុង ១ | ដំណាំមួយប្រភេទ។ |
| ល្ហួត | ឈ្មោះស្វាយមួយប្រភេទ។ |

# វ

| | |
|---|---|
| **វង់ព្រះអាទិត្យ** | ឈ្មោះប្រទាលមួយប្រភេទសន្ដានត្រាវ។ |
| **វ៉ាន់ស៊ុយ** | ឈ្មោះដំណាំតិណជាតិ។ |
| **វាយ ២** | ឈ្មោះឈើមួយប្រភេទ។ |
| **វើក ១** | ឈ្មោះវល្លិមួយប្រភេទ។ |

## ស

សក់សេះ (ព. ប្រ.) ឈ្មោះប្រទាលមួយប្រភេទ (ពួកទាល់, ពួកផ្ដៅ)។

សក់សេះ (ព. ប្រ.) ឈ្មោះស្មៅមួយប្រភេទ។

សង្កែ ១ ឈ្មោះឈើអសារជាតិមួយប្រភេទ។

សង្កែភ្លើង ឈ្មោះឈើមួយប្រភេទ។

សង្ស័រ ឈើតូចមួយប្រភេទ មានបន្លាខុបៗ។

សណ្ដា ឈ្មោះវល្លិមួយប្រភេទ។

សណ្ដា ឈ្មោះឈើមួយប្រភេទ។

សណ្ដាន់ (ស.) ឈើនោមមួយប្រភេទ។

សណ្ដែក ដំណាំលតាជាតិ។

សណ្ដែកដី សណ្ដែកមួយប្រភេទ។

សម៉ ឈ្មោះឈើព្រៃ។

សម្ងរ ឬ សម៉ូរ ឈ្មោះសម៉មួយប្រភេទ។

សម្ពុង ១ ឈ្មោះឈើមួយប្រភេទ។

សម្បួរ ឬ សំបួរ ឈ្មោះឈើពួកមួយ។

សរព្រះ ឈ្មោះឈើអសារជាតិមួយប្រភេទ។

សសិត ២ ឈ្មោះស្មៅមួយប្រភេទ។

សហស្ស ឈ្មោះឈើមួយប្រភេទ

សាកែ ឈ្មោះឈើដំណាំមួយប្រភេទ។

សាគូនោម ឈ្មោះឈើតូចមួយប្រភេទ។

សាមសិប ឈ្មោះវល្លិមួយប្រភេទ។

សាវទាវ ឈ្មោះឈើមួយប្រភេទ។

សាវម៉ាវ ឈ្មោះឈើមួយប្រភេទ។

| | |
|---|---|
| សារាយ | រុក្ខជាតិមួយប្រភេទ។ |
| សិរមាន់ | ឈ្មោះឈើធំមួយប្រភេទ។ |
| សីរសាច់ | ឈ្មោះឈើតូចមួយប្រភេទ។ |
| ស្លូង ២ *កិ.* | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| ស្លូង ២ *កិ.* | ឈ្មោះម្លូមួយប្រភេទ។ |
| សោក ២ | ឈ្មោះឈើមួយប្រភេទ។ |
| សោម ២ | ឈ្មោះផ្កាមួយប្រភេទ។ |
| សំពង់ ឬ សំពុង | ឈ្មោះឈើធំមួយប្រភេទ។ |
| សំព័រ | ឈ្មោះឈើមួយប្រភេទ។ |
| ស្លួយ ឬ ស្លួយ | ឈ្មោះដំណាំមួយប្រភេទដើមនិងស្លឹក |
| សំកោក ២ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ស្គន់ | វល្លិទឹកមួយពួក។ |
| ស្គន់ទំនប់ | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| ស្គា | ឈ្មោះស្មៅមានដើមរឹង។ |
| ស្គុះ ២ | ឈ្មោះស្គន់មួយប្រភេទ។ |
| ស្វាប ២ | ឈ្មោះស្លាព្រៃ។ |
| ស្តី ២ | ឈ្មោះឈើធំមួយប្រភេទ។ |
| ស្តុកស្តុរ | ឈ្មោះឈើធំមួយប្រភេទ ... ហៅក្លាយជា |
| ស្នាំងហើរ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ស្នាយ ១ | ឈ្មោះឈើមួយប្រភេទ។ |
| ស្នាយដែល | ឈ្មោះឈើមួយប្រភេទ។ |
| ស្នែង ៤ | ឈ្មោះចេកឥតគ្រាប់យូងមួយប្រភេទ។ |
| ស្នែងពពែ | ឈ្មោះចេកមួយប្រភេទ។ |
| ស្នោ | ឈ្មោះឈើតូចមួយប្រភេទ។ |

| | |
|---|---|
| ស្បូវ | ស្មៅមួយប្រភេទ។ |
| ស្បែក ២ | ឈ្មោះវល្លិពពាយមួយប្រភេទ។ |
| ស្បែង | ឈ្មោះឈើមួយប្រភេទ។ |
| ស្បែរឿង | ឈ្មោះឈើតូចមួយប្រភេទ។ |
| ស្បែរឿង | ឈ្មោះផ្កាមួយប្រភេទ។ |
| ស្តង់ | ឈ្មោះឈើធំមួយប្រភេទ។ |
| ស្តី ១ | ឈ្មោះឈើដំណាំមួយប្រភេទ។ |
| ស្តែ | ដំណាំពួកមួយ។ |
| ស្តែគោក | ឈ្មោះតិណជាតិ។ |
| ស្តៅ ឬ ផ្តៅ | ឈ្មោះធញ្ញជាតិមួយប្រភេទ។ |
| ស្នាច់ ២ | ឈ្មោះឈើមួយប្រភេទ។ |
| ស្នាច់ដោម | ឈ្មោះឈើមួយប្រភេទ។ |
| ស្នី ១ | ឈ្មោះឈើមួយប្រភេទ។ |
| ស្នែ | ឈ្មោះឈើមួយប្រភេទ។ |
| ស្នោង | ឈ្មោះស្មៅមួយប្រភេទ។ |
| ស្មៅស្រូបពិសពស់ | ឈ្មោះស្មៅមួយប្រភេទ។ |
| ស្វា | ឈ្មោះដំឡូងព្រៃមួយប្រភេទ។ |
| ស្រកានាគ | ឈ្មោះប្រទាលមួយប្រភេទ។ |
| ស្រគំ | ឈ្មោះឈើធំមួយប្រភេទ។ |
| ស្រងែ | ធញ្ញជាតិមួយប្រភេទ។ |
| ស្រដែត | ឈ្មោះប្រទាលមួយប្រភេទ។ |
| ស្របាល ២ ឬ សាបាល | ឈ្មោះស្មៅទឹកមួយប្រភេទ។ |
| ស្រលិត ឬ ស្រឡិត | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្រឡៅ | ឈ្មោះឈើធំមួយប្រភេទ។ |

| | |
|---|---|
| ស្រឹង ២ | ឈ្មោះឫស្សីព្រៃមួយប្រភេទ។ |
| ស្រឹង ២ | ឈ្មោះខ្ទឹមមួយប្រភេទ។ |
| ស្រូល | ឈ្មោះឈើមួយប្រភេទ។ |
| ស្រូល | ឈ្មោះឈើមួយប្រភេទទៀត ពួកច្រកែងទួយ។ |
| ស្រំ ២ | ឈ្មោះដំឡូងព្រៃមួយប្រភេទ។ |
| ស្លូត | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្លា | ដំណាំមួយប្រភេទ។ |
| ស្លាក់ ២ | ឈ្មោះឈើតូច។ |
| ស្លាកំញាន | ឈ្មោះស្លាមួយប្រភេទ។ |
| ស្លាផ្កា | ឈើមួយប្រភេទ។ |
| ស្លាឈ្មោល | ឈ្មោះរុក្ខជាតិមួយប្រភេទ។ |
| ស្លាតឱន ឬ ស្លាត្រឱន | ឈ្មោះឈើតចសារជាតិមួយប្រភេទ។ |
| ស្លាបច្រវា | ស្មៅទឹកមួយប្រភេទ។ |
| ស្លាបទា | ស្មៅទឹកមួយប្រភេទ។ |
| ស្លាអី | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្លឹកគ្រៃ | តិណជាតិមួយប្រភេទ។ |
| ស្លែង ២ | ឈ្មោះឈើពុល។ |
| ស្លែងដងដឹង | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្លែងព្រវៀក | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្វាត | ឈ្មោះវល្លិមួយប្រភេទ។ |
| ស្វាយចន្ទី | ឈ្មោះឈើមួយប្រភេទ។ |
| ស្អំ ២ | ឈ្មោះឈើមួយប្រភេទ។ |

## ហ

**ហោរ៉ា** ឈ្មោះក្អាតមួយប្រភេទ។

**ហ្ន័ង, ហ្នាំង** ២ ឬ **ណាំង** (ស.) ឈ្មោះខ្នុរមានសាច់ក្លែបរឹងបន្តិច។

*អ*

| | |
|---|---|
| អង្កាញ់ ១ | ឈ្មោះឈើមួយប្រភេទ។ |
| អង្កាម | ឈ្មោះដំរីមួយប្រភេទ។ |
| អង្គញដី | ឈ្មោះវល្លិមួយប្រភេទ។ |
| អង្ក្រមអង្ក្រម | ឈ្មោះវល្លិតូចមួយប្រភេទ។ |
| អង្គញ់ | ឈ្មោះវល្លិមួយប្រភេទ។ |
| អង្គញ់ស្វា | ឈ្មោះឈើធំមួយប្រភេទ។ |
| អង្គត់ ឬ អង្គទ ១ | ឈ្មោះវល្លិមួយប្រភេទ។ |
| អង្គា ២ | ឈ្មោះឈើមួយប្រភេទ ផ្កាសម្បុរលឿង។ |
| អង្គាដី | ឈ្មោះឈើស្រុក។ |
| អង្គាលឿង | ម.ព. *អង្គា ២*។ |
| អង្គាសីល | ម.ព. *អង្គា ២*។ |
| អង្គាបុស្ប | ឈ្មោះឈើមួយប្រភេទ។ |
| អង្គ្រង | ឈ្មោះឈើមួយប្រភេទ។ |
| អង្រែដែក | ឈ្មោះប្រទាលមួយប្រភេទ។ |
| អញ្ចាញ | ឈ្មោះឈើមួយប្រភេទ។ |
| អញ្ជ័ន (សំ. បា.) | ឈ្មោះវល្លិមួយប្រភេទ។ |
| អណ្តាតគោ | ឈ្មោះតិណជាតិគោកមួយប្រភេទ។ |
| អណ្តាតត្រកួត | ឈ្មោះឈើមួយប្រភេទ។ |
| អន្ទង់រីត | ឈ្មោះរុក្ខជាតិមួយប្រភេទ។ |
| អម្ពិល | ហៅឈើពួកមួយ។ |
| អម្ពិលទឹក | ឈ្មោះឈើមួយប្រភេទ។ |
| អម្ពិលប្រក់ផ្លែ | ឈ្មោះតិណជាតិស្មើរជាឈើមួយប្រភេទ។ |

| | |
|---|---|
| អាចម៍ឆ្មា | ឈ្មោះអម្ពិល។ |
| អាចម៍ឆ្កែស | ឈ្មោះប្រទាលមួយប្រភេទ។ |
| អាចម៍ដំរី | ឈ្មោះខ្នុរមួយប្រភេទ។ |
| អាចម៍មាន់ | ឈ្មោះផ្ទីមួយប្រភេទ។ |
| អាគៀន | ដំណាំមួយប្រភេទ។ |
| អារ៉ូកាចេរ (បារ.) | ឈ្មោះឈើជាដំណាំមួយប្រភេទ។ |
| ឥន្ទនេល | ឈ្មោះឈើមួយប្រភេទ។ |
| អ៊ីត | ឈ្មោះក្រូចមួយប្រភេទ។ |
| អុបធិយ (ស.) | ឈ្មោះឈើមួយប្រភេទ។ |
| ឪដំ | ឈ្មោះវល្លិមួយប្រភេទ។ |
| ឪណុល | ឈ្មោះវល្លិមួយប្រភេទ។ |
| ឪឡ | ឈ្មោះវល្លិមួយប្រភេទ។ |
| ឪឡឹក | ឈ្មោះដំណាំមួយប្រភេទ។ |
| ឪឡោក | ឈ្មោះឈើធំមួយប្រភេទ។ |
| អំបឹះ ឬ អំបើះ | ឈ្មោះរុក្ខជាតិពួកមួយ។ |
| អំបែងថ្ងៃ | ឈ្មោះឈើមួយប្រភេទ។ |
| អំពៅ | ឈ្មោះដំណាំពួកមួយ។ |
| អំពៅព្រៃ | ឈ្មោះតិណជាតិដើមរឹងមួយប្រភេទ។ |
| អំព្រំ | ឈ្មោះឈើមួយប្រភេទ។ |
| អំព្រំប្រែក្រាយ | ឈ្មោះឈើមួយប្រភេទ។ |